# ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៨
# តុលាការសម្រេចឃុំខ្លួនបុរសចិន៣នាក់និងស្ត្រីខ្មែរម្នាក់បណ្ដោះអាសន្ន ពាក់ព័ន្ធរឿង នាំស្ត្រីខ្មែរទៅការប្តីនៅស្រុកចិន

http://www.yobminh.com/ បញ្ញា | May 2, 2018

ភ្នំពេញ៖ យោងតាមប្រភពពីសមត្ថកិច្ចអាវុធហត្ថរាជធានីភ្នំពេញ បានឲ្យដឹងថា កាលពីរសៀលថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៨ម្សិលមិញ លោក កួយ សៅ ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានចេញដីកាបង្គាប់ឲ្យឃុំខ្លួនបុរស ចិន ៣នាក់ និងស្ត្រីខ្មែរម្នាក់ ជាបណ្ដោះអាសន្ន នៅពន្ធនាគារព្រៃស ពាក់ព័ន្ធ ករណី នាំស្ត្រីខ្មែរទៅរៀបការនៅប្រទេសចិន។ សមត្ថកិច្ចឲ្យដឹងថា ជនត្រូវចោទទាំង ០៤នាក់រួមមាន៖

-ទី១ឈ្មោះ JI JIAXIN ភេទប្រុស ជនជាតិចិន ( ជាប្តី )

-ទី២ឈ្មោះ តែម អឿន ភេទស្រី ជនជាតិខ្មែរ ( ជាប្រពន្ធ )

-ទី៣ឈ្មោះ ZHANG LIANG ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិចិន ( ជាអ្នកទិញនារីខ្មែរធ្វើប្រពន្ធ )

-និងទី៤ឈ្មោះ YAN FAN ភេទប្រុស អាយុ ២៨ឆ្នាំ ជនជាតិចិន ( ជាអ្នកទិញនារីខ្មែរធ្វើប្រពន្ធ )

ប្រភពដដែលបាន ឲ្យដឹងថា លោក ហោ លីណា ជាតំណាងអយ្យការបានចោទប្រកាន់ លើជនត្រូវចោទទាំង ០៤នាក់ ពីបទ ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ ប្រព្រឹត្តនៅរាជធានីភ្នំពេញ យោងតាមមាត្រា ១០ នៃច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

សូមបញ្ជាក់ថា ដោយមានកិច្ចសហការរវាង សមត្ថកិច្ចអាវុធហត្ថរាជធានីភ្នំពេញ និងអង្គការមេត្រីភាព អន្តរជាតិ ហៅកាត់ថា AIM SWAT បានឃាត់ខ្លួនក្រុមជនត្រូវចោទខាងលើ កាលពីយប់ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៨ នៅចំណុចផ្ទះសំណាក់មុដមាស ក្បែរផ្សារទំនើបស្ទឹងមានជ័យ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ខណៈដែលពួកគេកំពុង ពិភាក្សាគ្នា និងរៀបចំឯកសារ ចេញទៅប្រទេសចិន ក្រោមរូបភាពរៀបអាពិហ៍ពិពាហ៍។ ក្រោយឃាត់ខ្លួនក្រុមជនត្រូវចោទខាងលើសមត្ថកិច្ចបានជួយសង្គ្រោះ បាន នារីខ្មែររងគ្រោះ ចំនួន ០២នាក់ ដែលមានស្រុកកំណើតមកពីខេត្តតាកែវ ៕

# លោកវរៈសេនីយ៍ឯក ង៉ែត ព្រឿង ប្រឆាំងនឹងបទបញ្ជាសម្ដេចក្រឡាហោម ស ខេង បើកច្រករបៀងនាំពលករ និងទំនិញគេចពន្ធឆ្លងដែនដោយខុសច្បាប់

http://bayontv.com.kh/ 03/05/2018

បន្ទាយមានជ័យ ៖ ប្រភពព័ត៌មាន បានទម្លាយថា លោកវរសេនីយ៍ឯក ង៉ែត ព្រឿង កំពុងប្រឆាំង និងបទបញ្ជាសម្ដេចក្រឡាហោម ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បើកច្រករបៀងខុសច្បាប់ នាំពលករ នឹងទំនិញគេចពន្ធឆ្លងដែនដោយខុសច្បាប់ ។ ប្រភពព័ត៌មាន ដដែល បានបន្តថា លោកវរៈសេនីយ៍ឯក ង៉ែត ព្រឿង មិនគិតពីសុវត្ថិភាព ពលករចំណាកស្រុក និង លោកគិតតែពីប្រមូលលុយដាក់ ហោប៉ៅ នឹងគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួនតែប៉ុណ្ណោះ។ លោកវរសេនីយ៍ឯក ង៉ែត ព្រឿង បានបើកច្រករបៀង អនុញ្ញាតឲ្យពលករខ្មែរ លួចឆ្លងដែនទៅប្រទេសថៃ ដោយខុសច្បាប់ មិនខ្លាចពលករជួបនឹងការដេញចាប់ ពីសមត្ថកិច្ចថៃនោះទេ...??? ខ្លះទៀត បើករថយន្តរត់គេច ជួបនិងឧបទ្ទវហេតុផ្សេងៗ ហើយបានចាប់បញ្ជូនមក កម្ពុជាវិញ ក្នុង១ថ្ងៃៗ មិនក្រោមពី២០០នាក់ ទៅ២៥០នាក់ រឺអាចលើសពីនេះទៅទៀត។

សូមបញ្ជាក់ថា ស្ថិតក្នុងភូមិក្តិបថ្ម ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ គ្រប់គ្រងដោយ លោកវរសេនីយ៍ឯក ង៉ែត ព្រឿង យោធាភូមិភាគ៥ តំបន់អភិវឌ្ឍន៍ភ្នំធំត្រ បានបើកដៃ អោយកូនចៅរបស់ខ្លួន ឃុបឃិតគ្នា

ជាមួយមេខ្យល់ នាំពលករ នឹងទំនិញគេចពន្ធឆ្លងដែនដោយខុសច្បាប់ មានទាំងរថយន្តសេរីទំនើប ថែមទាំងមានរថយន្តតាក់ស៊ី ក្នុងនោះក៏មានមន្ត្រីរាជការ បានចូលទៅដឹក ។

សូមរំលឹកថា កន្លងមក សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី ស ខេង រដ្ឋមន្ត្រីក្រសួង មហាផ្ទៃ បានបញ្ជាក់ថា (ច្រករបៀង )ទាំងអស់ ត្រូវតែបិត មិនឲ្យបើកនោះឡើយ ព្រោះនាំអោយខាតបង់ ដល់ថវិកាជាតិ យ៉ាងច្រើនផងដែរ "។ ពាក់ព័ន្ធព័ត៌មាន ខាងលើនេះ BTV News មិនអាចសុំការបំភ្លឺពី លោកវរៈសេនីយ៍ឯក ង៉ែត ព្រឿង បាននៅឡើយទេ យើងនិងរងចាំការបកស្រាយគ្រប់ពេល ដើម្បីទទួលបានភាពយុត្តិធម៌៕

## អាជ្ញាធរថៃ ចាប់ជនសង្ស័យចាក់សម្លាប់ ពលករខ្មែរ បានហើយ

https://www.dap-news.com/kh/ ព្រហស្បតិ៍, 03 ឧសភា ២០១៨ 07:15 ដោយ: រិទ្ធិ ជ័យ ID:119

ប៉ៃលិន៖ កម្លាំងអាជ្ញាធរថៃ បានស្រាវជ្រាវចាប់ ជនសង្ស័យម្នាក់ ពីបទចាក់សម្លាប់ពលករខ្មែរ នៅក្នុងវង់ផឹកស៊ី ការឃាត់ខ្លួននេះធ្វើឡើងនៅល្ងាចថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៨ នៅខេត្តសាមុតប្រាកាន ប្រទេសថៃ បន្ទាប់ពីធ្វើសកម្មភាព រួចជនសង្ស័យបានរត់គេចខ្លួនបានមួយយប់ ។ បើតាមនគរបាលខេត្តប៉ៃលិន ទទួលព័ត៌មានពីអាជ្ញាធរថៃ បានឲ្យដឹងថា ជនសង្ស័យឈ្មោះ ពៅ សីហា ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ ជាពលករចំណាកស្រុកដូចគ្នា ។

គួរបញ្ជាក់ថា កាលពីវេលាម៉ោង ៩ និង៣០នាទី យប់ថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៨ មានបើកវង់ផឹកស៊ីមួយរវាងពលករខ្មែរធ្វើការនៅថៃ នៅចំណុចបន្ទប់លេខ១៣ ក្នុងអាផាតមែន ស្ថិតក្នុងភូមិឡាតប្រាជីវ ស្រុកឡាតក្រាបាំង ក្រុងបាងកក ដល់ពេលផឹកស៊ីយូរទៅ ក៏មានជម្លោះពាក្យសម្តីកើតឡើង ។ ទំនាស់ពាក្យសម្តីនេះជនសង្ស័យ ទាញកាំបិតមកចាក់ជនរងគ្រោះឈ្មោះ ចេង រ៉ាក់ ភេទប្រុស អាយុ២៧ឆ្នាំ ជាពលករដូចគ្នា ដែលមានស្រុកកំណើតនៅខេត្តកំពង់ឆ្នាំង ស្លាប់តែម្តង ៕

## កម្ពុជាមានកម្លាំងពលកម្មជាង១០លាននាក់ កំពុងបម្រើការងារក្នុង ឆ្នាំ២០១៨

https://www.facebook.com/TheSEATVNews/ ថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០១៨

ភ្នំពេញ ៖ វិស័យការងារនៅក្នុងប្រទេសកម្ពុជា មើលឃើញថាមានការរីកចម្រើនគួរឲ្យកត់សម្គាល់ ក្នុងនោះអត្រាមានការងារធ្វើ ក្នុងឆ្នាំ២០១៨ មានរហូតដល់ ៩៩,៣ភាគរយ រី ស្មើនឹងកម្លាំងពលកម្មសរុបជាង១០លាននាក់។

យោងតាមរបាយការណ៍របស់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បង្ហាញថា ក្នុងឆ្នាំ២០១៨នេះ ចំនួនសហគ្រាស គ្រឹះស្ថានសេដ្ឋកិច្ចក្នុងប្រព័ន្ធ ដែលបានចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានចំនួនសរុបជាង១ម៉ឺន២ពាន់គ្រឹះស្ថាន ចំនួននេះកើនឡើងនប្រមាណ១០%ពីឆ្នាំមុន ដែលកំពុងផ្តល់ការងារដល់កម្មករនិយោជិតសរុបជិត១លាន៥សែននាក់ ក្នុងនោះមានកម្លាំងជាស្ត្រីមានជាង៨សែននាក់ គឺកើនឡើងជាង២១% ។ ចំណែកចំនួនសហគ្រាស គ្រឹះស្ថានសេដ្ឋកិច្ចក្រៅប្រព័ន្ធ គិតត្រឹមឆ្នាំ២០១៨នេះមានចំនួនសរុប ជិត៦០ម៉ឺនសហគ្រាស ក្នុងនោះមានកម្មករជាង២លាន៤សែននាក់! កម្លាំងពលកម្មក្នុងវិស័យកសិកម្មមានប្រមាណជាង៤លាននាក់! ពលករធ្វើការនៅក្រៅប្រទេស មានប្រមាណ១លាន២សែននាក់ និងមន្ត្រីសាធារណៈ ជាង៥សែននាក់ ។

តាមការលើកឡើងរបស់ លោក អ៊ិត សំហេង នាពេលកន្លងមកបានបញ្ជាក់ថាប្រព័ន្ធអធិការកិច្ចការងារក្នុងប្រទេសកម្ពុជាត្រូវបានកែទម្រង់ ដោយពង្រឹងការអនុវត្តច្បាប់ស្តីពីការងារ ច្បាប់ស្តីពីសហជីព ដែលធ្វើឱ្យលក្ខខណ្ឌការងារ និងការទំនាក់ទំនងវិជ្ជាជីវៈកាន់តែមានភាពប្រសើរឡើង។ ទន្ទឹមនឹងនេះ បញ្ហាកូដកម្ម បាតុកម្ម ត្រូវបានដោះស្រាយប្រកបដោយប្រសិទ្ធភាព ។ យន្តការត្រីភាគីត្រូវបានពង្រឹង និងបន្តតួនាទីដ៏សំខាន់ក្នុងការដោះស្រាយបញ្ហានានា ដែលទាក់ទងនឹងផលប្រយោជន៍របស់កម្មករនិយោជិត និងនិយោជក » ។

គួរកត់សំគាល់ថា ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើងក្នុងឆ្នាំ២០១៨ ត្រូវបានដំឡើងពីចំនួន១៥៣ដុល្លារដល់១៧០ដុល្លារ គឺកើន១១,១% បើគិតពីប្រាក់អត្ថប្រយោជន៍ផ្សេងៗទៀត កម្មករនិយោជិតម្នាក់ៗអាចទទួលបានប្រាក់ចំណូលពី១៨៧ ទៅ១៩៨ដុល្លារអាមេរិកក្នុង១ខែ ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលកំពុងរៀបចំច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ដើម្បីធានាការលើកកម្ពស់ជីវភាពរបស់កម្មករនិយោជិតផងដែរ ។ លោកក៏បានលើកឡើងថា គិតត្រឹមត្រីមាសទី១ ឆ្នាំ២០១៨ កម្ពុជាមានសហជីពមូលដ្ឋានកើនរហូតដល់ចំនួន៤.២២៧, សហព័ន្ធសហជីព១៥៨, សហភាពសហជីព២៥, សមាគម៩, អង្គការ៤ និងសមាគមនិយោជក៨ ។

ចំពោះការអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ដែលរាជរដ្ឋាភិបាល កំពុងផ្តល់ជូនកម្មករនិយោជិក នាពេលនេះ មានដូចជា ៖ -ការពិនិត្យ និងព្យាបាលជំងឺនៅតាមមន្ទីរពេទ្យរដ្ឋ ដោយមិនបង់ប្រាក់ ។ - ការផ្តល់ប្រាក់ឈ្នួល១២០% និងការឈប់សម្រាករយៈពេល៣ខែក្នុងពេលសម្រាលកូន ជូនកម្មការិនី ។ -ការផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មការិនីសម្រាលកូន ១នាក់ ទទួលបាន ថវិកាចំនួន៤០ម៉ឺនរៀល, កូន២នាក់ ថវិកាចំនួន៨០ម៉ឺនរៀល និងកូន៣នាក់ ថវិកាចំនួន១លាន ២សែនរៀល ព្រមទាំងទទួលបានថវិកាបន្ថែមចំនួន៥លានរៀលពីសម្តេចតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិតផ្ទាល់ ។

រាជរដ្ឋាភិបាលបានកំណត់ឱ្យ និយោជក ជាប់កាតព្វកិច្ចបង់វិភាគទានរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព ១០០% ជំនួសកម្មករ និយោជិត ចាប់ពីខែមករា ឆ្នាំ២០១៨ ។ -រដ្ឋបាលថ្នាក់ក្រោមជាតិ បានត្រួតពិនិត្យជាប្រចាំនូវថ្លៃឈ្នួលផ្ទះ ថ្លៃទឹក និងថ្លៃអគ្គិសនី នៅតាមផ្ទះជួល និងបានផ្តល់ជូនកម្មករនិយោជិតធ្វើដំណើរតាមរថយន្តក្រុងនៅរាជធានីភ្នំពេញ ដោយឥតបង់ប្រាក់ ។ រាជរដ្ឋាភិបាលកំពុងរៀបចំដាក់ឲ្យអនុវត្តនូវរបបសន្តិសុខសង្គម ផ្នែកសោធននិវត្តន៍ ឆ្នាំ២០១៩ ។ -រាជរដ្ឋាភិបាលបានផ្តល់បុរេប្រទានថវិកាចំនួនជាង៤លាន៦សែនដុល្លារសម្រាប់ទូទាត់ប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ផ្សេងៗជូនកម្មករនិយោជិត ដែលរោងចក្របិទទ្វារដោយសារម្ចាស់រត់ចោល និងរៀបចំបទប្បញ្ញត្តិដើម្បីធានាអត្ថប្រយោជន៍របស់កម្មករនិយោជិតចំពោះករណីនេះនាពេលខាងមុខ ។ -

រាជរដ្ឋាភិបាលកំពុងបន្តពង្រឹងកិច្ចសហការជាមួយប្រទេសដៃគូ ដើម្បីបន្តផ្តល់ឱកាសការងារជូនពលករ ការពារសិទ្ធិ និងផលប្រយោជន៍ពលករ ដែលកំពុងបម្រើការងារនៅប្រទេសទាំងនោះ និងបង្កលក្ខណសម្បត្តិឱ្យពលករក្រៅប្រទេសទទួលបានរបបគាំពារសង្គមទាំងនាពេលបច្ចុប្បន្ន និងពេលវិលត្រឡប់មកកម្ពុជាវិញផងដែរ ៕

## ទីតាំងធ្វើលិខិតឆ្លងដែនធ្វើការ ជូនពលករកម្ពុជា នៅខេត្តឈុនបុរី បើកដំណើរការហើយ.!

http://www.pheaktraprak.com May 1, 2018

ក្រុមការងារផ្តល់ភាពស្របច្បាប់ ជូនបងប្អូនពលករកម្ពុជានៅក្នុងប្រទេសថៃ បានចល័តទៅបើកដំណើរការបញ្ជាក់អត្តសញ្ញាណ(ធ្វើលិខិតឆ្លងដែនធ្វើការ) ជូនបងប្អូនពលករកម្ពុជាដែលធ្វើការរស់នៅក្នុងខេត្តឈុនបុរីហើយ ។ បានបើកការិយាល័យធ្វើលិខិតឆ្លងដែនធ្វើការនៅក្នុងហាងទំនើប vicory center Chonburi (ហាងទំនើបវីយោរី ុស៊េនធ័រឈុនបុរី) រៀងរាល់(ច័ន្ទ-សៅរ៍) ចាប់ពីវេលាម៉ោង០៨:៣០នាទីព្រឹកដល់ម៉ោង០៤:៣០នាទីល្ងាច។ ដូច្នេះហើយសូមបងប្អូនពលករកម្ពុជាដែលកំពុងធ្វើការនៅក្នុងខេត្តឈុនបុរី ហើយមិនបានបានធ្វើប៉ាស្ព័រ សូមប្រញាប់រួសរាន់ទំនាក់ទំនងសុំលេខរៀងធ្វើពីមន្ទីការងារខេត្តឈុនបុរី ដើម្បី បញ្ជាក់អត្តសញ្ញាណអោយបានរួចរាល់តាមការកំណត់។

## ក្រុមការងារទទួលបន្ទុកទីប្រឹក្សាពលករកម្ពុជា ប្រចាំប្រទេសថៃ កំពុងរកយុត្តិធម៌ ជូនពលករកម្ពុជា ចំនួន ២៨នាក់

http://www.pheaktraprak.com May 3, 2018

ក្រុមការងារទទួលបន្ទុកទីប្រឹក្សាពលករកម្ពុជា ប្រចាំប្រទេសថៃ បានធ្វើដំណើរមកដាក់ពាក្យបណ្តឹងនៅមន្ទីរគាំពារពលករ ប្រចាំខេត្តសមុតប្រាកាន ប្រទេសថៃ ។ ក្នុងករណីពលករកម្ពុជាចំនួន ២៨ នាក់ ដែលធ្វើដំណើរចូលមកធ្វើការ នៅក្នុងខេត្តសមុុតប្រាកាន ប្រទេសថៃ តាមរយៈក្រុមហ៊ុនមួយ ដែលសន្យាថានិងធ្វើឯកសារស្របច្បាប់អោយពួកគាត់យ៉ាងត្រឹមត្រូវ តែពេលវេលាកន្លងទៅជាង ៧ខែ អ្នកគ្រប់គ្រងរោងចក្របានកាត់ប្រាក់ពួកថ្លៃដើររឿងធ្វើលិខិតឆ្លងដែន MOU អស់រួចហើយ ប៉ុន្តែបែរជាមិនបានរឿងអោយ ហើយព្រមទាំងបញ្ឈប់ពួកគាត់អោយធ្វើការទៀត ព្យ៉ាងអយុត្តិធម៌ ។ បច្ចុប្បន្ននេះក្រុមការងារទីប្រឹក្សាពលករកម្ពុជាប្រចាំប្រទេសថៃ កំពុងប្រជុំជាមួយមន្ទីរការងារខេត្តសមុតប្រាកាន និង មន្ទីរគាំពារពលករខេត្ត រួមទាំងភ្នាក់ងារមានសមត្ថកិច្ច កំពុងរកវិធានការដោះស្រាយបញ្ហា ជូនបងប្អូនពលករខ្មែរ ដែលរងគ្រោះ អោយទទួលបានយុត្តិធម៌ និងប្រាក់សំណងយ៉ាងត្រឹមត្រូវតាមផ្លូវច្បាប់។ ០៣-០៥-២០១៨

## ក្រសួងការងារ បញ្ចេញឈ្មោះក្រុមហ៊ុនបញ្ជូនពលករទៅជប៉ុន ស្របច្បាប់

http://kleykley.sabay.com.kh/ ពុធ, 2 ឧសភា 2018 11:17

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ បានបញ្ចេញឈ្មោះក្រុមហ៊ុនឯកជនដែលមានសិទ្ធិជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងកម្មសិក្សាខ្មែរទៅធ្វើកម្មសិក្សា និងធ្វើការនៅប្រទេសជប៉ុន ចំនួន៨៣ក្រុមហ៊ុន។ ចំនួននេះ គឺកើនឡើងពី៧៩ក្រុមហ៊ុន ដែលក្រសួងបានប្រកាសកាលពីដើមឆ្នាំនេះ។ ក្រសួងបញ្ជាក់ថា រាល់ក្រុមហ៊ុនណា ដែលពុំមានឈ្មោះក្នុងបញ្ជីខាងក្រោមនេះទេ គឺចាត់ទុកថាជាក្រុមហ៊ុនខុសច្បាប់ ដោយក្រសួងបានអំពាវនាវឲ្យសាធារណជន រាយការណ៍ជាបន្ទាន់ទៅទូរសព្ទលេខ ០២៣ ៨៨០ ៤៧៤ និងទំនាក់ទំនងមន្ទីរការងារទាំង២៥ រាជធានី-ខេត្ត នៅរៀងរាល់ម៉ោងធ្វើការ។ ជាមួយគ្នានេះ ក្រសួងការងារ ក៏ទើបតែបញ្ចេញឈ្មោះក្រុមហ៊ុនឯកជនស្របច្បាប់ចំនួន២៧ផងដែរ ក្នុងការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសអារ៉ាប៊ីសាអ៊ូឌីត។

គួររម្លឹកថា នៅក្នុងរបាយការណ៍១របស់ក្រសួងការងារ ចេញផ្សាយកាលពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ បានឲ្យដឹងថា ចំនួនក្រុមហ៊ុនស្របច្បាប់បញ្ជូនពលករទៅធ្វើការនៅបរទេសមាន ៩០ក្រុមហ៊ុន។ ក្រុមហ៊ុនស្របច្បាប់ទាំងនោះ បានបញ្ជូនទៅប្រទេសគោលដៅចំនួន៦ ក្នុងប្រទេសថៃ មានចំនួន ៦១កន្លែង ម៉ាឡេស៊ី ៥៨កន្លែង ជប៉ុន ៧៩កន្លែង ហុងកុង ៦កន្លែង និងអារ៉ាប់ចំនួន២៣កន្លែង។ ដោយឡែក នៅកូរ៉េខាងត្បូងដែលជាប្រទេសមានពលករខ្មែរធ្វើការរាប់ម៉ឺននាក់ដែរនោះ គឺក្នុងរបាយការណ៍ក្រសួងការងារ មិនបានបង្ហាញឈ្មោះក្រុមហ៊ុន ឯកជនស្របច្បាប់ដែលបញ្ជូនទៅឡើយ៕

## ពលករ២នាក់បានស្លាប់ និងជាង១០នាក់ទៀតរងរបួសធ្ងន់ស្រាលក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍នៅប្រទេសថៃ

http://nokorwatnews.com/ ថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០១៨

ប៉ោយប៉ែត៖ សពពលករខ្មែរម្នាក់បានបញ្ជូន មកតាមច្រកទ្វារអន្តជាតិប៉ោយប៉ែតកាលពីវេលាម៉ោង៨និង៣៥នាទីរសៀល ថ្ងៃព្រហស្បតិ៍ ៤រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៨ ដើម្បីសាងនៅក្នុងវត្តបាលិលេយ្យ និងដឹកបន្តទៅធ្វើបុណ្យនៅ ស្រុកកំណើតក្នុងខេត្តព្រៃវែង ។ ចំណែកសពម្នាក់ទៀតរួមទាំងពលករប្រុស ស្រីជាង១០នាក់ នៅសម្រាកក្នុងមន្ទីរពេទ្យក្នុងខេត្តឈុនបូរី(ថៃ) ។

បុរសម្នាក់មានឈ្មោះ ចេក អាយុ២៤ឆ្នាំ រស់នៅភូមិគ្រើល ឃុំព្រែករំដេង ស្រុកមេសាងខេត្តព្រៃវែងនៅក្នុងហេតុការគ្រោះថ្នាក់ចរាចរណ៍ប្រទេសថៃអះអាងថា សពរងគ្រោះត្រូវជាសាច់ញ្ញាតិឈ្មោះដុង គ្រាក់ គេទ្រុស អាយុ៣៥ឆ្នាំ រស់នៅភូមិជាមួយ ។ បុរសរូបនោះបន្តថា ចំណែកសពម្នាក់ទៀតគាត់មិនស្គាល់អត្តញ្ញាណឡើយ តែត្រូវបងប្អូនយកមកស្រុកកំណើតតាមច្រកតំបន់ផ្សេង រីឯពលករប្រុសស្រី រងរបួសធ្ងន់ស្រាលជាង១០នាក់ទៀត ក្នុងហេតុការគ្រោះថ្នាក់ចរាចរណ៍នៅប្រទេសថៃនោះកំពុងតែសម្រាកនៅមន្ទីរពេទ្យពីក្នុងខេត្តប្រាជីបូរី(ថៃ) ។ ហើយក្រុមពលករ ដែលជួបគ្រោះថ្នាក់ចរាចរណ៍ខាងលើនោះត្រូវមេខ្យល់នាំចេញទៅធ្វើការ ជាកម្មករគេនៅប្រទេសថៃ ក្នុងខេត្តឈុនបូរី តាមច្រករបៀងមួយកន្លែងក្នុង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ដោយជិះរថយន្តរបស់ថៃចេញពីព្រំដែននៅម៉ោង១២យប់ ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៨ ។

ក្រុមពលករប្រុសស្រីដែលឆ្លងដែននោះជិះរថយន្តម៉ាកវីហ្គោមួយបាំងកន្លះពណ៌ខ្មៅមិនស្គាល់ស្លាក់លេខ ពលករដែលជិះទៅជាមួយខ្លួនមានចំនួន២៤នាក់ដោយអ្នកជិះរថយន្តខាងក្រោយ ១២នាក់គេគ្រប់តង់កៅស៊ូខ្មៅពីលើចំណែកអ្នកជិះក្នុងកាប៊ីនជាមួយតៃកុងរថយន្តចំនួន១២នាក់ដែរ ។ នៅក្នុងការធ្វើដំណើរដោយមានល្បឿនលឿន ម្យ៉ាងអ្នក បើកបររថយន្តមានភាពស្រវឹង លុះធ្វើដំណើរបានប្រហែល២ម៉ោងចូលដល់ខេត្តធាក់ធីនសៅ(ថៃ)ស្រាប់តែជួបតម្រួតថៃដែលពួនស្ទាក់នៅក្នុងព្រៃហៅឲ្យម្ចាស់រថយន្តឈប់ តែមិនឈប់នៅតែបន្តដំណើរទៅមុខទៀតស្របពេលនោះតម្រួតថៃបានជិះរថយន្តប្រដេញតាមបាញ់ពីក្រោយចំនួនពីគ្រាប់ដើម្បីឲ្យអ្នកបើកបររថយន្តឈប់ តែតៃកុងរថយន្តដែលជាជនជាតិថៃនៅតែមិនព្រមឈប់ ក៏សមត្ថកិច្ចថៃបាញ់មួយគ្រាប់ទៀតត្រូវចំកង់រថយន្តខាងក្រោយផ្នែកខាងស្តាំបណ្តាលឲ្យរថយន្តរ៉េចង្កូត ក្រប់ឡាប់ចំនួន២ត្រលបធ្វើឲ្យអ្នកជិះក្នុងរថយន្តរងរបួសធ្ងន់ស្រាលជាង១០នាក់ និងស្លាប់១នាក់នៅកន្លែងកើតហេតុ ។

ចំណែកពលករប្រុស ស្រីជាង១០នាក់រួមទាំងសពរងគ្រោះត្រូវបានសមត្ថកិច្ចថៃដឹកទៅសង្គ្រោះនៅមន្ទីរពេទ្យចំនួន២ក្នុងខេត្តប្រាជីនបូរីចំណែកសពរងគ្រោះខាងលើបានស្លាប់នៅមន្ទីរពេទ្យបន្ទាប់ពីដឹកទៅសង្គ្រោះ ៕ វណ្ណា

## ទូតខ្មែរអំពាវនាវ ដល់ពលករកម្ពុជា ធ្វើការនៅថៃ ឲ្យមកបញ្ជាក់ អត្តសញ្ញាណ ឲ្យបាន មុនថ្ងៃទី៣០ មិថុនា

https://www.dap-news.com/kh/ សុក្រ, 04 ឧសភា ២០១៨ 13:00 ដោយ: ធី លីថូ ID:112

ភ្នំពេញ ៖ យោងតាមសេចក្តី ជូនដំណឹង របស់គណៈកម្មការ ផ្តល់ភាពស្របច្បាប់ ដល់ពលករ កម្ពុជា បានធ្វើការអំពាវនាវ ដល់ប្រជាពលរដ្ឋកម្ពុជា ដែលកំពុងស្នាក់នៅនិង ធ្វើការនៅប្រទេស ថៃ ដែលពុំទាន់បានមកបញ្ជាក់អត្តសញ្ញាណ (លិខិតឆ្លងដែនPP លិខិតធ្វើដំណើរTD ប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេសOCWC) ឲ្យប្រញាប់រួសរាន់មកធ្វើការ បញ្ជាក់ជាមួយ ក្រុមការងារអន្តរក្រសួង ចល័តរបស់គណៈកម្មការ ផ្តល់ភាពស្របច្បាប់ ដែលមានទីតាំង នៅទីក្រុងបាំងកក ខេត្ត ផាធុមថានី ខេត្តរ៉ាក់យ៉ង ប្រទេសថៃ ឲ្យបានត្រឹមថ្ងៃទី៣០ខែមិថុនា ឆ្នាំ២០១៨។

សូមបញ្ជាក់ថា ប្រជាពលរដ្ឋកម្ពុជា ដែលបានចុះបញ្ជីជាមួយអាជ្ញាធរថៃ តែមិនទាន់បានទទួល ប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណពណ៌ស៊ីជម្ពូ)និងពលរដ្ឋ ដែលបានបញ្ជាក់អត្តសញ្ញាណរួចហើយ សូមប្រញាប់រួសរាន់ទៅបន្តធ្វើប័ណ្ណ មិនមែនសញ្ជាតិថៃ (ប័ណ្ណពណ៌ស៊ីជម្ពូ)ថ្មី និងស្នើសុំទិដ្ឋាការស្នាក់នៅ និងប័ណ្ណអនុញ្ញាតការងារ ពីការិយាល័យច្រកចេញចូលតែមួយដែលមានចំនួន ៨០កន្លែង ក្នុងនោះ៤កន្លែង នៅទីក្រុងបាំងកក និង៧៦ នៅតាមបណ្តាខេត្តទូទាំងប្រទេសថៃ ឲ្យបានត្រឹមថ្ងៃទី៣០ខែមិថុនា ឆ្នាំ២០១៨។

ក្នុងករណីដែលដែលប្រជាពលរដ្ឋ មានចម្ងល់ក្នុងបញ្ហានេះ សូមទំនាក់ទំនងមក្រុមការងារ គណៈកម្មការផ្តល់ភាពស្របច្បាប់ តាមប្រព័ន្ធទូរស័ព្ទ លេខ ០៨២ ៤២២ ០០១១,០៨២ ៤២២និង០៨២ ៤២២ ០០៤៤ ៕

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការផ្ដល់ភាពស្របច្បាប់ដល់ពលករកម្ពុជា**
**ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ**

លេខៈ ៦៦១ គ.ផ.ថ

# សេចក្ដីជូនដំណឹង

គណៈកម្មការផ្ដល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ សូមជម្រាបជូនដំណឹង ដល់បងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ដែលពុំទាន់បានមកបញ្ជាក់អត្តសញ្ញាណ (លិខិតឆ្លងដែន PP/ លិខិតធ្វើដំណើរ TD/ ប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស OCWC) ជាមួយក្រុមការងារអន្តរក្រសួងចល័តរបស់គណៈកម្មការផ្ដល់ភាពស្របច្បាប់ សូមប្រញាប់ប្រញាល់សរាន់មកធ្វើការបញ្ជាក់អត្តសញ្ញាណជាមួយក្រុមការងារដែលមានទីតាំងនៅទីក្រុងបាងកក ខេត្តជាធុមថានី ខេត្តរ៉ាក់យ៉ង និងក្រុមការងារចល័តដែលចុះទៅខេត្តដែលបងប្អូនកំពុងស្នាក់នៅ និងធ្វើការឱ្យបានត្រឹម **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨។**

ជាមួយគ្នានេះ ចំពោះបងប្អូនពលករកម្ពុជាដែលបានចុះបញ្ជីជាមួយអាជ្ញាធរថៃ តែមិនទាន់បានទទួលប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណពណ៌ស៊ីជម្ពូ) និង បងប្អូនពលករដែលបានបញ្ជាក់អត្តសញ្ញាណរួចហើយ សូមប្រញាប់ប្រញាល់សរាន់ទៅបន្តធ្វើប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណពណ៌ស៊ីជម្ពូ) ថ្មី និង ស្នើសុំទិដ្ឋាការស្នាក់នៅ និងប័ណ្ណអនុញ្ញាតការងារ ពីការិយាល័យច្រកចេញចូលតែមួយដែលមាន **ចំនួន៨០កន្លែង ក្នុងនោះ៤កន្លែងនៅទីក្រុងបាងកក និង៧៦ នៅតាមបណ្ដាខេត្តទូទាំងប្រទេសថៃ** ឱ្យបានត្រឹម **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨។**

ក្នុងករណីមានចម្ងល់ពាក់ព័ន្ធបញ្ហានេះ សូមទំនាក់ទំនងមកក្រុមការងារគណៈកម្មការផ្ដល់ភាពស្របច្បាប់ តាមប្រព័ន្ធទូរសព្ទលេខ ០៨២ ៤២២ ០០១១ / ០៨២ ៤២២ ០០២២ និង ០៨២ ៤២២ ០០៤៤។

អាស្រ័យដូចបានជម្រាបជូន សូម សាធារណជន ជាពិសេសបងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ៥ រោច ខែជេស្ឋ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស២៥៦២

បាងកក ថ្ងៃទី ៨ ខែមិថុនា គ.ស ២០១៨

**ជ.ប្រធានគណៈកម្មការ**

**អនុប្រធាន**

**ឈុន ទិសារណា**

## ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៨

## ពលករកម្ពុជាធ្វើការនៅថៃ ត្រូវបញ្ជាក់អត្តសញ្ញាណ ឲ្យបានមុនថ្ងៃទី៣០ ខែមិថុនា

https://thmeythmey.com/ 06, May 2018 , 3:40 pm ដោយ: ថ្មីៗ

ភ្នំពេញ៖ គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា បានប្រាប់ពលករខ្មែរ ដែលកំពុងធ្វើការនៅប្រទេសថៃ ដោយពុំទាន់មានលិខិតត្រឹមត្រូវ ត្រូវប្រញាប់មកបំពេញអត្តសញ្ញាណ ឲ្យបានមុនថ្ងៃ៣០ ខែមិថុនា ឆ្នាំ ២០១៨ ។ សេចក្តីជូនដំណឹងរបស់គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា បានបញ្ជាក់ថា ពលករកម្ពុជា ដែលស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ដែលពុំទាន់បានបញ្ជាក់អត្តសញ្ញាណ(លិខិតឆ្លងដែន PP, លិខិតធ្វើដំណើរ TD និងប័ណ្ណពលករធ្វើការនៅបរទេសOCWC) ត្រូវប្រញាប់មកបញ្ជាក់ ជាមួយក្រុមការងារអន្តរក្រសួងរបស់គណៈកម្មការផ្តល់ភាពស្របច្បាប់ នៅទីក្រុងបាងកក, ខេត្តផាថុមថានី និងខេត្តរ៉ាក់យ៉ង ។

ចំពោះពលករ ដែលបានចុះបញ្ជីជាមួយអាជ្ញាថៃ តែមិនទាន់បានទទួលប័ណ្ណមិនមែនសញ្ជាតិថៃ និងពលករបញ្ជាក់អត្តសញ្ញាណរួចហើយ ត្រូវបន្តធ្វើប័ណ្ណមិនមែនសញ្ជាតិថៃថ្មី ឬស្នើសុំទិដ្ឋាការស្នាក់នៅ និងប័ណ្ណអនុញ្ញាតការងារ ពីការិយាល័យច្រកចេញ-ចូលតែមួយ ដែលមានចំនួន៨០កន្លែង ដោយក្នុងនោះមានចំនួន៤កន្លែង នៅទីក្រុងបាងកក ៕

## លោក ពៅ រិទ្ធី មេបញ្ជាការរងវរៈការពារព្រំដែន គោក៨៩១ ប្រើប្រាស់ដីកម្មសិទ្ធិផ្ទាល់ខ្លួនបើកច្រករបៀងខុសច្បាប់?

http://mekong-post.com/ ដោយ មេគង្គ ប៉ុស្តិ៍ ចេញផ្សាយ ថ្ងៃទី 6 May, 2018

ប៉ោយប៉ែត ៖ សេចក្តីរាយការពីបន្ទាត់ព្រំដែនថា ទីតាំងដីមួយកន្លែងនៅជាប់មាត់អូរព្រំដែនកម្ពុជា-ថៃ ដែលគេស្គាល់ថា ជាកម្មសិទ្ធិរបស់លោក ពៅ រិទ្ធី ហៅ ធីខ្នា ជាមេបញ្ជាការរងវរៈការពារព្រំដែន៨៩១ ស្ថិតក្នុងភូមិគីឡូម៉ែត្រលេខ៤ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត បានបើកធ្វជាច្រករបៀងឲ្យពលរដ្ឋចេញចូល និងនាំទំនិញគ្រប់ប្រភេទឆ្លងចូលមកទឹកដីកម្ពុជា ដែលជាធម្មតា ក្នុងមួយសប្តាហ៍បើកឲ្យឆ្លងចេញចូល១ថ្ងៃ ។

គួររំឭកថា សម្តេចក្រឡាហោម ស ខេង ធ្លាប់បានដាក់បទបញ្ជាយ៉ាងម៉ឺងមាត់ឲ្យអាជ្ញាធរ និងកម្លាំងតាមព្រំដែនទាំងអស់ត្រូវត្រួតពិនិត្យ និងបិទឲ្យអស់ទាំងស្រុងរាល់ច្រករបៀងខុសច្បាប់នៅតាមខ្សែបន្ទាត់ព្រំដែន ដើម្បីទប់ស្កាត់រាល់បទល្មើសឆ្លងគ្រប់ប្រភេទ ប៉ុន្តែរហូតមកដល់ពេលនេះច្រករបៀងមួយចំនួននៅតែបន្តបើកយ៉ាងងងើល ឧទាហរណ៍ដូចជាច្រករបៀងដែលស្ថិតក្នុងទីតាំងដីកម្មសិទ្ធិរបស់លោក ពៅ រិទ្ធី ហៅ ធី ខ្នា នេះជាដើម។ សកម្មភាព លួចបើកច្រករបៀងក្រោមអំណាច លោកពៅ រិទ្ធី ហៅ ធីខ្នា គឺប្រឆាំងទៅនឹងបទបញ្ជាសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ ក្នុងរូបភាពនេះ ជាភស្តុតាងនៃសកម្មភាពពលករឆ្លងដែន និងក្រុមឈ្មួញ នាំទំនិញ ចូលមក ស្រុកខ្មែរ តាមច្រករបៀងនៅចំណុចភូមិគីឡូម៉ែត្រលេខ៤ ដែលគេស្គាល់ថា ជាដីកម្មសិទ្ធរបស់លោកពៅ រិទ្ធី ។

មានអ្នកលួចខ្សឹបប្រាប់ថា ទំនិញនាំចូលមួយផ្នែកធំ ដែលលួចឆ្លងចូលពីទឹកដីថៃ មកកម្ពុជាតាមច្ររបៀងខាងលើ គឺលោក ពៅ រិទ្ធី ផ្ទាល់តែម្តង ដែលជាអ្នករួមចំណែកយ៉ាងធំបង្កឲ្យរដ្ឋបាត់បង់ចំណូលពន្ធ ដូចទៅនឹង ប្រសាសន៍នៃនាំរបស់សម្តេចក្រឡាហោម ស ខេង ចេញបទបញ្ជាឲ្យបិទច្រករបៀងទាំងអស់ ដើម្បីធានាដល់ការទប់ស្កាត់ការបាត់បង់ប្រាក់ពន្ធចូលរដ្ឋ។ ទាក់ទិននឹងព័ត៌មានខាងលើនេះ ភ្នាក់ងារព័ត៌មាន មេគង្គប៉ុស្តិ៍ បានព្យាយាមទំនាក់ទំនងតាមទូរស័ព្ទ ដើម្បីសុំការពន្យល់ពីលោក ធីខ្នា ដែរ តែអ្នកទទួលទូរស័ព្ទចេះតែឆ្លើយបដិសេធថា ខុសឈ្មោះហើយ រួចក៏បិទទូរស័ព្ទ៕

## ថៃឃាត់ខ្លួនពលករខ្មែរ១៣នាក់ដែលលបឆ្លងដែនគ្មានច្បាប់អនុញ្ញា

http://cambodiapolice.com/ 3:07 pm 6 ឧសភា 2018

ប្រទេសថៃ ៖ មេខ្យល់ និងពលករខ្មែរសរុបចំនួន១៣នាក់ ត្រូវបានក្រុមតម្រួតថៃដេញតាមប្រមាញ់រហូតឈានដល់ការឃាត់ខ្លួន នៅក្នុងស្រុកអារញ្ញប្រាថេត បន្ទាប់ពីពលករទាំងនេះត្រូវបានមេខ្យល់រៀបចំគម្រោងអោយដេកសំងំនៅលើរថយន្ត ដោយគ្របបិទបាំងយ៉ាងជិតដើម្បីបញ្ជូនទៅធ្វើការនៅក្នុងទីក្រុងបាងកក ប្រទេសថៃ ។ កិច្ចប្រតិបត្តិការរបស់ក្រុមតម្រួតថៃនេះ បានធ្វើឡើងនៅវេលាម៉ោង១០ព្រឹក ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៨ តាមបណ្តោយផ្លូវពីព្រំដែនកម្ពុជា ទៅកាន់ទីក្រុងបាងកក ត្រង់ចំណុចមុខស្ថានីយ៍ហ្គាស LPG ស្ថិតក្នុងឃុំ ណងសាំង ស្រុកអារញ្ញប្រាថេត ខេត្តស្រះកែវ ប្រទេសថៃ ។

នៅក្នុងកិច្ចប្រតិបត្តិការនោះដែរ គេសង្កេតឃើញថា មានការឃាត់រថយន្តមួយគ្រឿងម៉ាកតូយ៉ូតា វីហ្គូ ពណ៌ប្រផេះ ពាក់ស្លាកលេខ បាងកក ៥៣០០ ខណៈដែលរថយន្តនេះមានដឹកអ្វីម្យ៉ាងដោយមានគ្របស្បៃ និងតង់យ៉ាងជិតផង ដោយអ្នកបើកបរមានឈ្មោះ អាំងផន សានណារៀង ភេទប្រុស អាយុ៣៨ឆ្នាំ ជាជនជាតិថៃ រស់នៅភូមិ៣ ឃុំបាងណាំខៀវ ស្រុកព្រុំបុរី ខេត្តសិង្ហបុរី ។ នៅក្នុងរថយន្តនោះដែរ ក្រោយពេលបើកតង់ឡើង គេឃើញមានពលករខ្មែរដេកតម្រៀបគ្នា រដូករណែលដែលសរុបមានចំនួន១២នាក់ រួមជាមួយនិងមេខ្យល់ម្នាក់ដែលជាជនជាតិខ្មែរដែរដែលគេនោះមានឈ្មោះ លូន ភេទប្រុស អាយុ៤៥ឆ្នាំ ដោយពួកគេទាំងពីរនាក់មានការឃុបឃិត និងត្រូវរ៉ូវគ្នាក្នុងការដឹកជញ្ជូនពលករខុសច្បាប់អោយចូលទៅបម្រើការងារនៅក្នុងប្រទេសថៃ ។

សមត្ថកិច្ចថៃបានអះអាងថា ជនទាំងពីរនាក់នេះគឺមានទោសទៅតាមកំហុសរៀងៗខ្លួនដោយអ្នកបើកបរខុសលើការជួយបិទបាំង និងដឹកជញ្ជូនពលករអោយគេចផុតពីការត្រួតពិនិត្យ និងចាប់ខ្លួន រីឯមេខ្យល់ គឺជាជនជាតិខ្មែរដែលហ៊ាននាំពលករជាច្រើននាក់អោយលបឆ្លងដែនចូលទៅក្នុងប្រទេសថៃ ដោយគ្មានច្បាប់អនុញ្ញាត ដូច្នេះពួកគេត្រូវបានកំលាំងបញ្ជូនទៅកាន់តុលាការដើម្បីសម្រេច ៕

## ទាហានថៃនឹងតម្រួតថៃចាប់បានបងប្អូនពលករខ្មែរនៅក្នុងទឹកដីថៃ ច្រករបៀង ចំនួន 54 នាក់ ដែលចូលប្រទេសថៃខុសច្បាប់

https://www.facebook.com/search/ ទឹកចិត្ត ពលករ ឆ្លងដែន ថ្ងៃទី ៥ ខែឧសភា ឆ្នាំ២០១៨

ក្រោយពីទាហានថៃនិងតម្រួតថៃ បានបើកអង្គប្រជុំកាលពីម្សិលមិញប្រជុំស្តីពីពាក់ព័ន្ធនឹងពលករឆ្លងដែនខុសច្បាប់ អោយមានការត្រួតពិនិត្យយ៉ាងរឹងតឹងនៅតាមច្រកព្រំដែនថៃ ក្នុងថ្ងៃនេះដែរទាហានថៃនឹងតម្រួតថៃ ចាប់បានបងប្អូនពលករខ្មែរដែលចូលទៅតាមច្រកព្រំដែនកម្ពុជា ថៃ នៅតាមច្រកសំពៅលូន ខេត្តបាត់ដំបង ទាហានថៃនិងតម្រួតថៃចាប់បានបងប្អូនពលករខ្មែរនៅក្នុងទឹកដីថៃ ច្រករបៀង ចំនួន 54 នាក់ ដែលចូលប្រទេសថៃខុសច្បាប់ ។

សូមបងប្អូនពលករខ្មែរប្រុងប្រយ័ត្នផង ថៃបានត្រួតត្រាយ៉ាងរឹងតឹងណាស់នៅតាមច្រកព្រំដែន ជាពិសេសបងប្អូនពលករខ្មែរដែលចូលប្រទេសថៃខុសច្បាប់ ។ (អំពីខ្ញុំ ទឹកចិត្ត ពលករ ឆ្លងដែន) ជួយ ស៊ែ បន្ត ផង 5-5-2018

## រាជរដ្ឋាភិបាលថៃ សម្រេច ចេញច្បាប់ដាក់ទណ្ឌកម្មថៅកែ ដែលរឹបអូសឯកសារពលករ

http://www.pheaktraprak.com May 6, 2018

យោងតាមមតិគណៈរដ្ឋមន្ត្រីថៃ បន្ទាប់ពីបើកកិច្ចប្រជុំគណៈរដ្ឋមន្ត្រីកំពូលកាលពីពេលថ្មីៗកន្លងទៅនេះ រាជរដ្ឋាភិបាលថៃបានសម្រេចលើកខ្ពស់ច្បាប់បញ្ហាជួញដូរមនុស្សនៅក្នុងប្រទេសថៃ និងបញ្ហាធ្វើពលកម្មដោយការបង្ខិតបង្ខំ ដោយច្បាប់នេះបានធ្វើឡើងដើម្បីដាក់ទណ្ឌកម្មទៅលើនិយោជក ដែលរឹបអូសលិខិតឆ្លងដែន និងឯកសារសម្គាល់ខ្លួនរបស់ពលករ ដើម្បីជាថ្នូរក្នុងធ្វើការដោយបង្ខិតបង្ខំអោយពលករនៅធ្វើការជាមួយខ្លួន។

# គណៈកម្មការផ្ដល់ភាពស្របច្បាប់ដល់ពលករកម្ពុជានៅប្រទេសថៃ

https://www.facebook.com គណៈកម្មការផ្ដល់ភាពស្របច្បាប់ដល់ពលករកម្ពុជានៅប្រទេសថៃ May 7, 2018

សេចក្ដីជូនដំណឹង នាឱកាសបុណ្យចម្រើនព្រះជន្ម ព្រះករុណា ព្រះបាទសម្ដេចបរមនាថ នរោត្ដម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្រុមការងារបើកផ្ដល់លិខិតឆ្លងដែន (PP) លិខិតធ្វើដំណើរ (TD) និងប័ណ្ណពលករទៅធ្វើការនៅបរទេស (OCWC) ទាំងអស់នឹងឈប់សម្រាកចំនួន ០២ថ្ងៃគឺចាប់ពីថ្ងៃច័ន្ទ ១៥រោច ខែពិសាខ ដល់ថ្ងៃអង្គារ ១កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី១៤-១៥ ខែឧសភា គ.ស២០១៨។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការផ្ដល់ភាពស្របច្បាប់ដល់ពលករកម្ពុជា**
**ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ**
លេខ:.....៦៦២......................គ.ផ.ថ

## សេចក្ដីជូនដំណឹង

គណៈកម្មការផ្ដល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ សូមជម្រាបជូនដំណឹងដល់សាធារណជន ជាពិសេសបងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ឱ្យបានជ្រាបថា **នាឱកាសបុណ្យចម្រើនព្រះជន្ម ព្រះករុណា ព្រះបាទសម្ដេចបរមនាថ នរោត្ដម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ក្រុមការងារបើកផ្ដល់លិខិតឆ្លងដែន(PP) លិខិតធ្វើដំណើរ(TD) និងប័ណ្ណពលករទៅធ្វើការនៅបរទេស(OCWC) នៅលេខាធិការដ្ឋានអចិន្ត្រៃយ៍ប្រចាំស្ថានទូតកម្ពុជានៅទីក្រុងបាងកក ក្រុមការងារអន្តរក្រសួងចល័តនៅទីក្រុងបាងកក ខេត្តរ៉ាក់យ៉ង ខេត្តប៉ាធុមថានី និងក្រុមការងារប្រមូលទិន្នន័យចល័ត នឹងឈប់សម្រាកចំនួន **០២ថ្ងៃ**គឺចាប់ពីថ្ងៃច័ន្ទ ១៥រោច ខែពិសាខ ដល់ថ្ងៃអង្គារ ១កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ **ត្រូវនឹងថ្ងៃទី១៤ -១៥ ខែឧសភា គ.ស២០១៨** ។

ករណីបងប្អូនពលករមានចង្ងល់ពាក់ពន្ធ័ នឹងបញ្ហានេះ សូមបងប្អូនពលករទាក់ទងមកលេខទូរស័ព្ទ ០៨២ ៤២ ២០ ០១១,០៨២ ៤២ ២០ ០២២ និង០៨២ ៤២ ២០ ០៤៤ ។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូមសាធារណជន ជាពិសេសបងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ជ្រាបជាព័ត៌មាន។

ថ្ងៃ សុក្រ ៥កេីត ខែពិសាខ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស២៥៦២
បាងកក ថ្ងៃទី ៤ ខែឧសភា គ.ស ២០១៨
**ជ.ប្រធានគណៈកម្មការ**
**អនុប្រធាន**

**ឡុង ទិមសារឿន**

# ថៃចេញច្បាប់ថ្មី អនុញ្ញាតឲ្យប្រើពលករបរទេសតែ ២០% ប៉ុណ្ណោះ

http://kleykley.sabay.com.kh/ May 7, 2018

ច្បាប់ថ្មីមួយ ដែលទើបត្រូវបានអនុម័តដោយសភាថៃ កាលពីខែមេសា ២០១៨ កន្លងទៅ បានកំណត់ថា ក្រុមហ៊ុន និងសហគ្រាសនៅក្នុងប្រទេសថៃ ត្រូវអនុញ្ញាតឲ្យប្រើពលករបរទេសត្រឹមតែ ២០%ប៉ុណ្ណោះ។ ច្បាប់នេះ នឹងចាប់អនុវត្តចាប់ពីថ្ងៃទី១ ខែកក្កដា ២០១៨ ខាងមុខនេះ។ ការអនុវត្តច្បាប់ថ្មីនេះ គឺក្នុងគោលបំណងការពារការងាររបស់កម្មករជនជាតិថៃ ពីសំណាក់កម្មករបរទេសដែលចូលទៅធ្វើការក្នុងប្រទេសថៃរាប់លាននាក់។ ច្បាប់ស្តីពីការគ្រប់គ្រងពលករអន្តោប្រវេសន៍នេះ នឹងអនុវត្តលើគ្រប់ពលករបរទេសទាំងអស់ មិនថាពលករនោះ ត្រូវបានជួលក្រោមការចុះអនុស្សរណៈទ្វេភាគីជាមួយរដ្ឋាភិបាលថៃ ឬអត់នោះទេ។ ច្បាប់នេះបានកំណត់ចំនួននិយោជិកបរទេស នៅតាមវិស័យសេវាកម្ម និងឧស្សាហកម្ម ត្រឹមតែ ២០% ប៉ុណ្ណោះ៕ ប្រភព៖ Bangkokpost ប្រែសម្រួល៖ វាសនា

## អាជ្ញាធរថៃបង្ក្រាប បង្ក្រាបទូកនេសាទវៀតណាម ៥គ្រឿង និងពលករខុសច្បាប់ចំនួន ៣០នាក់

http://www.pheaktraprak.com May 6, 2018

កម្លាំងអាជ្ញាធរថៃការពារដែនសមុទ្រនៃភូមិភាគខាងត្បូងប្រទេសថៃ ធ្វើការបង្ក្រាបទូកនេសាទត្រីខុសច្បាប់សញ្ជាតិវៀតណាមចំនួន០៥គ្រឿង និងធ្វើការឃាត់ខ្លួនពលករធ្វើការនៅលើទូកចំនួន៣០នាក់ យកទៅចាត់វិធានការតាមផ្លូវច្បាប់ ករណីនេះបង្ក្រាបនេះបានធ្វើឡើងកាលពីថ្ងៃសៅរ៍ទី០៥ ខែឧសភា ឆ្នាំ២០១៨ ម្សិលមិញនេះ នៅក្នុងតំបន់សមុទ្រខាងត្បូងស្ថិតនៅខេត្តសង់ក្លាប្រទេសថៃ។

## ស្ថានតំណាងកម្ពុជា អន្តរាគមជួយពលរដ្ឋខ្មែរ២១នាក់

http://www.rasmeinews.com/ May 7, 2018, 11:35 AM

**ដោយ : មុន្នីរ័ត្ន / ភ្នំពេញ ៖** លោកជុំ សុន្ទរី អ្នកនាំពាក្យក្រសួងការបរទេស បានឲ្យដឹងថា ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច របស់ម៉ាឡេស៊ី ដោះស្រាយបញ្ហានិងរៀបចំមាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរចំនួន១៥នាក់ (នារី១៤នាក់) មកពីខេត្តកណ្តាល កំពត ក្រចេះ កំពង់ធំ កំពង់ចាម ត្បូងឃ្មុំ និងពោធិ៍សាត់ ដែលបានទៅធ្វើការដោយខុសច្បាប់នៅប្រទេសម៉ាឡេស៊ី។ ពលករ-ពលការិនីទាំង១៥នាក់នោះ បានមកដល់កម្ពុជាវិញ ជាបន្តបន្ទាប់ ចន្លោះពីថ្ងៃទី១៤ ដល់ថ្ងៃទី២៩ ខែ មេសា ឆ្នាំ២០១៨ ។

លោកបន្តថា ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងហូជីមិញ ប្រទេសវៀតណាម បានរៀបចំមាតុភូមិនិវត្តន៍របស់ស្ត្រីខ្មែរចំនួន៦នាក់ ដែលត្រូវបានមេខ្យល់បោកបញ្ឆោតបម្រុងយកទៅរៀបការជាមួយបុរសជនជាតិ នៅប្រទេសចិន។ ស្ត្រីរងគ្រោះទាំងនោះ មកពីខេត្តកណ្តាល កំពង់ចាម កោះកុង និងក្រចេះ ត្រូវបានមេខ្យល់នាំធ្វើដំណើរពីភ្នំពេញនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៨ ហើយបានទៅដល់អាកាសយានដ្ឋាន អន្តរជាតិ តាន់សឺនញឹត ទីក្រុងហូជីមិញ នៅយប់ថ្ងៃទី២៦ ខែមេសា បម្រុងបន្តដំណើរទៅប្រទេសចិន តែត្រូវបានអាជ្ញាធរមានសមត្ថកិច្ចខេត្តតៃនិញ ប្រទេសវៀតណាម ជួយសង្គ្រោះទាន់ពេល។

ស្ថានអគ្គកុងស៊ុល បានផ្តល់កន្លែងស្នាក់នៅនិងអាហារបរិភោគ ហើយជូនស្ត្រីខ្មែរទាំង៦នាក់ ត្រឡប់មកកម្ពុជាវិញនៅថ្ងៃទី០៣ខែ ឧសភា ឆ្នាំ២០១៨ តាមច្រកទ្វារព្រំដែនអន្តរជាតិបាវិត និងបាន ប្រគល់ជូនអាជ្ញាធរកម្ពុជាចាត់ចែងបន្ត ៕B

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

# ស្ថានតំណាងកម្ពុជា អន្តរាគមជួយពលរដ្ឋខ្មែរ២១នាក់

-----------

១. ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ម៉ាឡេស៊ី** បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ម៉ាឡេស៊ី ដោះស្រាយបញ្ហានិងរៀបចំមាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរចំនួន**១៥នាក់** (នារី ១៤នាក់) មកពីខេត្តកណ្ដាល កំពត ក្រចេះ កំពង់ធំ កំពង់ចាម ត្បូងឃ្មុំ និងពោធិ៍សាត់ ដែលបានទៅធ្វើការដោយខុសច្បាប់នៅប្រទេសម៉ាឡេស៊ី។ ពលករ-ពលការិនីទាំង១៥នាក់នោះ បានមកដល់កម្ពុជាវិញជាបន្តបន្ទាប់ ចន្លោះពីថ្ងៃទី**១៤** ដល់ថ្ងៃទី**២៩** ខែ **មេសា ឆ្នាំ២០១៨** ។

២. ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុង**ហូជីមិញ** ប្រទេសវៀតណាម បានរៀបចំមាតុភូមិនិវត្តន៍របស់ស្ត្រីខ្មែរចំនួន**៦នាក់** ដែលត្រូវបានមេខ្យល់បោកបញ្ឆោតបម្រុងយកទៅរៀបការជាមួយបុរសជនជាតិនៅប្រទេសចិន។ ស្ត្រីរងគ្រោះទាំងនោះ មកពីខេត្តកណ្ដាល កំពង់ចាម កោះកុង និងក្រចេះ ត្រូវបានមេខ្យល់នាំធ្វើដំណើរពីភ្នំពេញនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៨ ហើយបានទៅដល់អាកាសយានដ្ឋានអន្តរជាតិ តាន់សឺនញឹត ទីក្រុងហូជីមិញ នៅយប់ថ្ងៃទី២៦ ខែមេសា បម្រុងបន្តដំណើរទៅប្រទេសចិន តែត្រូវបានអាជ្ញាធរមានសមត្ថកិច្ចខេត្តតៃនិញ ប្រទេសវៀតណាម ជួយសង្គ្រោះទាន់ពេល។

ស្ថានអគ្គកុងស៊ុល បានផ្ដល់កន្លែងស្នាក់នៅនិងអាហារបរិភោគ ហើយជូនស្ត្រីខ្មែរទាំង**៦នាក់** ត្រឡប់មកកម្ពុជាវិញ នៅថ្ងៃទី**០៣** ខែ **ឧសភា ឆ្នាំ២០១៨** តាមច្រកទ្វារព្រំដែនអន្តរជាតិ**បាវិត** និងបានប្រគល់ជូនអាជ្ញាធរកម្ពុជាចាត់ចែងបន្ត។

ថ្ងៃចន្ទ ៨រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ភ្នំពេញ, ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៨
**ជុំ សុន្ទរី**
**អ្នកនាំពាក្យ**
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨
## ម៉ាឡេស៊ី ចាប់នាវារត់ពន្ធមនុស្សទៅអូស្ត្រាលី និង នូវែលសេឡង់

https://www.postkhmer.com/ AFP | Publication date 07 May 2018 | 11:50 ICT

**ក្រុងគូឡាឡាំពួ:** ក្រុមអាជ្ញាធរ បាននិយាយកាលពីថ្ងៃសៅរ៍ថា ម៉ាឡេស៊ី បានចាប់ខ្លួនសមាជិកជាង ១០ នាក់ របស់ក្រុមជួញដូរមនុស្សតាមដែលគេចោទប្រកាន់ ក្រោយពីចាប់ទូកបាន ១ គ្រឿង ដែលដឹកជនចំណាកស្រុកស្រីលង្កា ១២៧ នាក់ ដែលត្រូវបានគេជឿថា មានទិសដៅអូស្ត្រាលី និងនូវែលសេឡង់។

នៅក្នុងសេចក្ដីថ្លែងការណ៍មួយកាលពីថ្ងៃសៅរ៍ប្រមុខប៉ូលិសជាតិលោក Mohamad Fuzi Harun បានថ្លែងថា កាលពីថ្ងៃអង្គារ ក្រុមអាជ្ញាធរដែនសមុទ្រ បានចាប់នាវាមួយគ្រឿងឈ្មោះ Etra នៅក្នុង ដែនទឹករបស់ម៉ាឡេស៊ីនៃរដ្ឋជូហរភាគខាងត្បូង។ បុរសស្រីលង្កាជិត ១០០ នាក់ ស្ត្រី ២៤ នាក់ និងកុមារ ៩ នាក់ជិះនៅលើនាវានោះដែលបានធ្វើដំណើរចូលទៅដែនទឹកអន្តរជាតិ នៅពេល នាវានោះ ត្រូវបានគេឃាត់ឲ្យឈប់។ លោក Mohamad បានថ្លែងថា ក្រុមអាជ្ញាធរ បានចាប់ខ្លួនមនុស្ស ១៦ នាក់ពាក់ព័ន្ធបណ្ដាញអ្នករត់ពន្ធមនុស្សអន្តរជាតិនៅក្នុងនោះមានឥណ្ឌូនេស៊ី ៣ នាក់ និងម៉ាឡេស៊ី ៤ នាក់ ជិះនៅទូកនាវានេសាទ ១ គ្រឿងដែលត្រូវបានប្រើដើម្បីដឹកជញ្ជូនក្រុមជនចំណាកស្រុកពីឆ្នេរសមុទ្រជូហរ ទៅកាន់នាវានោះ។

ម៉ាឡេស៊ី ៤ នាក់ផ្សេងទៀតត្រូវបានចាប់ខ្លួននៅក្នុងរដ្ឋធានី Johor Bahru នៅក្បែរនោះខណៈមនុស្សទី ៥ ម្នាក់ត្រូវយកទៅឃុំខ្លួននៅរដ្ឋ Penag។ បុរសស្រីលង្កា ៤ នាក់នៅលើនាវានោះពីបទពាក់ព័ន្ធជាមួយ នឹងបណ្ដាញជួញដូរមនុស្សដែលលោក Mohamad បាននិយាយថា បានធ្វើកិច្ចប្រតិបត្តិការរបស់ពួកគេ ចាប់តាំងពីឆ្នាំ ២០១៧ មក៕

## ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨
## នាយករដ្ឋមន្ត្រី ដាក់ចេញអនុសាសន៍៩ចំណុច ដល់ក្រសួងពាក់ព័ន្ធ អនុវត្តឲ្យមានប្រសិទ្ធភាព ចំពោះកម្មករ

https://www.dap-news.com/kh/ ថ្ងៃពុធ, 09 ឧសភា ២០១៨ 11:00 ដោយ: ដើមអម្ពិល ID:112

ភ្នំពេញ៖ បន្ទាប់ពីបានផ្ដល់ អត្ថប្រយោជន៍ជាច្រើន ដល់កម្មករកម្មការិនី សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃកម្ពុជានៅថ្ងៃទី៩ ខែឧសភានេះ បានដាក់ចេញនូវអនុសាសន៍៩ចំណុច ដល់ក្រសួងពាក់ព័ន្ធ អនុវត្តឲ្យមានប្រសិទ្ធភាព ចំពោះកម្មករ។ អនុសាសន៍៩ចំណុចសំខាន់ៗ របស់សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នោះរួមមាន៖

១)ត្រូវអនុវត្តប្រាក់ខែអប្បបរិមា ១៧០ ដុល្លារ ចាប់ពីថ្ងៃ១ ខែមករា ឆ្នាំ២០១៨ តទៅ។

២)ត្រូវអនុវត្តការចុះពិនិត្យនៅតាមមន្ទីរពេទ្យរដ្ឋ ចំពោះការពិនិត្យសុខភាព និងការព្យាបាល កម្មករកម្មការិនីរោងចក្រ រួមទាំងកីឡាករ កីឡាការិនី ក្រុមប្រឹក្សាភូមិឃុំ ក៏ត្រូវបានអនុវត្តដូចគ្នា ជាពិសេសរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងក្រសួងការងារត្រូវធ្វើអោយបានហ្មត់ចត់។

៣)ត្រូវអនុវត្តចំពោះស្ត្រីមានផ្ទៃពោះសំរាលកូនគឺនឹងទទួលបានពេលវេលាឈប់សម្រាក ពីការងាររយៈ ពេល៣ខែ ហើយទទួលបានប្រាក់ខែ ១២០% (៥០% ដោយក្រុមហ៊ុន និង ៧០%ដោយបេឡាជាតិ) ក្រសួងពាក់ព័ន្ធត្រូវតាមដានការងារ ឲ្យបានជិតដល់ចំពោះការ អនុវត្តសកម្មភាពនេះ។

៤.ត្រូវអនុវត្តចំពោះកម្មការិនីសម្រាលបានកូន(១)គឺទទួលថវិកា៤០ម៉ឺនរៀល និងពិនិត្យផ្ទៃពោះ ដោយឥតគិតថ្លៃ។ បើសម្រាលបានកូនភ្លោះ (២) គឺទទួលបានថវិកា៨០ម៉ឺនរៀល។ បើសម្រាលបានកូន(៣)គឺទទួលបានថវិកា១លាន២សែនរៀលហើយបូកប្រាក់ឧបត្ថម្ភចំនួន៥លានរៀលទៀតពីសម្ដេចតេជោ និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត។

៥)ត្រូវអនុវត្តចំពោះរបប សន្តិសុខសង្គម ដោយចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ តទៅ កម្មករកម្មករនីមិនចាំបាច់បង់ទៀតទេ គឺម្ចាស់ក្រុមហ៊ុនជាអ្នកបង់ជំនួស ១០០%។

៦)អនុវត្តតាមដានមើលបញ្ហា ទឹក ភ្លើង គឺត្រូវខិតខំបន្ត តទឹកតភ្លើងដល់ផ្ទះ របស់កម្មករយើង ដែលនៅឆ្ងាយ ដែលមិនទាន់ទៅដល់ឲ្យបានគ្រប់គ្រាន់ និងតំលៃផ្ទះជួលដល់កម្មករកម្មការនីកុំ អោយមានការឡើងថ្លៃក្នុងឆ្នាំ២០១៨ ពីព្រោះកន្លងមកយើងមានកំណត់រួចរាល់ហើយ។

៧)អនុវត្តប្រាក់សោធននិវត្តន៍ ចាប់ពីឆ្នាំ ២០១៩ ទៅក្នុយកម្មករ និងទទួលបានប្រាក់ចូលនិវត្តន៍ (ប្រាក់រីត្រែត)ដូចច្នេះក្នុងរយៈពេល១ឆ្នាំ(២០១៨)ត្រូវត្រៀមរៀបចំអោយហើយដើម្បីឲ្យដំណើរការបានល្អនៅក្នុងឆ្នាំ២០១៩នូវរបបសោធននិវត្តន៍នេះ។

៨)អនុវត្តចូលរួមបន្តយកចិត្តទុកដាក់ និងដោះស្រាយបញ្ហាផ្សេងៗ ដែលបងប្អូនពលករ ទៅក្រៅប្រទេសជួយសម្រួល នូវបែបបទលិខិតបទដ្ឋានផ្លូវច្បាប់នានា និងដើម្បីទទួលបាននូវ ល័ក្ខខ័ណ្ឌការងារ ល្អប្រសើរ។

៩)ក្រសួងការងារត្រូវចុះអនុវត្តតាមដានភ្លាមៗឲ្យបានជិតដល់ និងចូលរួមដោះស្រាយបញ្ហា ប្រឈមនានាចំពោះកម្មករ នៅពេលដែលម្ចាស់រោងចក្ររត់ចោល។ ក្នុងនោះគឺត្រូវដោះស្រាយផ្តល់ ប្រាក់ឈ្នួលជាបន្ទាន់ដល់កម្មករកម្មការិនីដែលបានធ្វើការ ក្នុងពេលដែលថៅកែរោងចក្របានរត់ចោលហើយត្រូវបន្តដោះស្រាយបញ្ហានានាជាមួយម្ចាស់រោងចក្រដោយផ្ទាល់។ទន្ទឹមនឹងនោះដែរគឺត្រូវជួយរកការងារធ្វើដល់កម្មករកម្មការនីអោយបានឆាប់បំផុត។

ទន្ទឹមនឹងនេះដែរ សម្តេចតេជោ ហ៊ុន សែន អំពាវនាវឲ្យកម្មករកម្មការិនី ក៏ដូចជាប្រជាពលរដ្ឋ ទាំងអស់ត្រូវរួមគ្នាថែរក្សា "សន្តិភាព" ឲ្យបានគង់វង្សដើម្បីបន្តការអភិវឌ្ឍ ប្រទេសជាតិ ឲ្យមានការរីកចម្រើនតទៅមុខទៀត។ សម្តេចតេជោសុំកុំឲ្យបណ្តាលរោងចក្រទាំងអស់មាន នូវបងតូចបងធំ(ជើងកាង) ដែលមក បំបាសបំបោលកម្មករ។ សូមកម្មករកម្មការិនីត្រូវរួមគ្នា រក្សាការងាររបស់ខ្លួន ត្រូវគោរពគ្នាទៅ វិញទៅមករវាងម្ចាស់រោងចក្រ និងកម្មករ៕

## មន្រ្តីជាន់ខ្ពស់ក្រសួងមហាផ្ទៃ ៖ ស្ត្រីខ្មែររងគ្រោះភាគច្រើននៅប្រទេសចិន គឺដោយសារ អាពាហ៍ពិពាហ៍ប្រថុយប្រថាន

http://cambodiapolice.com/ 12:54 pm 10 ឧសភា 2018 36

**ភ្នំពេញ ៖** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ លោកជំទាវ ជូ ប៊ុនអេង បានអះអាងថា ស្ត្រីខ្មែរដែលត្រូវបានគេជួញដូរ និងរងគ្រោះច្រើនជាងគេនៅប្រទេសចិនកាលពីកន្លងទៅនោះ គឺភាគច្រើនដោយសារការរៀបអាពាហ៍ពិពាហ៍ប្រថុយប្រថាន និងផ្ទុយពីឆន្ទៈ ខណៈក្រុមស្ត្រីរងគ្រោះទាំងនោះត្រូវបានអាជ្ញាធរកម្ពុជា និងចិនជួយសង្គ្រោះឲ្យមកប្រទេសកម្ពុជាវិញ ប្រមាណជិត៦០នាក់ កាលពីឆ្នាំ២០១៧កន្លងទៅនេះ ។ ថ្លែងប្រាប់អ្នកយកព័ត៌មាននៅព្រឹកថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨នេះ នៅសណ្ឋាគារភ្នំពេញមុននឹងបើកកិច្ចប្រជុំប្រចាំឆ្នាំលើកទី២ រវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពីភាពរីកចំរើននៃការអនុវត្តកិច្ចព្រមព្រៀងសហប្រតិបត្តិការក្នុងការបង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងផែនការសកម្មភាព ។ លោកជំទាវ ជូ ប៊ុនអេង បានលើកឡើងថា ស្ត្រីខ្មែរយើងច្រើនណាស់ដែលបានរងគ្រោះ និងជួញដូរដោយខុសច្បាប់នៅប្រទេសចិន ។ ដូច្នេះកិច្ចប្រជុំនេះ គឺភាគីកម្ពុជា និងចិន ស្វែងរកផែនការសម្រាប់ជួយសង្គ្រោះពួកគេ និងទប់ស្កាត់ទង្វើនេះមិនឲ្យមានបន្តទៀត ។

បើតាម លោកជំទាវ ជូ ប៊ុនអេង ដដែលបានបន្តទៀតថា កិច្ចប្រជុំលើកទី២ ជាមួយភាគីចិននាពេលនេះ គឺជាការត្រួតពិនិត្យរួមគ្នាលើកិច្ចសហប្រតិបត្តិការ ដែលក្រុមអ្នកទទួលបន្ទុកអនុវត្តកិច្ចព្រមព្រៀងរបស់ប្រទេសទាំងពីរបាន និងកំពុងធ្វើការងារយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ លោកជំទាវ បានបន្តថា កិច្ចព្រមព្រៀងទ្វេភាគីនេះ គឺបានធ្វើឡើងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន ហើយត្រូវបានចុះ

ហត្ថលេខានៅថ្ងៃទី១៣ ខែ តុលា ឆ្នាំ២០១៦ នៅវិមានសន្តិភាព ក្រោមអធិបតីភាព សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម ស៊ី ជីនភីង ប្រធានាធិបតី នៃសាធារណរដ្ឋប្រជាមានិតចិន ។

សូមរំលឹកថា កិច្ចប្រជុំនេះ គឺជាលើកទី២ហើយ ដោយលើកទី១ បានធ្វើឡើងកាលពីឆ្នាំ២០១៧កន្លងទៅនៅខេត្តអានហួយ ប្រទេសចិន ដោយភាគីទាំងពីរបានផ្លាស់ប្តូរព័ត៌មានស្តីអំពីភាពរីកចំរើន នៃកិច្ចសហប្រតិបត្តិការ ក្នុងការបង្ការបង្ក្រាប និងជួយជូរជនរងគ្រោះដោយអំពើជួយជូរមនុស្សដែលភាគច្រើន គឺជាការរងគ្រោះដោយអាពាហ៍ពិពាហ៍ប្រថុយប្រថាន និងផ្ទុយពីធន្ទះជាដើម ។ កិច្ចប្រជុំលើកទី២នេះ គឺបានកំពុងធ្វើឡើងនៅប្រទេសកម្ពុជា ចំនួនបីថ្ងៃ គឺចាប់ពីថ្ងៃទី១០ដល់ថ្ងៃទី១២ ភាគីកម្ពុជាដឹកនាំដោយ លោកជំទាវ ជូរ ប៊ុន អេង និងភាគីចិនដឹកនាំដោយ លោក ស៊ីនស៊ីកូ អគ្គនាយករងនាយកដ្ឋាន ស៊ើបអង្កេតព្រហ្មទណ្ឌ ក្រសួងសន្តិសុខសាធារណៈរដ្ឋប្រជាមានិតចិន ៕

## សមត្ថកិច្ចថៃបានបញ្ជូនសាកសពប្រជាពលរដ្ឋខ្មែរចំនួន១០នាក់និងពលករខុសច្បាប់ចំនួន ៣.៧៥០នាក់ក្នុងខែមេសា ឆ្នាំ២០១៨

http://cambodiapolice.com/ 10:09 pm 9 ឧសភា 2018

**បន្ទាយមានជ័យ៖** អាជ្ញាធរមានសមត្ថកិច្ចថៃបានបញ្ជូនសាកសពប្រជាពលរដ្ឋខ្មែរចំនួន១០នាក់និងពលករខុសច្បាប់ចំនួន៣.៧៥០នាក់ ក្នុងខែមេសា ឆ្នាំ២០១៨ តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត។

ដោយយោងតាមរបាយការណ៍ខែមេសា ឆ្នាំ២០១៨នេះ អាជ្ញាធរមានសមត្ថកិច្ចថៃបានបញ្ជូនសាកសពប្រជាពលរដ្ឋខ្មែរចំនួន៩នាក់ និងកម្ពុជាបញ្ជូនសាកសពថៃម្នាក់ទៅថៃ ហើយបានបញ្ជូនពលករខ្មែរដែលធ្វើការដោយខុសច្បាប់នៅប្រទេសថៃមានចំនួន៧២លើកមានចំនួន៣.៧៥០នាក់ ក្នុងនោះមានបុរសចំនួន១.៩៩០នាក់ ស្រីចំនួន១.៣៥៩នាក់ កុមារ៤០១នាក់។ ក្នុងកិច្ចប្រជុំគណៈបញ្ជាការឯកភាពខេត្តបន្ទាយមានជ័យកាលពីកន្លងទៅថ្មីៗនេះ លោក សួន បវរ អភិបាលខេត្តបន្ទាយមានជ័យបានលើកឡើងថាបញ្ហាពលករចំណាកស្រុកដោយខុសច្បាប់គឺជាបញ្ហាសំខាន់បំផុតចំពោះសុវត្ថិភាពបងប្អូនប្រជាពលរដ្ឋខ្មែរ ដែលទៅរកការងារធ្វើដោយខុសច្បាប់តាមរយៈមេខ្យល់ប្រឈមគ្រោះថ្នាក់ដូចជាឆ្លងព្រំដែនល្មើសច្បាប់និងទៅរកការងារធ្វើនៅប្រទេសថៃដោយខុសច្បាប់។

លោកបានដាក់វិធានការដល់កម្លាំង ដែលឈរជើងតាមបន្ទាត់ព្រំដែនត្រូវលុបបំបាត់នៅច្រករបៀងខុសច្បាប់ឲ្យអស់តាមការណែនាំពីសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវលុបបំបាត់ឲ្យអស់ច្រករបៀងល្មើសច្បាប់ដែលលួចពលករចេញចូលខុសច្បាប់ និងទំនិញគេចពន្ធនិងខូចគុណភាពបទល្មើសផ្សេងៗដែលកើតឡើងទប់ស្កាត់ឲ្យបាន៕ចន្ត្រា

## វគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសបទសម្ភាសន៍និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស

http://cambodiapolice.com/ 5:26 pm 9 ឧសភា 2018

**សៀមរាប** ៖ វគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសបទសម្ភាសន៍និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សដែលមានរយៈពេល៣ថ្ងៃចាប់ពីថ្ងៃទី០៩ ដល់ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ ត្រូវបានធ្វើឡើងនៅសាលប្រជុំស្នងការដ្ឋាននគរបាលខេត្តសៀមរាប ក្រោមអធិបតីភាពឧត្តមសេនីយ៍ទោ សែន សត្យា គ្រូបណ្ឌិតសភាកម្រិតឧត្តមថ្នាក់លេខ១ លោកឧត្តមសេនីយ៍ទោ គឹម ភាព គ្រូបណ្ឌិតសភា កម្រិតឧត្តមថ្នាក់លេខ១ លោកស្រីឧត្តមសេនីយ៍ត្រី ដួង ថាវរី ស្នងការរង និងជាតំណាងដ៏ខ្ពង់ខ្ពស់លោកឧត្តមសេនីយ៍ត្រី ទិត្យ ណារ៉ុង ស្នងការនគរបាលខេត្តសៀមរាប និងអស់លោក លោកស្រី តំណាងអង្គការបេសកម្មយុត្តិធម៌អន្តរជាតិកម្ពុជា( IernetionalJusticeMissionCombodia )

និងអង្គការទស្សនៈពិភពលោកអន្តរជាតិកម្ពុជា(WorldvisionInternationalCombodia)(WuICombodia) ដែលមានសិក្ខាកាមអញ្ជើញចូលរួមមានលោកនាយនាយរងការិយាល័យ លោកនាយនាយរងផ្នែកការិយាល័យជំនាញជួញដូរផ្លូវភេទនិងការពារអនិតិជននិងអធិការចំនួន៦ស្រុកដែលមាន-ស្រុកពួក ស្រុកក្រឡាញ់ ស្រុកស្រីស្នំ ស្រុកប្រាសាទបាគង ស្រុកអង្គរធំ ស្រុកអង្គរជុំ និងប៉ុស្ដិ៍ចំនួន៤៩ប៉ុស្ដិ៍សរុប៦០នាក់ចូលរួមផងដែរ។

លោកស្រី ដួង ថាវរី ស្នងការរងបានឡើងមានមតិស្វាគមន៍និងអានរបាយការណ៍អំពីលទ្ធផលការងារនិងបទពិសោធន៍ ដែលកងកម្លាំងនគរបាលជំនាញយើងបានអនុវត្តកន្លងមកក្នុងការងារជំនាញបង្ការទប់ស្កាត់បទល្មើសជួញដូរស្ត្រី និងកុមារការរំលោភបំពារបំពានកេងប្រវ័ញ្ចផ្លូវភេទលើស្ត្រី និងកុមាជូនអង្គពិធីរួចមកលោកឧត្តមសេនីយ៍ទោ សែន សត្យាគ្រូបណ្ឌិតសភាកម្រិតឧត្តមថ្នាក់លេខ១ បានមានមតិសំណេះសំណាលដល់សិក្ខាកាមដែលមានមុខនាពេលនេះអោយយកចិត្តទុកស្ដាប់ការពន្យល់របស់គ្រូឧទ្ទេសនាម ដើម្បីទទួលយកចំណេះដឹងនឹងបទពិសោធន៍ថ្មីៗដើម្បីយកទៅអនុវត្តការងារជំនាញបច្ចេកទេសបទសម្ភាសន៍ និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅករណីដែលកើតឡើងនៅតាមមូលដ្ឋានដែលខ្លួនគ្រប់គ្រងអោយកាន់តែមានប្រសិទ្ធិភាពខ្ពស់និងតម្លាភាព ៕

## កូនប្រុសលោកស្នងការរងម្នាក់ជាប់ចោទករណីបង្ខាំងមនុស្សទុករំលោភ

http://www.rasmeinews.com/ May 9, 2018, 5:01 PM

*ដោយៈចាន់ថន/ព្រៃវែងៈ* កាលពីព្រឹកថ្ងៃទី៩ខែឧសភាឆ្នាំ២០១៨នារីម្នាក់បានមកដាក់ពាក្យប្ដឹងនៅអធិការដ្ឋាននគរបាលស្រុកកំពង់ត្របែកខេត្តព្រៃវែង។ ក្នុងពាក្យបណ្ដឹងនោះបានប្ដឹងចោទប្រកាន់ទៅលើបុរសជាមន្ត្រីនគរបាលខេត្តព្រៃវែងម្នាក់ឈ្មោះឌឹមមករាឋាននន្តរស័ក្តិអនុសេនីយ៍ទោនិងជាកូនប្រុសបង្កើតរបស់លោក ឧត្តមសេនីយ៍ត្រី ឌឹម យ៉ារ៉ុប ស្នងការរងខេត្តព្រៃវែង។

សេចក្ដីរាយការណ៍បឋមបានឲ្យដឹងថា ស្ត្រីរងគ្រោះមានស្រុកកំណើតនៅស្រុកកំពង់ត្របែក ។ រីឯជនរងបណ្ដឹងក៏នៅស្រុកកំពង់ត្របែកដូចគ្នា។ ជាមួយគ្នានោះនារីរងគ្រោះបានប្ដឹងចោទប្រកាន់ថា ឈ្មោះឌឹមមករាបានចាប់រំលោភនាង និងបង្ខាំងនាងទុកសម្រាប់រំលោភអស់រយៈពេលជាង៤ខែ។ មិនតែប៉ុណ្ណោះជននេះរៀបគម្រោងលក់នាងឲ្យទៅប្រុសផ្សេង និងគំរាមបាញ់សម្លាប់នាងទាំងពូជទៀតផង។

ទោះជាយ៉ាងណាលោក ឧត្តមសេនីយ៍ទោ ស្រេង ជា ស្នងការខេត្តព្រៃវែង បានឲ្យដឹងនៅល្ងាចថ្ងៃទី៩ខែឧសភានេះថាចំពោះបណ្ដឹងមួយនេះ នារីរងគ្រោះទើបនឹងមកដាក់ពាក្យប្ដឹងនៅអធិការស្រុកកំពង់ត្របែក កាលពីម៉ោង១០ព្រឹកទី០៩ខែឧសភា នេះទេ។ លោកបានបញ្ជាឱ្យកម្លាំងនគរបាល ស្រុកនិងខេត្ត ចុះស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់ បើឃើញថា កូនលោកស្នងការរងប្រព្រឹត្តដូចការចោទប្រកាន់នោះមែនលោកនិងចាត់ការតាមច្បាប់ដោយមិនយោគយល់ឡើយ៕S/

## ស្ត្រីជួលក្មេងឱ្យសុំទានត្រូវបានផ្ដន្ទាទោសឱ្យជាប់ពន្ធនាគារ ៨ ឆ្នាំ

https://www.postkhmer.com/ នៀម ឆេង | Publication date 10 May 2018 | 10:22

ភ្នំពេញៈ សាលាដំបូងរាជធានីភ្នំពេញបានប្រកាសផ្ដន្ទាទោសស្រី ឈ្មោះ ភួង ចន្ទី អាយុ ៥០ ឆ្នាំដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំពីបទ «ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច» នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ នេះបើតាមអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) កម្ពុជា និងលោក សេក សារឿន ជាមេធាវីការពារក្មេងៗរងគ្រោះ ៧ នាក់។

លោក សេក សារឿន បញ្ជាក់ថាការប្រកាសនេះបានធ្វើឡើងកាលពីថ្ងៃសុក្រ ក្រោយបើកសវនាការនៅថ្ងៃ ១០ មេសាដែលមានលោកចៅក្រម ម៉ុង មុនីសោភា ជាប្រធានក្រុមជំនុំជម្រះ។ លោកថាក្នុងសវនាការស្រីជាប់ចោទបានសារភាពថាខ្លួនបានបង្ខំក្មេងឲ្យសុំទាន ហើយយកលុយឲ្យខ្លួនដោយការប្រព្រឹត្តដូច្នេះ ៨ ឆ្នាំមកហើយ។ លោក សេក សារឿន ថ្លែងថាកុមារទាំងនោះទទួលបានអាហារតែ ១ ពេលក្នុង ១ ថ្ងៃហើយត្រូវបង្ខំឲ្យសុំទានឲ្យបាន ២ ដុល្លារក្នុង ១ ថ្ងៃ បើមិនបាននឹងត្រូវទទួលការវាយនឹងខ្សែភ្លើង និងបង្ខំឲ្យដេកលើបង់តាមទីសាធារណៈ។

ដោយឡែកលោក អោ គឹមអាន នាយលេខាធិការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញបានឲ្យដឹងថា ស្ត្រីឈ្មោះ ក្លូង ចន្នី បានជួលក្មេងៗទាំងនោះពីអ្នកសុំទានផ្សេងទៀតដោយមានក្មេង ៥ នាក់ចេះដើរ ហើយក្មេង ២ នាក់ទៀតមិនទាន់ចេះដើរ។ លោកថា៖ «ក្មេងដែលចេះដើរគាត់ឲ្យដើរសុំទាន ចំណែកក្មេងតូចៗគាត់ពដើរសុំ និងជួលគេម្នាក់ឲ្យពដើរសុំដូចគាត់។ គាត់ជាអ្នកចាត់ចែងហើយគាត់ជាអ្នកដើរប្រមូលលុយ»។

លោក យូ សុភ័ក្រ្ត អនុប្រធានមន្ទីរសង្គមកិច្ចរាជធានី-ភ្នំពេញថ្លែងស្វាគមន៍ចំពោះការដាក់ទោសស្ត្រីនេះដោយលោកថ្លែងថា វាអាចជាការទប់ស្កាត់កុំឲ្យមានកុមាររងគ្រោះក្នុងអំពើដូច្នេះបន្តទៀត៕

## បុរសអាមេរិកចូលនិវត្តន៍ត្រូវបានចោទប្រកាន់បើក «ទេសចរណ៍ផ្លូវភេទ» តាមព្រំដែនថៃ-ភូមា

http://www.cen.com.kh/ May 9, 2018

បុរសអាមេរិកម្នាក់ត្រូវបានចាប់ខ្លួន ក្នុងប្រតិបត្តិការចោទប្រកាន់បើកសេវាបនពេស្យាចរតាមអនឡាន ដែលបាន «អូសទាញ» បុរសៗនៅក្នុងភាគខាងជើងនៃប្រទេសថៃ ឲ្យត្រូវរ៉ូវគ្នាជាមួយស្ត្រីកស៊ីផ្លូវភេទភូមា នៅតាមព្រំដែនរវាងប្រទេសទាំងពីរ ។ ប៉ូលីសនិយាយថា បុរសអាមេរិកឈ្មោះ Kenneth Viggo Albertsen អាយុ ៦៦ ឆ្នាំ កំពុងរស់នៅក្នុងខេត្ត Chiang Rai តាមរយៈទិដ្ឋាការចូលនិវត្តន៍ គឺស្ថិតនៅពីក្រោយវេបសាយមួយ និងផេកហ្វេសប៊ុកឈ្មោះ "Burmese Border Chicks for Hire" ដែលបានលក់សេវាកម្មផ្លូវភេទជាមួយស្ត្រីភូមាក្នុងតម្លៃ ៦,៥០០ បាត (២០០ ដុល្លារ) ។ វេបសេវាកម្មផ្លូវភេទនេះ បាននាំយកស្រីៗ ទៅជួបអតិថិជនជាច្រើន នៅតាមបណ្តោយព្រំដែន Mae Sai និងក៏បាន « ណែនាំ» បុរសៗចូលទៅភូមា ដើម្បីរកសេវាកម្មផ្លូវភេទនេះផងដែរ ។ មេបញ្ជាការរងប៉ូលីសបង្ក្រាបបទឧក្រិដ្ឋកម្មថៃ លោកវរសេនីយឯក Jirabhob Bhuridej បាននិយាយថា៖ «បុរសជនជាតិអាមេរិកនេះបានបើកមុខរបរខុសច្បាប់នេះយ៉ាងតិច ១០ ឆ្នាំ មកហើយ» ៕ **ចន្នី**

## ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨

## ប្រមុខរាជរដ្ឋាភិបាលកម្ពុជា អំពាវនាវឱ្យកម្មករធ្វើការខុសច្បាប់ នៅថៃ អាចមករកធ្វើការក្នុងប្រទេសវិញ ព្រោះកម្ពុជាកំពុងត្រូវការកម្លាំងពលកម្ម

http://www.freshnewsasia.com/ 2018-05-10

**(បាវិត-ស្វាយរៀង)៖** ថ្លែងចេញពីខេត្តស្វាយរៀង សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា នៅព្រឹកថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨នេះ បានអំពាវនាវឱ្យកម្មករ-កម្មការិនី ដែលកំពុងធ្វើការនៅប្រទេសថៃ អាចត្រឡប់មកធ្វើការនៅក្នុងប្រទេស ព្រោះនៅក្នុងស្រុកកំពុងត្រូវការកម្លាំងពលកម្ម។

ការមានប្រសាសន៍ខាងលើនេះ របស់សម្តេចតេជោ ហ៊ុន សែន ត្រូវបានធ្វើឡើងនៅព្រឹកថ្ងៃព្រហស្បតិ៍ ១១រោច ខែពិសាខ សំរឹទ្ធស័ក ព.ស២៥៦២ ត្រូវថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨នេះ ក្នុងឱកាសសម្តេចតេជោ បានបន្តអញ្ជើញជួបសំណេះសំណាលជាមួយកម្មករ កម្មការិនីជិត ២ម៉ឺននាក់ នៅទីតាំងតំបន់សេដ្ឋកិច្ចពិសេស អ៊ិនជើវៀ អូតូម៉ូបាល អ៊ិនដាសស្រ្ទី ខមផ្លេកស៍ ក្នុងក្រុងបាវិត ខេត្តស្វាយរៀង។ កម្មករ-កម្មការិនីក្នុងខេត្តស្វាយរៀង ដែលសម្តេចតេជោ ហ៊ុន សែន អញ្ជើញជួបសំណេះសំណាលជាមួយនេះ មកពីរោងចក្រ សហគ្រាសចំនួន៣២ ក្នុងនោះមកពីរោងចក្រ សហ

គ្រាសនៅតំបន់សេដ្ឋកិច្ចពិសេសតាយសេងចំនួន ២៤រោងចក្រ, តំបន់សេដ្ឋកិច្ចពិសេសនាគរាជចំនួន ៤រោងចក្រ និងតំបន់សេដ្ឋកិច្ចពិសេសសានតុងចំនួន ៤រោងចក្រ។

ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានមានប្រសាសន៍យ៉ាងដូច្នេះថា «**ឥឡូវនេះបងប្អូនកម្មករ កម្មការិនី ដែលទៅធ្វើការនៅប្រទេសក្រៅ ជាពិសេសទៅប្រទេសថៃ ដោយទៅធ្វើការខុសច្បាប់នៅទីនោះត្រឡប់មកវិញក៏អាចធ្វើមករកការងារធ្វើនៅក្នុងប្រទេសបាន ដែលពេលនេះយើងកំពុងខ្វះកម្មករហើយ**»។

ជាមួយគ្នានេះសម្តេចតេជោ បានមានប្រសាសន៍បន្តថា គ្រាន់តែសណ្ឋាគារមួយ គឺត្រូវការកម្លាំងកម្មករជិត ១០០០នាក់ ក៏ប៉ុន្តែឥឡូវនេះនៅខ្វះខាតកម្លាំងកម្មករប៉ុន្មានរយនាក់ទៀត ឯណោះទាំងនេះដោយសារកំណើនការងារនៅក្នុងប្រទេសកំពុងត្រូវការយ៉ាងខ្លាំង ហើយក៏ទទួលបានប្រាក់ខែខ្ពស់រហូតជាង២០០ដុល្លារ និងធ្វើការនៅក្នុងម៉ាស៊ីនត្រជាក់ នៅតែរកកម្លាំងពលកម្មមិនគ្រប់ទៀត។ ទទឹមនឹងនេះ ចំការកៅស៊ូ, ចំការម្រេច និងកសិដ្ឋានកសិកម្មមួយចំនួនកំពុងតែខ្វះកម្លាំងកម្មករធ្វើការ ក៏ប៉ុន្តែប្រជាពលរដ្ឋមួយចំនួនបែរជានាំគ្នា ធ្វើចំណាក់ស្រុកទៅប្រទេសថៃ ដោយប្រថុយប្រថានទៅវិញ ព្រោះគិតថាទទួលបានប្រាក់បៀវត្សខ្ពស់ជាងនៅក្នុងស្រុក ក៏ប៉ុន្តែវាមិនប្រាកដថាទទួលបានផលខ្ពស់នោះទេ ព្រោះត្រូវការលើថ្លៃចំណាយខ្ពស់លើម្ហូបអាហារ និងកន្លែងស្នាក់នៅ។

ថ្លែងចេញពីលើវេទិកាសម្តេចតេជោ ក៏បានក្រើនរំលឹកដល់ក្មួយៗកម្មករ កម្មការិនីទាំងអស់ត្រូវខិតខំធ្វើការ និងត្រូវចងចាំថាមិនឱ្យមានក្រុមណាមួយ ឬមនុស្សណាម្នាក់មកបំផ្លិចបំផ្លាញ សន្តិភាពដែលកម្ពុជាកំពុងតែមាននៅក្នុងពេលបច្ចុប្បន្ននេះជាដាច់ខាត ហើយមានតែសន្តិភាពប៉ុណ្ណោះ ដែលអាចនាំមកនូវការអភិវឌ្ឍបាន ឪពុក ម្តាយ ជីដូន ជីតា របស់ក្មួយៗបានជួបប្រទះរឿងសោកនាដកម្មច្រើនណាស់ នៅក្នុងអតីតកាល មានក្មួយៗខ្លះមិនទាន់ស្គាល់មុខជីដូន ជីតារបស់ខ្លួននោះទេ ព្រោះត្រូវបានក្រុម ប៉ុល ពត កាប់សម្លាប់យ៉ាងរង្គាល់។

ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានបញ្ជាក់ថា ងាយស្រួលណាស់ក្នុងការរក្សាសន្តិភាព ស្ថិរភាពនយោបាយ គឺត្រូវបោះឆ្នោតឱ្យគណបក្សប្រជាជនកម្ពុជា តែមួយគត់ ដើម្បីធានារក្សាសន្តិភាព និងដើម្បីបន្តដឹកនាំនាវាកម្ពុជា ទៅរកការអភិវឌ្ឍលើគ្រប់វិស័យរហូតមកដល់សព្វថ្ងៃនេះ ជាពិសេសកុំជឿលើការញុះញង់ បំភ័ន្តការពិត ក្នុងន័យបំផ្លិចបំផ្លាញកម្ពុជាឱ្យខ្ទិចខ្ទីដូចអតីតកាល៕

## សម្តេចក្រឡាហោម ស ខេង អនុញ្ញាតិឲ្យប្រតិភូចិនចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ

http://cambodiapolice.com/ 6:26 pm 10 ឧសភា 2018 119

**ភ្នំពេញ ៖** សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នាល្ងាចថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨នេះ បានអនុញ្ញាតឲ្យប្រតិភូចិន ដែលដឹកនាំដោយ លោកចិន ស៊ីហ្គូ (CHEN SHIQU) អគ្គនាយករងនៃអគ្គនាយកដ្ឋានស៊ើបអង្កេតព្រហ្មទណ្ឌ ក្រសួងសន្តិសុខសាធារណៈ នៃសាធារណៈរដ្ឋប្រជាមានិតចិន ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅទីស្តីការក្រសួងមហាផ្ទៃ ។

ថ្លែងប្រាប់អ្នកយកព័ត៌មានក្រោយពីកិច្ចជំនួបនោះ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានលើកឡើងថា នៅក្នុងកិច្ចជំនួប សម្តេចក្រឡាហោម ស ខេង និងភាគីចិនបានយល់ស្របគ្នាក្នុងការឲ្យមានកិច្ចប្រជុំលើកទី២ នៅប្រទេសកម្ពុជា ដើម្បីស្វែងរកដំណោះស្រាយបន្ថែមសម្រាប់ជួយដល់ស្ត្រីខ្មែរដែលត្រូវបានជួញដូរ និងរងគ្រោះនៅប្រទេសចិននោះ ។ លោកជំទាវ បានបន្តថា ភាគីចិន លោក ចិន ស៊ីហ្គូ (CHEN SHIQU) បានស្វាគមន៍ជានិច្ចសម្រាប់កិច្ចសហប្រតិបត្តិការជាមួយកម្ពុជាក្នុងការជួយសង្គ្រោះស្ត្រីខ្មែរ ដែលបានចាញ់បោកមេខ្យល់ឲ្យរៀបការជាមួយបុរសចិនដោយខុសច្បាប់ និងស្ត្រីខ្មែរដែលបានរងគ្រោះពីកត្តាផ្សេងៗនៅប្រទេសចិន ។

លោក ចិន ស៊ីហ្គូ (CHEN SHIQU) បានរំពឹងថាឆ្នាំលើកទី២រវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពីភាពរីកចំរើន នៃការអនុវត្តកិច្ចព្រមព្រៀងសហប្រតិបត្តិការក្នុងការបង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងផែនការសកម្មភាពនេះនឹងទទួលបានជោគជ័យក្នុងការរិះរកផែនការបន្ថែមសម្រាប់ជួយស្ត្រីរងគ្រោះទាំងនោះ ។

បើតាម លោកជំទាវ ជូ ប៊ុនអេង បានឲ្យដឹងថា នៅក្នុងកិច្ចជំនួបនោះ សម្តេចក្រឡាហោម ស ខេង បានថ្លែងអំណរអគុណយ៉ាងខ្លាំងចំពោះរដ្ឋាភិបាលចិន ដែលបានជួយសហការក្នុងការជួយទប់ស្កាត់ និងជួយសង្គ្រោះស្ត្រីខ្មែរដែលរងគ្រោះនៅប្រទេសចិន ។ យ៉ាងណាក៏ដោយ សម្តេច ក៏បានជម្រុញដល់កិច្ចប្រជុំត្រូវតែធ្វើយ៉ាងម៉េចរិះរកមធ្យោបាយយ៉ាងណាទប់ស្កាត់កុំឲ្យមានករណីស្ត្រីខ្មែររៀបអាពាហ៍ពិពាហ៍ជាមួយបុរសចិនដោយខុសច្បាប់ទៀត ហើយគប្បីរិះរកយ៉ាងណាណែនាំដល់ស្ត្រីទាំងនោះកុំឲ្យចាញ់បោកមេខ្យល់ទៀតផងដែរ ៕

## សម្តេចក្រឡាហោម ៖ ប្រើគ្រប់មធ្យោបាយ ទប់ស្កាត់កុំឲ្យមាន ស្ត្រីខ្មែរ រៀបការ ជាមួយបុរសចិន ដោយខុសច្បាប់ទៀត

http://www.cen.com.kh/ May 11, 2018

ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានជំរុញគ្រប់ភាគីពាក់ព័ន្ធ ជាពិសេសរដ្ឋាភិបាលចិន ត្រូវតែធ្វើយ៉ាងណា រិះរកគ្រប់មធ្យោបាយ ទប់ស្កាត់កុំឲ្យមានករណី ស្ត្រីខ្មែរ រៀបអាពាហ៍ពិពាហ៍ ជាមួយបុរសចិន ដោយខុសច្បាប់ទៀត ហើយគប្បីរិះរកយ៉ាងណា ណែនាំដល់ស្ត្រីទាំងនោះ កុំឲ្យចាញ់បោកមេខ្យល់ទៀត។

ថ្លែងប្រាប់អ្នកយកព័ត៌មានក្រោយពីកិច្ចជំនួបសម្តេចក្រឡាហោម ស ខេង ជាមួយនឹងប្រតិភូចិន លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានលើកឡើងថា នៅក្នុងកិច្ចជំនួប សម្តេចក្រឡាហោម ស ខេង និងភាគីចិន បានយល់ស្របគ្នា ក្នុងការឲ្យមានកិច្ចប្រជុំលើកទី២ នៅប្រទេសកម្ពុជា ដើម្បីស្វែងរកដំណោះស្រាយបន្ថែម សម្រាប់ជួយដល់ស្ត្រីខ្មែរ ដែលត្រូវបានជួញដូរ និងរងគ្រោះ នៅប្រទេសចិន ដោយការជួញដូរនិងរៀបអាពាហ៍ពិពាហ៍ ដោយខុសច្បាប់ ។

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នាល្ងាចថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨នេះ បានអនុញ្ញាតឲ្យប្រតិភូចិន ដែលដឹកនាំដោយ លោកចិន ស៊ីហ្គូ (CHEN SHIQU) អគ្គនាយករង នៃអគ្គនាយកដ្ឋានស៊ើបអង្កេតព្រហ្មទណ្ឌ ក្រសួងសន្តិសុខសាធារណៈ នៃសាធារណៈរដ្ឋប្រជាមានិតចិន ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅទីស្តីការក្រសួងមហាផ្ទៃ ។

លោកស្រីរដ្ឋលេខាធិការ បានបន្តថា លោក ចិន ស៊ីហ្គូ (CHEN SHIQU) បានស្វាគមន៍ជានិច្ច សម្រាប់កិច្ចសហប្រតិបត្តិការ ជាមួយកម្ពុជា ក្នុងការជួយសង្គ្រោះស្ត្រីខ្មែរ ដែលបានចាញ់បោកមេខ្យល់ ឲ្យរៀបអាពាហ៍ពិពាហ៍ ជាមួយបុរសចិន ដោយខុសច្បាប់ និងស្ត្រីខ្មែរ ដែលបានរងគ្រោះ ពីកត្តាផ្សេងៗនៅប្រទេសចិន ។

លោក ចិន ស៊ីហ្គូ បានរំពឹងថា រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលចិន ស្តីពីភាពរីកចម្រើន នៃការអនុវត្តកិច្ចព្រមព្រៀងសហប្រតិបត្តិការក្នុងការបង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងផែនការសកម្មភាពនេះនឹងទទួលបានជោគជ័យក្នុងការរិះរកផែនការបន្ថែមសម្រាប់ជួយស្ត្រីរងគ្រោះទាំងនោះ ។ លោកស្រី ជូរ ប៊ុនអេង បានឲ្យដឹងថា សម្តេចក្រឡាហោម ស ខេង បានថ្លែងអំណរអគុណយ៉ាងខ្លាំងចំពោះរដ្ឋាភិបាលចិន ដែលបានជួយសហការក្នុងការជួយទប់ស្កាត់ និងជួយសង្គ្រោះស្ត្រីខ្មែរដែលរងគ្រោះនៅប្រទេសចិន ៕ ដោយៈបញ្ញាស័ក្តិ

## ផ្តន្ទាទោសបុរសជប៉ុន និងប្រពន្ធខ្មែរម្នាក់ ដាក់គុកម្នាក់៧ឆ្នាំ រឿងនាំស្រ្តីខ្មែរទៅលក់នៅប្រទេសជប៉ុន

https://www.facebook.com/ApsaraNewsNetwork/ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨

រាជធានីភ្នំពេញ៖ កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ ម្សិលមិញ លោក វេង ហត់ ប្រធានក្រុមប្រឹក្សាចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានីភ្នំពេញ បានបើកសវនាការប្រកាសសាលក្រមផ្តន្ទាទោស ជនជាប់ចោទ បុរសជនជាតិជប៉ុនម្នាក់ និងស្រ្តីខ្មែរជាប្រពន្ធ ដែលពាក់ព័ន្ធករណីនាំស្រ្តីខ្មែរទៅលក់នៅប្រទេសជប៉ុន។

សាលក្រមរបស់តុលាការបានសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ Furju Sukumo ភេទប្រុស អាយុ៥២ឆ្នាំ ជនជាតិជប៉ុន ជាប្តី ដាក់ពន្ធនាគារកំណត់រយៈពេល ៧ឆ្នាំ និងបង្គាប់ឲ្យសងជនរងគ្រោះចំនួន ២០លានរៀល និងជនជាប់ចោទឈ្មោះ លឹម លក្ខណា ភេទស្រី អាយុ២៦ឆ្នាំ ជាប្រពន្ធ ដាក់ពន្ធនាគារកំណត់រយៈពេល៧ឆ្នាំ ប៉ុន្តែអនុវត្តទោសត្រឹម ៤ឆ្នាំ ក្នុងពន្ធនាគារទោសសល់ពីនោះត្រូវព្យួរធម្មតា ពីបទជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ចន៍ ប្រព្រឹត្តកាលពីអំឡុងខែ សីហា ឆ្នាំ២០១៦ យោងតាមមាត្រា១២ នៃច្បាប់ ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

យោងតាមប្រភពពីសមត្ថកិច្ចនៃមន្ទីរប្រឆាំងការជួញដូរមនុស្ស បានឲ្យដឹងថា ជនជាប់ចោទទាំង២នាក់ បានសារភាពនៅក្នុងសវនាការថា ពួកគេពិតជាបាន ប្រកាសជ្រើសរើស និងបញ្ជូននារីរងគ្រោះ ចំនួន១០នាក់ ទៅប្រទេសជប៉ុន មែន ប៉ុន្តែរឿង លក់ស្រ្តីរងគ្រោះឲ្យផ្ទះបននៅប្រទេសជប៉ុន ពួកគេមិនបានដឹងនោះទេ គឺខាងថៅកែនៅប្រទេសជប៉ុនជាអ្នកធ្វើ។

យោងតាមរបាយការណ៍របស់សមត្ថកិច្ចកាលពីពេលចាប់ខ្លួន ជនជាប់ចោទ បានបញ្ជាក់ថា ក្រុមជនជាប់ចោទបានរួមគំនិតគ្នា លួងលោម និងបោកបញ្ឆោតនាំនារីខ្មែរ ចំនួន ១០នាក់ឲ្យទៅធ្វើការនៅប្រទេសជប៉ុន ដោយឲ្យប្រាក់ខ្ចីមុនក្នុងម្នាក់ៗ ៥០០ដុល្លារ។ ក្រុមជនជាប់ចោទ បានសន្យាផ្តល់ការងារដល់ជនរងគ្រោះ នៅប្រទេសជប៉ុន ដែលមានប្រាក់ខែចាប់ពី ៣៥០០ដុល្លារ ទៅដល់៥០០០ដុល្លារ ក្នុង១ខែ។ មិនដូចអ្វីដែលបានសន្យាឡើយ ក្រុមជនជាប់ចោទទាំង៣នាក់ បាននាំនារីរងគ្រោះយកទៅលក់ឲ្យផ្ទះបន ដើម្បីបម្រើផ្លូវភេទទៅវិញ។ ក្រោយមកក្រុមនារីរងគ្រោះបាននាំគ្នាទៅប្តឹងសមត្ថកិច្ចឲ្យជួយរំដោះចេញពីបននោះបាន និងត្រូវបានអាជ្ញាធរកម្ពុជាជួយនាំមកប្រទេសកំណើតវិញ៕
ដោយ៖ ឡុក សំរិត

## កម្ពុជានិងថៃសហការគ្នាជួយពលករចំណាស្រុកខ្មែរ

https://wmc.org.kh/ ថ្ងៃព្រហស្បតិ៍ ទី១០ ខែឧសភា ឆ្នាំ២០១៨ ធូ វីរៈ

ភ្នំពេញ៖ ក្នុងសិក្ខាសាលានៅទីក្រុងបាងកក ប្រទេសថៃ កាលពីថ្ងៃ អង្គារ ទី ៨ ខែ ឧសភានេះ រាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលថៃ សហការគ្នាយ៉ាងជិតស្និទ្ធជាមួយអង្គការក្រៅរដ្ឋាភិបាល ដើម្បីជួយឲ្យពលករខ្មែរចំណាកស្រុកប្រកបដោយសុវត្ថិភាពនៃអំពីការជួញដូរមនុស្ស និងការពារសិទ្ធិការងាររបស់ពួកគេកាន់តែមានប្រសិទ្ធភាព។ នេះបើតាម កាសែត Bangkok Post។ កិច្ចការនេះរដ្ឋាភិបាលទាំងពីរទទួលបានពីគម្រោងជំនួយពីសហភាពអឺរ៉ុប (EU) ហៅថា គម្រោង MIG-RIGHT។ គម្រោងនេះគាំទ្រ និងជួយការពារសិទ្ធិពលករចំណាកស្រុកខ្មែរធ្វើការងារនៅប្រទេសថៃ ហើយទប់ស្កាត់អំពើហិង្សា និងការជួញដូរមនុស្ស។ លើសពីនេះគម្រោងនេះក៏នឹងជួយដោះស្រាយបញ្ហាដល់ពលករចំណាកស្រុកខ្មែរចូលទៅប្រទេសថៃ ដោយខុសច្បាប់ផងដែរ។ នេះបើតាម កាសែត Bangkok Post ។ កាសែតថៃបញ្ជាក់ថា បើតាមតួរលេខរបស់រដ្ឋាភិបាលកម្ពុជា និងសហភាពអឺរ៉ុប ពលករជាង ៩០ ភាគរយ ក្នុងចំណោមពលករចំណាកស្រុកខ្មែរបម្រើការងារនៅប្រទេសថៃ ១ លាន ២ សែន នាក់ ប៉ុន្តែពលករតិចជាង ៣០ ភាគរយ ក្នុងចំណោមនោះកំពុងចំណាកស្រុកទៅថៃតាមច្រកទ្វារអន្តរជាតិនានារបស់រដ្ឋាភិបាលកម្ពុជា។

បើតាមការិយាល័យគ្រឿងញៀន និងឧក្រិដ្ឋកម្ម នៃអង្គការសហប្រជាជាតិ (UNODC) ឲ្យដឹងថា ប្រជាពលរដ្ឋកម្ពុជាដែលចង់ចូលទៅរកការងារធ្វើនៅប្រទេសថៃក្រោមកិច្ចព្រមព្រៀងទ្វេភាគីត្រូវបង់ប្រាក់ចន្លោះពី ៦០០ ដុល្លារ ទៅ ៧៥០ ដុល្លារក្នុងម្នាក់។ តែជាមួយគ្នានេះ របាយការណ៍របស់អង្គការ Human Right Watch ក្រោមចំណងជើងថា«ការរំលោភសិទ្ធិ និងធ្វើការដោយបង្ខំនៅឧស្សាហកម្មនេសាទក្នុងប្រទេសថៃ» ចេញផ្សាយនៅដើមឆ្នាំ ២០១៨ រកឃើញថាពលករខ្មែរ និងភូមា រងការរំលោភបំពាន់សិទ្ធិ និងការជួញដូរមនុស្ស រួមទាំងការបើកប្រាក់ខែមិនទៀងទាត់ និងទទួលបានកម្រៃទាប។ លើសពីនេះ ពលករទាំងនោះខ្វះការគាំពារផ្នែកច្បាប់នោះទេ។ Human Right Watch អះអាងថា ពលករធ្វើការលើទូកនេសាទនៅប្រទេសថៃប្រមាណ ៥ ម៉ឺននាក់ត្រូវបានរំលោភសិទ្ធិធ្ងន់ធ្ងរ ហើយនៅឆ្នាំ ២០១៥ រដ្ឋាភិបាលថៃរកមិនឃើញសូម្បី មួយករណីក្នុងចំណោមពលករជាង ៤៧ម៉ឺននាក់ ត្រូវបានបង្ខំឲ្យធ្វើការហួសកម្លាំង។

កាសែតបាងកកប៉ុស្ដិ៍ បានដកស្រង់ប្រសាសន៍មន្ត្រីតំណាងនាយកដ្ឋានការពារពលកម្ម និងសុខមាភាពនៃក្រសួងការងារថៃ ឲ្យដឹងថា ច្បាប់ថ្មីបានតឹងរឹងដោយការពារពលករលើទូកនេសាទ និងពលកម្មផ្នែកផ្សេងទៀត បានអនុម័តរួចរាល់ហើយ។ មន្ត្រីតំណាងនាយកដ្ឋានការពារពលកម្ម និយាយថា ច្បាប់ថ្មីនេះតម្រូវឲ្យនយោជិក និងនយោជកចុះកិច្ចសន្យា ក្នុងការផ្ទេរប្រាក់ដោយផ្ទាល់តាមរយៈធនាគារ។ និយោជិក ឬថៅកែ ត្រូវរក្សាទុកកំណត់ត្រាត្រឹមត្រូវ ដើម្បីកត់ត្រា ការបង់ប្រាក់ឲ្យកម្មករចំណាកស្រុក ក្នុងការកាត់បន្ថយការជួញដូរមនុស្ស និងការកេញប្រវ័ញ្ចកម្មករ និងការកើនឡើងទ្វេដងនៃការត្រួតពិនិត្យដោយនាយកដ្ឋាននិងនគរបាលរាជភូមិន្ទថៃ ដើម្បីកាត់បន្ថយការគំរាមកំហែងដល់សិទ្ធិពលករចំណាកស្រុក៕

## នារីពលករខ្មែរម្នាក់ កៀបបម្រាមដៃនិងម៉ាស៊ីនកិនម្សៅ ស្រែកយំយ៉ាងវេទនា

http://www.pheaktraprak.com May 10, 2018

កាលពីវេលាម៉ោង១១:៣០នាទី ថ្ងៃត្រង់ នាថ្ងៃព្រហស្បតិ៍ ទី១០ ខែឧសភា ឆ្នាំ២០១៨ មានករណីនារីពលករកម្ពុជាម្នាក់ ឈ្មោះ ឆាគុណ ដូរយ៉ើ (ชาคูณ โดยี)អាយុ ២៤ ឆ្នាំ សញ្ជាតិខ្មែរ ធ្វើការនៅក្នុងសិប្បកម្មធ្វើនំប៉័ង មួយកន្លែងស្ថិតនៅក្នុងផ្ទះ២៨៥/៤០ ឡូ៨ សង្កាត់ ស៊ូសាក់ ស្រុកស៊ីរាចផា ខេត្តឈុនបុរី ប្រទេសថៃ បានកើតឧបទ្ទវហេតុរងគ្រោះត្រូវម៉ាស៊ីនកិនម្សៅធ្វើនំប៉័ងកៀបជាប់ម្រាមដៃ ខាងស្តាំបណ្តាលឲ្យជាប់គាំងម្រាមដៃ ធ្វើឲ្យនារីរងគ្រោះស្រែកយំដោយក្តីវេទនា នៅវេលាបន្តបន្ទាប់នារីរងគ្រោះបានភ្នាក់ងារសង្គ្រោះស្រុកស៊ីរាចផា ជួយអន្តរាគមន៍ ដោះយកម្រាមដៃចេញរួចបញ្ជូនទៅព្យាបាលនៅមន្ទីរសម្តេចប្រាក់បារមេរាចថេវី ដោយសុវត្ថិភាព។ ប្រភពពី÷HotNewsChonburiTV

## ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨

### គណៈប្រតិភូក្រសួងសន្តិសុខសាធារណៈចិន ជួបពិភាក្សាការងារជាមួយអភិបាលខេត្ត ព្រះសីហនុ

http://www.akp.gov.kh/kh/ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៨

AKP ព្រះសីហនុ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៨ –គណៈប្រតិភូក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋប្រជាមានិតចិន ដឹកនាំដោយ ឯកឧត្តម Chen Shiqu អគ្គនាយករង នៃក្រសួងសន្តិសុខសាធារណៈចិន បាន ចូលជួបពិភាក្សា និងឈ្វេងយល់អំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅព្រះរាជាណាចក្រកម្ពុជា ពិសេស នៅក្នុងខេត្តព្រះសីហនុ កាលពីថ្ងៃសុក្រ ១២រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ ។

ឯកឧត្តម Chen Shiqu បានកោតសរសើរដល់ថ្នាក់ដឹកនាំខេត្តព្រះសីហនុ ដែលបាន ដឹកនាំខេត្តព្រះសីហនុ ឱ្យមានការអភិវឌ្ឍរីកចម្រើនយ៉ាងលឿន ព្រមទាំងបានស្នើសុំ ដល់រដ្ឋ បាលខេត្តព្រះសីហនុជួយសហការក្នុង ការបង្ការបង្ក្រាបនូវបទល្មើសដែលបង្កឡើងដោយជនជាតិចិនមួយចំនួនតូចនៅខេត្ត ដោយចាត់វិធានការតាមផ្លូវច្បាប់ឱ្យបានតឹងរ៉ឹងបំផុត។ ឯកឧត្តម សង្ឃឹមថា នៅពេលអនាគតខេត្តព្រះសីហនុ នឹងមានកំណើនវត្តមានជនជាតិចិន មកធ្វើការវិនិយោគ និងទេសចរណ៍កាន់តែច្រើនបន្ថែមទៀត។

ឯកឧត្តម យន្ត មីន អភិបាលខេត្តព្រះសីហនុបានស្វាគមន៍ចំពោះគណៈប្រតិភូ នៃ ក្រសួងសន្តិសុខសាធារណៈចិន មកទស្សនកិច្ចឈ្វេងយល់ នៃការប្រយុទ្ធប្រឆាំងអំពើជួញដូរ មនុស្សនៅខេត្តព្រះសីហនុ។ ទន្ទឹមនេះ រដ្ឋបាលខេត្ត

ស្វាគមន៍អ្នកវិនិយោគ និងអ្នកទេសចរ មកពីគ្រប់ទិសទីលើពិភពលោក ប៉ុន្តែទាំងអ្នកទេសចរ និងអ្នកវិនិយោគ បញ្ហាសំខាន់ត្រូវតែ គោរពច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។ ឯកឧត្តម អភិបាលខេត្ត បានស្នើឱ្យតំណាងក្រសួងសន្តិសុខចិន ជួយជំរុញអ្នកវិនិយោគ និងទេសចរចិន ងាក មកចាប់អារម្មណ៍ក្នុងការមកធ្វើការវិនិយោគ និងកម្សាន្តខេត្តព្រះសីហនុ ដោយរដ្ឋបាលខេត្តធានាសន្តិសុខ សុវត្ថិភាពចំពោះអ្នកវិនិយោគ និងភ្ញៀវទេសចរ៕ ដោយ ងួ សុមុនី

## សេវាផ្លូវភេទដឹងតែបង្កប់ក្នុងហ្វឹងតែម្តង

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១៨ ម៉ោង ១៦:៣១ ដោយ ពិសម័យ

ខេត្តបាត់ដំបង ៖ មន្ត្រីការិយាល័យជំនាញនៃស្នងការខេត្តបានឲ្យដឹងថា ស្ត្រីមេការ និងថៅកែហាងកោសជប់ដែលបង្កប់សេវាបម្រើផ្លូវភេទចំនួន៤នាក់នឹងត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការនៅថ្ងៃទី១៥ ឧសភានេះ ខណៈអ្នកពាក់ព័ន្ធទាំង៣ភេទជាង៥០នាក់ទៀតត្រូវបានដោះលែងវិញ ក្រោយពីធ្វើកិច្ចសន្យា និងធ្វើការអប់រំ ។ បើយោងតាមសេចក្តីរាយការណ៍បានឲ្យដឹងថា ក្រុមដែលប្រព្រឹត្តសេវាផ្លូវភេទនេះត្រូវបានបង្ក្រាបនៅតាមបណ្តាហាងកោសជប់ ហាងម៉ាស្សា និងនៅតាមសួនច្បារសាធារណៈ នៅក្នុងក្រុងបាត់ដំបង កាលពីវេលារំលងអធ្រាត្រឈានចូលថ្ងៃទី១៤ ឧសភានេះ ។

ស្នងការរងខេត្តលោកកុយ ហ៊ាងបានឲ្យដឹងថា ក្រុមខាងលើត្រូវកម្លាំងជំនាញរបស់ស្នងការខេត្តចុះបង្ក្រាបបានមួយចំនួននៅតាមហាងកោសជប់ ហាងម៉ាស្សានានា ដែលមានបង្កប់សេវាបម្រើផ្លូវភេទ និងមួយចំនួនទៀតបង្ក្រាបនៅតាមសួនច្បារសាធារណៈដែលរង់ចាំបម្រើសេវាដូចគ្នា ។ ប៉ុន្តែក្រុមក្មេងទំនើងមួយចំនួនក៏ត្រូវបង្ក្រាបបានជាមួយនឹងក្រុមស្ត្រីបម្រើ សេវាផ្លូវភេទនៅតាមសួនច្បារ និងនៅកន្លែងម៉ាស្សាកោសជប់នេះដែរ ។ គេនៅមិនទាន់មានរបាយការណ៍ជាក់លាក់អំពីទីតាំងម៉ាស្សា និងកោសជប់នេះនៅឡើយទេ ។

បើតាមប្រភពព័ត៌មានបានឲ្យដឹងថា ទីតាំងទាំងនេះសុទ្ធតែដាក់ស្លាកឃីហោកោសជប់ និងម៉ាស្សា តែជាគុពិតសុទ្ធតែបង្កប់សេវាបំរើផ្លូវភេទ ។ បច្ចុប្បន្នសេវាបម្រើផ្លូវភេទជ្រកក្រោមស្លាកកោសជប់ ឬម៉ាស្សាទាំងនេះកំពុងរីកដូចផ្សិត នៅក្នុងក្រុងបាត់ដំបង ។

បើតាមលោកកុយ ហ៊ាង ស្នងការរងខេត្តបានបញ្ជាក់ថា មានតែមេការ និងថៅកែស្រីចំនួន៤នាក់ប៉ុណ្ណោះ ដែលនឹងត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការ ក្រៅពីនេះមនុស្សទាំង៣ភេទចំនួន៥៤នាក់ ត្រូវលោកស្នងការខេត្ត និងលោកព្រះរាជអាជ្ញាបញ្ជាឲ្យធ្វើកិច្ចសន្យាបញ្ឈប់សកម្មភាពទុច្ចរិតនេះ ហើយធ្វើការអប់រំឲ្យត្រូវទៅផ្ទះវិញ ៕

## ក្រុមការងារមូលនិធិ LPN ប្រទេសថៃ ជូនដំណើរពលករកម្ពុជាចំនួន០៣នាក់ ទៅស្រុកកំណើតរបស់ខ្លួនវិញ

http://www.pheaktraprak.com May 15, 2018

នៅថ្ងៃអង្គារ ទី១៥ ខែឧសភា ឆ្នាំ២០១៨ តំណាង លោក Som Pong Srakaew ប្រធានមូលនិធិ LPN ប្រទេសថៃ ដឹកនាំដោយលោក Samak Tubtanee បានធ្វើដំណើរជូនពលករកម្ពុជាចំនួន០៣នាក់ ដែលរងគ្រោះដោយសារការជួញដូរមនុស្ស បន្ទាប់ពីនៅធ្វើការក្នុងរោងចក្រផលិតទឹកកក មួយកន្លែងស្ថិតនៅស្រុកបាងសុីមឿង ខេត្តមុនដាក់បុរីកាលពីចុងខែកុម្ភៈឆ្នាំ២០១៨កន្លងទៅ។ បច្ចុប្បន្នពលករកម្ពុជាដែលរងគ្រោះទាំង០៣នាក់ត្រូវបានក្រុមការងារមូលនិធិ LPN ប្រទេសថៃជូនដំណើរទៅកាន់ស្រុកកំណើតរបស់ខ្លួនវិញតាមរយៈច្រកព្រំដែនអន្តរជាតិប៉ោយប៉ែត រួចធ្វើដំណើរបន្តទៅកាន់ខេត្តកំពុងឆ្នាំងដែលជាស្រុក កំណើតរបស់ពលករកម្ពុជាទាំង០៣នាក់ ប្រកបដោយសុវត្ថិភាព។ ក្នុងនោះលោក Samak Tubtanee តំណាងឱ្យលោក SomPong Srakaew ប្រធានមូលនិធិ LPN ប្រទេសថៃ បានប្រគល់ថវិកាមួយចំនួនជូនដល់ក្រុមគ្រួសារពលករកម្ពុជា ទាំង០៣នាក់ ព្រមទាំងទទួលទានអាហារថ្ងៃត្រង់ជាមួយក្រុមគ្រួសារពលករកម្ពុជាផងដែរ។ ប្រភពពី÷Samak Tubtanee

## ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៨

## នាយឧត្តមសេនីយ៍ សុខ ផលៈ ពលករបរទេសមកធ្វើប័ណ្ណការងារ សម្រាប់ឆ្នាំ២០១៨ មាន ជាង៣ម៉ឺននាក់ ដើម្បីបំពេញភាពស្របច្បាប់នៅកម្ពុជា

http://www.freshnewsasia.com/ 2018-05-17

**(ភ្នំពេញ)៖** នាយឧត្តមសេនីយ៍ សុខ ផល អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៅព្រឹកថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៨នេះ បានឲ្យដឹងថា ពលករបរទេសដែលគ្មានប័ណ្ណការងារ នៅឆ្នាំ២០១៧ បានមកធ្វើប័ណ្ណការងារ សម្រាប់ឆ្នាំ២០១៨ មានចំនួន៣១,៥៩៨នាក់ ដើម្បីបំពេញភាពស្របច្បាប់ ពេលកំពុងធ្វើការនៅប្រទេសកម្ពុជា។

ការលើកឡើងបែបនេះ ត្រូវបានធ្វើឡើងក្នុងឱកាស នាយឧត្តមសេនីយ៍ សុខ ផល ប្រគល់រថយន្តស៊ីរ៉ែន៨គ្រឿង ជូននាយកដ្ឋានជនបរទេសអន្តោប្រវេសន៍ ជាអ្នកវិនិយោគឯកជន សម្រាប់ចុះអធិការកិច្ចត្រួតពិនិត្យហត្ថពលកម្មបរទេស ទាំង២៥ រាជធានី-ខេត្ត។ បើតាមនាយឧត្តមសេនីយ៍ សុខ ផល ឆ្នាំ២០១៧នាយកដ្ឋានជំនាញ បានត្រួតពិនិត្យចំនួន៣,៩៦៩គោលដៅ មានពលករបរទេសចំនួន៣២,៩១២នាក់ និងមានទិន្នន័យធ្វើប័ណ្ណការងារចំនួន៥៧,០០០នាក់ ព្រមទាំងចំនួនធ្វើប័ណ្ណការងារ (គិតត្រឹមថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៨) ក្នុងនោះ មានប័ណ្ណការងារឆ្នាំ២០១៧ ពន្យាប័ណ្ណការងារឆ្នាំ២០១៨ មានចំនួន៣៣,៧៥២នាក់។ នៅព្រឹកមិញនេះ នាយឧត្តមសេនីយ៍អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក៏បានបង្ហាញពីតួរលេខ នៃការប្រៀបធៀប ចំនួនគោលដៅ ចំនួនពលករបរទេស ចំនួនពលករបរទេសផាកពិន័យ និងទិន្នន័យពលករបរទេសធ្វើប័ណ្ណការងារ និងសៀវភៅការងារ (ឆ្នាំ២០១៤, ឆ្នាំ២០១៥, ឆ្នាំ២០១៦, និងគិតត្រឹមថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧)។

ដោយក្នុងនោះ ឆ្នាំ២០១៤ គោលដៅបានត្រួតពិនិត្យ មានចំនួន១,៦០៤គោលដៅ មានពលករបរទេស ចំនួន១២,០៧២នាក់ និងទិន្នន័យធ្វើប័ណ្ណការងារ មានចំនួន៤,០០០នាក់ និងក្នុងឆ្នាំ២០១៥ គោលដៅបានត្រួតពិនិត្យចំនួន២,៦៦៥គោលដៅ មានពលករបរទេស ចំនួន១៨,៨៣៦នាក់ ទិន្នន័យធ្វើប័ណ្ណការងារ មានចំនួន៣០,៩២៨នាក់។ ក្នុងឆ្នាំ២០១៦ គោលដៅបានត្រួតពិនិត្យ មានចំនួន៣,៥៥២គោលដៅ មានពលករបរទេស ចំនួន២៧,០៩១នាក់ និងទិន្នន័យធ្វើប័ណ្ណការងារ មានចំនួន៣៩,១២០នាក់៕

## ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៨

## ក្រុមការងារទីប្រឹក្សាទទួលបន្ទុកពលករកម្ពុជា ប្រចាំប្រទេសថៃ ចុះសួរសុខទុក្ខពលការិនី ខ្មែរ០២រូប ដែលកំពុងសម្រាកនៅមន្ទីរពេទ្យ ក្នុងខេត្តឈុនបុរី

http://www.pheaktraprak.com/ May 12, 2018

កាលពីថ្ងៃសុក្រទី១១ ខែឧសភា ឆ្នាំ២០១៨ ក្រុមការងារទីប្រឹក្សាទទួលលបន្ទុកពលករ តំណាងអោយឯកឧត្តមឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃ បានចុះសួរសុខទុក្ខពលការិនីកម្ពុជា ចំនួន០២រូប ដែលកំពុងសម្រាលកូននៅមន្ទីរពេទ្យបាងឡាមុង ខេត្តឈុនបុរី ដែលបានសម្រាលកូននៅមុខប៉ុស្តិ៍ប៉ូលីសថៃ ស្ថិតក្នុងខេត្តឈុនបុរី ដោយសារតែទៅមន្ទីរពេទ្យមិនទាន់។ បច្ចុប្បន្ន ទាំងម្តាយ និងទារកមានសុខភាពល្អ និងកំពុងសម្រាកនៅមន្ទីរពេទ្យ ដោយថ្លៃសម្រាកព្យាបាល គឺផ្នែកធានារ៉ាប់រងសុខភាពថៃ ជាអ្នកទទួលបន្ទុកដោយសារតែពលករមានឯកសារគ្រប់គ្រាន់ និងបានចូលក្នុងប្រពន្ធ័ធានារ៉ាប់រងសុខភាពរបស់ប្រទេសថៃ។ ជាមួយគ្នានេះដែរក្រុមការងារក៏បានពាំនាំនូវថវិកាមួយចំនួនជូនដល់ប្អូនស្រីរូបនោះផងដែរ។

ចំណែកឯពលការិនីម្នាក់ទៀត ដែលកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យសម្តេចរាចថេរី ស្រុកស៊ីរាចថា បន្ទាប់ពីកើតឧបទ្ទវហេតុកៀបម្រាមដៃនិងម៉ាស៊ីនកិនម្សៅនំប៉័ង កិនដៃក្នុងពេលបំពេញការងារ។ ក្រុមការងារបានទំនាក់ទំនងទៅ

និយោជក និងអាជ្ញាធរថៃដើម្បីជួយសម្របសម្រួលអោយភាគីនិយោជកក៏ដូចជាផ្នែកជានាប់បង់សង្គមរបស់ថៃផ្តល់នូវសំណងតាមច្បាប់របស់ប្រទេសថៃនិងបានពាំនាំនូវថវិកាមួយចំនួនជូនដល់ប្អូនស្រីរូបនោះផងដែរ។

### ខ្មែរ៤នាក់ និងជាតិសាសន៍ផ្សេងទៀត ត្រូវអាជ្ញាធរថៃឃាត់ខ្លួន នៅថ្ងៃ១៧ឧសភា

http://kleykley.sabay.com.kh/ ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៨ ម៉ោង 15:02

សមត្ថកិច្ចថៃ បានធ្វើការចុះឃាត់ខ្លួនជនបរទេសចំនួន ៣៦នាក់ រួមទាំងជនជាតិខ្មែរ ៤នាក់ នៅព្រឹកថ្ងៃព្រហស្បតិ៍ ទី១៧ ខែឧសភានេះ នៅទីតាំងចំនួន ១០៤កន្លែង ក្នុងប្រទេសថៃ ដែលពួកគេបានឆ្លងដែនចូលទៅកាន់ប្រទេសថៃដោយខុសច្បាប់ ស្នាក់នៅលើសពីសុពលភាពទិដ្ឋាការជាដើម។ ការឃាត់ខ្លួននេះ បានធ្វើឡើងនៅទីតាំងមួយចំនួននៅក្រុងបាងកក ព្រមទាំងតំបន់ទេសចរណ៍នៅខេត្ត ពូកេត ឈុនបូរី សុងក្លា និងឈៀងម៉ៃ។ ចំណែកអ្នកដែលត្រូវឃាត់ខ្លួន មានមួយចំនួនជានិស្សិតបរទេស។ ក្រៅពីជនជាតិខ្មែរ ៤នាក់ នៅមានជនជាតិ អាល់ហ្សេរីម្នាក់ ឥណ្ឌា៦នាក់ មីយ៉ាន់ម៉ា ៧នាក់ និងឡាវ ៩នាក់ ដែលពាក់ព័ន្ធនឹងការឆ្លងដែនខុសច្បាប់។ រីឯជនសង្ស័យ៦នាក់ ដែលមកពី ស្វីស រុស្ស៊ី សេណេហ្គាល់ ឥណ្ឌា វៀតណាម និងកូឌីវ័រ ត្រូវចោទពីបទស្នាក់នៅលើសពីសុពលភាពទិដ្ឋាការ។ ចំណែក ៤នាក់ទៀត មាន មីយ៉ាន់ម៉ា ២នាក់ ឥណ្ឌាម្នាក់ និងថៃម្នាក់ ត្រូវចោទពីករណីផ្សេងៗទៀត។

លោកមេបញ្ជាការ Surachate បានឲ្យដឹងថា ការចុះឃាត់ខ្លួននេះ ជាប្រតិបត្តិការជំណាក់កាលទី១១ នៃការបង្ក្រាបជនបរទេសខុសច្បាប់ (X-Ray Outlaw Foreigner) ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើឧក្រិដ្ឋកម្ម ដែលបង្កឡើងដោយជនបរទេសឆ្លងដែនចូលទៅក្នុងប្រទេសថៃ។

សូមជម្រាបថា មកទល់ពេលនេះ ប្រតិបត្តិការខាងលើបានឃាត់ខ្លួនជនសង្ស័យបាន ១១៦១នាក់ ពីទីតាំង ៣៤៧៤កន្លែង នៅជុំវិញប្រទេសថៃ។ កាលពីដើមខែឧសភានេះ ជនជាតិខ្មែរ ១០នាក់ ត្រូវឃាត់ខ្លួនដោយសមត្ថកិច្ចថៃពីបទឆ្លងដែនខុសច្បាប់ផងដែរ៕ ប្រភព៖ Bangkokpost ប្រែសម្រួល៖ លាភ.

## ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៨

### “បច្ចុប្បន្នបញ្ហាពលករកម្ពុជាចំណាកស្រុក កំពុងត្រូវបានស្នើនយោបាយ ដើម្បីកែបញ្ហាដោះស្រាយ រឿងជួញដូរមនុស្ស និងបញ្ហាស្វែងរកផលប្រយោជន៍ពីពលករចំណាក់ស្រុក”

http://www.pheaktraprak.com/ May 19, 2018

“បច្ចុប្បន្នបញ្ហាពលករកម្ពុជាចំណាកស្រុកកំពុងត្រូវបានស្នើនយោបាយ ដើម្បីកែបញ្ហាដោះស្រាយ រឿងជួញដូរមនុស្ស និងបញ្ហាស្វែងរកផលប្រយោជន៍ពីពលករចំណាកស្រុក” ស្ថានភាពបញ្ហាពលករកម្ពុជា បច្ចុប្បន្នកំពុងរងការស្វែងរកផលប្រយោជន៍ពីពលករ និងរងការបង្ខិតបង្ខំអោយធ្វើការ និងអំពើជួញដូរមនុស្សខុសច្បាប់នៅក្នុងប្រទេសថៃ ។

យោងតាមរបាយការណ៍របស់ ” មូលនិធិលើកស្ទួយសិទ្ធិសេរីភាពពលករប្រទេសថៃ LPN ” ក្នុងរយៈពេល០២ឆ្នាំកន្លងមក មានពលករកម្ពុជា ជាច្រើននាក់បានចូលមកស្វែងរកការងារធ្វើនៅក្នុងប្រទេសថៃ ទាំងចូលមកជាលក្ខណៈស្របច្បាប់ឬហៅថា MOU និងចូលមកបែបលក្ខណៈខុសច្បាប់ ហើយត្រូវបានរងគ្រោះ ការរំលោភបំពនសិទ្ធិសេរីភាពការងារ ព្រមទាំងការបង្ខិតបង្ខំ កំរាមកំហែង ផ្លូវកាយផ្លូវចិត្ត ពីអំពើជួញដូរមនុស្សខុសច្បាប់ ដូចជាករណី ដាក់ស្ដែងពលករធ្វើកានេសាទត្រីនៅលើផ្ទៃទឹកថៃ ,ករណីធ្វើការក្នុងរោងចក្រផលិតទឹកកក និងការងារទូទៅផ្សេងទៀត ដោយខ្លះទៀតរងការរំលោភបំពានផ្លូវភេទ និងរងការធ្វើទារុណកម្មផ្លូវកាយផ្លូវចិត្ត ព្រមទាំងរងការបោកប្រាស់ប្រាក់កាសពីសំណាក់អ្នកស៊ីឈ្នួលរត់ឯកសារ ឬធ្វើប៉ាស្ព័រស្របច្បាប់ និងត្រូវនាំទៅធ្វើការនៅកន្លែងដែលពលករមិនបានយល់ព្រមតាំងពីដំបូង។

រយៈកន្លងមកបណ្តាញមូលនិធិលើកស្ទួយកម្ពស់សិទ្ធិសេរីភាពពលករប្រទេសថៃ LPN តែងតែគិតថា ទោះបីជារាជរដ្ឋាភិបាលថៃ មាននយោបាយពង្រឹងការចុះបញ្ជីឈ្មោះពលករអោយស្របច្បាប់ និងបញ្ជាក់អត្តសញ្ញាណពលករឲ្យ

ច្បាស់លាស់ និងការនាំចូលពលករបែប MOU ដោយមានភាពតឹងរឹងជាងមុន ដើម្បីទប់ស្កាត់បញ្ហាពលករចំណាកស្រុកខុសច្បាប់ និងចុះត្រួតពិនិត្យតាមរោងចក្រសហគ្រាសកែច្នៃគ្រឿងសមុទ្រ និងបណ្តាញការងារផ្សេងទៀតអោយកាន់តែរឹងបំផុត ។ ប៉ុន្តែយ៉ាងក៏ដោយពលករចំណាកស្រុកកម្ពុជាចំនួនមិនតិចនោះទេ ដែលរងការកេងប្រវ័ញ្ចកម្លាំង ញើសឈាមពីការងារ និងមិនទទួលបានប្រាក់ឈ្នួលតាមគោលការណ៍រដ្ឋកំណត់ ដោយខ្លះទៀតរងការជំរិតទាប្រាក់ ដោយមិនហានរាយការណ៍ ឬប្តឹងភ្នាក់ងាររដ្ឋអោយជួយអន្តរាគមន៍ និងអង្គការសង្គមស៊ីវិលធ្វើការងារនោះទេ។ ស្ថានភាពទាំងអស់នេះហើយ គឺជាចំណោទយ៉ាងសំខាន់មួយ ដែលត្រូវដោះយ៉ាងណា ដើម្បីអោយពលករទាំងអស់នោះទទួលបាននៅសិទ្ធិការពារ ព្រមទាំងទទួលយកចិត្តទុកដាក់ដោយភាពសុក្រឹត និងយុត្តិធម៌ ត្រឹមត្រូវនាពេលអនាគត។

នៅឆ្នាំ២០១៦-២០១៧ ស្ថិតិចំនួនពលករកម្ពុជា ដែលរងគ្រោះនិងជួបប្រទះបញ្ហា ត្រូវបានមូលនិធិលើកស្ទួយសិទ្ធិសេរីភាពពលករ ប្រទេសថៃ LPN ជួយអន្តរាគមន៍ដោយមានការ សហការរួមគ្នាជាមួយរាជរដ្ឋាភិបាលថៃ និងរាជរដ្ឋាភិបាលកម្ពុជា អង្គការសហប្រតិបត្តិការអន្តរជាតិ មានចំនួនដូចតទៅនេះ៖ ជនរងគ្រោះដោសាការជួញដូរមនុស្ស ចំនួន ៨៣នាក់ ,ពលកររងគ្រោះដោយសារមានបញ្ហារឿងប្រាក់ខែ ចំនួន ២៤នាក់ ,ពលកររងគ្រោះថ្នាក់ពីការងារ ចំនួន ០១នាក់, ពលករដែលរងគ្រោះបញ្ហាផ្លូវភេទ ចំនួន ០៩នាក់ ,ពលករដែលមានបញ្ហារឿងសុខភាពចំនួន១៨នាក់ ,និងកុមារកម្ពុជាដែលទទួលរងគ្រោះការប្រើអំពើហឹង្សា និងមិនមានលទ្ធភាពក្នុងប្រព័ន្ធសិក្សាអប់រំ ចំនួន ៤០០នាក់ ។

## បុរសពលករខ្មែរម្នាក់,ធ្លាក់ពីលើដំបូលផ្ទះស្លាប់ទាំងព្រឹក

http://www.pheaktraprak.com/ May 19, 2018

នៅវេលាម៉ោង០៩ព្រឹក ថ្ងៃសុក្រ ទី១៨ ខែឧសភា ឆ្នាំ២០១៨ មានករណីបុរសពលករខ្មែរម្នាក់ ឈ្មោះ ធឿន ប៊ុនថន ស្រុកកំណើត រស់នៅស្រុកត្រាំកក់ ខេត្តតាកែវ ប្រទេសកម្ពុជា បច្ចុប្បន្នធ្វើការនៅក្នុងខេត្តឈុនបុរី ប្រទេសថៃ បានរងគ្រោះស្លាប់បាត់បង់ជីវិតដោយសារធ្លាក់ពីលើដំបូលផ្ទះ បណ្តាលឲ្យស្លាប់ភ្លាមនៅកន្លែងកើតហេតុ ។ បច្ចុប្បន្នសាកសពជនរងគ្រោះត្រូវបានសមត្ថកិច្ចថៃយកទៅរក្សាទុកនៅមន្ទីរពេទ្យ ដើម្បីរង់ចាំប្រគល់ជូនសាច់ញាតិអោយយកទៅធ្វើបុណ្យតាមប្រពៃណី។

## ខែមិថុនា ស្ត្រីខ្មែរ៣០០នាក់ នឹងចេញទៅបម្រើការងារតាមផ្ទះ នៅប្រទេសអាស៊ាន១

http://kleykley.sabay.com.kh/ ថ្ងៃសៅរ៍, 19 ឧសភា 2018 16:35

នៅខែមិថុនា ឆ្នាំ២០១៨ខាងមុខនេះ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងបញ្ជូនស្ត្រីខ្មែរ ដែលជាពលការិនី ទៅធ្វើការជាស្ត្រីបម្រើតាមផ្ទះ នៅប្រទេសម៉ាឡេស៊ីឡើងវិញ។ ពលការិនីកម្ពុជាទាំងនោះ មានប្រមាណ ៣០០នាក់។ កាលពីដើមខែកុម្ភៈ ឆ្នាំ២០១៨ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងធនធានមនុស្សរបស់ប្រទេសម៉ាឡេស៊ី បានចុះកិច្ចព្រមព្រៀង ពាក់ព័ន្ធនឹងការបញ្ជូន និងទទួលពលការិនី ដែលតម្រូវឲ្យចូលរួមវគ្គបណ្តុះបណ្តាល និងកិច្ចការពារស្ត្រីខ្មែរទាំងនោះ។ តាមរយៈកិច្ចព្រមព្រៀងថ្មីនេះ ស្ត្រីខ្មែរ ដែលនឹងត្រូវបញ្ជូនទៅបម្រើតាមផ្ទះនៅប្រទេសម៉ាឡេស៊ី នឹងមានចំនួន ៥ម៉ឺននាក់ ក្នុងមួយឆ្នាំ។

សូមរំឭកថា កម្ពុជា បានសម្រេចផ្អាក មិនបញ្ជូនស្ត្រីបម្រើតាមផ្ទះ ទៅប្រទេសម៉ាឡេស៊ី កាលពីខែតុលា ឆ្នាំ២០១១ បន្ទាប់ពីមានករណីរំលោភបំពាន រហូតបណ្តាលឲ្យស្ត្រីខ្មែរ ស្លាប់ជាច្រើននាក់ ក្នុងពេលបំពេញការងារនៅទីនោះ។ ការបញ្ជូនពលករកម្ពុជា ទៅធ្វើការនៅម៉ាឡេស៊ី បានចាប់ដំណើរការតាំងពីឆ្នាំ១៩៩៨ នៅក្រោយពេលដែលរាជរដ្ឋាភិបាលកម្ពុជា ទទួលបានការអនុញ្ញាតពីរដ្ឋាភិបាលម៉ាឡេស៊ី ក្នុងខែតុលា ឆ្នាំ១៩៩៦។ ចាប់ពីពេលនោះមក ចំនួន

ពលករ ដែលស្ទើរតែទាំងអស់ ជាស្ត្រី ត្រូវបានក្រុមហ៊ុនទីភ្នាក់ងារជ្រើសរើសពលករទៅធ្វើការនៅក្រៅប្រទេស បានបញ្ជូនទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ដោយមានការកើនឡើងជាបន្តបន្ទាប់។

រហូតមកដល់ខែឧសភា ឆ្នាំ២០១៨ ពលករខ្មែរ ដែលបានបញ្ជូនទៅធ្វើការនៅប្រទេសម៉ាឡេស៊ី មានចំនួនជាង ៤៦ ម៉ឺននាក់ ក្នុងនោះ មានស្ត្រីជាង ៤០ម៉ឺននាក់។ រីឯចំនួនស្ត្រីខ្មែរ ធ្វើការងារតាមផ្ទះនៅប្រទេសម៉ាឡេស៊ី មានជិត ៣៤ ម៉ឺននាក់។ នេះបើតាមរបាយការណ៍របស់ក្រសួងការងារ៕ អត្ថបទ៖ លីហៀង

## សមត្ថកិច្ចបញ្ជូនខ្លួនមេខ្យល់ នាំនារីខ្មែរទៅប្រទេសចិន ២នាក់បងប្អូនប្រុស-ស្រី ទៅតុលាការ

http://bayontv.com.kh/ ថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០១៨

ភ្នំពេញ៖ ជនសង្ស័យប្រុស-ស្រីទាំង២នាក់បងប្អូន ត្រូវបានកម្លាំងនគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បញ្ជូនខ្លួនទៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការ តាមនីតិវិធី នៅព្រឹកថ្ងៃទី២១ ខែ ឧសភា ឆ្នាំ២០១៨នេះ។

គួររំលឹកផងដែរ កាលពីវេលាម៉ោង៨ព្រឹក ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៨ តាមបណ្តោយផ្លូវ២៧១ ស្ថិតក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កម្លាំងនគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ចុះប្រតិបត្តិការបង្ក្រាប និងឃាត់ខ្លួនជនសង្ស័យប្រុស-ស្រី២នាក់ ដែលជាមេខ្យល់ និងរំដោះជនរងគ្រោះបាន ២នាក់ ដែលជាប់ពាក់ព័ន្ធទៅ នឹងករណីជួញដូរមនុស្សឆ្លងដែនពីប្រទេសកម្ពុជា ទៅប្រទេសចិន។ ប្រតិបត្តិការនេះ ដោយមានការចង្អុលបង្ហាញពីឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គស្នងការង និងមានការសម្របសម្រួល ពីលោក គុជ គីមឡុង ព្រះរាជអាជ្ញារង អយ្យកា អមសាលាដំបូងរាជធានីភ្នំពេញ និងមានការបញ្ជាផ្ទាល់ដោយ លោក ឧត្តមសេនីយ៍ត្រី ចាន់ កិត្តិខុម ស្នងការរងទទួលផែនប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

ជនសង្ស័យប្រុសស្រីមានឈ្មោះ ទី១ ឈ្មោះ ទេព ជី ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ ស្នាក់នៅ ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង។ ឃាត់ខ្លួននៅចំណុចហាងការហ្វេ ស្ថិតក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ ជនសង្ស័យទី២ ឈ្មោះ ទេព សុគន្ធ ភេទស្រី ៣៨ឆ្នាំ ជនជាតិខ្មែរ ស្នាក់នៅស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង។ ឃាត់ខ្លួនចំណុចមុខរោងចក្រ ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ សូមបញ្ជាក់ផងដែរ ជនសង្ស័យប្រុសស្រី២នាក់ត្រូវជាបងប្អូនបង្កើត និងមានជនសង្ស័យម្នាក់ទៀតត្រូវជាបងប្អូនជាជនសង្ស័យទាំង២នាក់ ដែរ គឺរស់នៅប្រទេសចិនតែម្តង ឈ្មោះ ទេព សាលី។

តាមប្រភពព័ត៌មាន អោយដឹងថា នៅមុនពេលឈានដល់ការឃាត់ខ្លួនជនសង្ស័យប្រុសស្រីទាំង២នាក់ កម្លាំងនគរបាលនៃការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានធ្វើការស្រាវជ្រាវតាមជំនាញ អស់រយៈពេលជាច្រើនថ្ងៃ រហូតដល់ថ្ងៃទី១៩ខែឧសភា ឆ្នាំ២០១៨ ទើបចុះប្រតិបត្តិការខ្លួនជនសង្ស័យទាំង២នាក់បងប្អូន នៅទីតាំងផ្សេងគ្នាដែរម្តង។ តាមប្រភពព័ត៌មាននារីរងគ្រោះ បានរាប់រៀបប្រាប់ថា កាលពីថ្ងៃបុណ្យចូលឆ្នាំ រូបនាង បានស្គាល់គ្នាជាមួយស្ត្រីម្នាក់ ឈ្មោះ ទេព សាលី ភេទស្រី អាយុ៣០ឆ្នាំ បានបបួលរូបនាងខ្ញុំអោយទៅប្រទេសចិន ងាយរកលុយ ហើយបើរូបនាងព្រមទៅ ពេលទៅដល់ប្រទេសចិន និងវេលុយអោយឪពុកម្តាយនាង៣៥០០ ដុល្លារតែម្តង ពេលនោះ រូបនាងថា ចាំគិតមើលសិន។ រយៈក្រោយមក ស្ត្រីឈ្មោះ ទេព សាលី បានទាក់ទងមក បញ្ចុះបញ្ចូលរាល់ថ្ងៃ ថាបើ ព្រមទៅប្រទេសចិន រូបគាត់នឹងថែមលុយអោយច្រើនយ៉ាងនេះទៀត ស្តាប់យូៗទៅ រូបភាព ក៏សម្រេចចិត្តថា ទៅព្រោះ គិត

ថាចង់បានលុយដើម្បីផ្ញើជូនឪពុកម្តាយ។ បន្ទាប់មកទៀត ពេលដែររូបនាងលើព្រមថាទៅ ស្ត្រីឈ្មោះ សាលី បានអោយប្អូនប្រុសរបស់គាត់ ឈ្មោះ ទេព ជី ទាក់ទងមកនាង ដើម្បីយកទៅធ្វើលិខិតឆ្លងដែន(ធ្វើ១ថ្ងៃយកតែម្តង តម្លៃ២៣០$)។

នគរបាល បានបញ្ជាក់ប្រាប់ថា ជនសង្ស័យ ដែលនគរបាលឃាត់ខ្លួនបាន មានគោលបំណងនាំនារីគ្រោះ ចេញទៅប្រទេសចិន តាមច្រកបាវិត ចូលប្រទេសវៀតណាម រួមឡើងយន្តហោះទៅប្រទេសចិនតែម្តង។ ចំណែកនារីរងគ្រោះ ត្រូវបានកម្លាំងនគរបាលប្រគល់ជូនសង្គមកិច្ចដើម្បីធ្វើការអប់រំ៕

## ពលករចំណាកស្រុកចំនួន៤រូប ចាញ់បោកមេខ្យល់ ទៅធ្វើការនៅប្រទេស ម៉ាឡេស៊ី រយៈពេល៤ឆ្នាំ រួមនិងកូនក្មេងម្នាក់ ត្រូវបានជួយសង្គ្រោះ

https://www.facebook.com/CentralCambodiaOrg/ ថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០១៨ CENTRAL

ពលករចំណាកស្រុកចំនួន៤រូប(ស្រី២ .កុមារី ) ចាញ់បោកមេខ្យល់ ទៅធ្វើការនៅប្រទេសម៉ាឡេស៊ី រយៈពេល៤ឆ្នាំ រួមនិងកូនក្មេងម្នាក់ ត្រូវបានជួយសង្គ្រោះដោយ អង្គការសង់ត្រាល់ សហការជាមួយស្ថានទូតកម្ពុជា ប្រចាំនៅប្រទេសម៉ាឡេស៊ី។ ពួកគាត់បានមកដល់ ព្រលានយន្តហោះអន្តរជាតិភ្នំពេញ កាលពីព្រឹកថ្ងៃទី ២១ ឧសភា ២០១៨ ។

## ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨

## សម្តេចក្រឡាហោម ស ខេង៖ រាជរដ្ឋាភិបាលខិតខំការពារពលករខ្មែរពីការរំលោភបំពាន និង កេងប្រវ័ញ្ចគ្រប់រូបភាព

http://cambodiapolice.com/policekh/ 12:21 pm 22 ឧសភា 2018

**ភ្នំពេញ ៖** សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានលើកឡើងថា រាជរដ្ឋាភិបាលបានផ្តល់ភាពស្របច្បាប់ជូនពលករដែលបានកំពុងតែធ្វើការនៅប្រទេសថៃ និងបើកកន្លែងធ្វើលិខិតឆ្លងដែន និងប័ណ្ណអនុញ្ញាតការងារនៅទីតាំងសំខាន់ៗមួយចំនួន ឲ្យមានដំណោះស្រាយមួយក្នុងការការពារពលករពីការរំលោភបំពាន និងកេងប្រវ័ញ្ចគ្រប់រូបភាពពីពលករខុសច្បាប់។

ថ្លែងក្នុងឱកាសអញ្ជើញជាអធិបតីភាពនៅក្នុងពិធីផ្សព្វផ្សាយ របាយការណ៍បូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៧ និងទិសដៅអនុវត្តឆ្នាំ២០១៨ នៅព្រឹកថ្ងៃទី២២ ខែឧសភានេះ នៅក្រសួងមហាផ្ទៃ។ សម្តេចក្រឡាហោមបានលើកឡើងថារាជរដ្ឋាភិបាលកម្ពុជាបានធ្វើកិច្ចការងារជាច្រើន ដោយប្រឹងប្រែងជាមួយសហគមន៍អន្តរជាតិ និងប្រទេសពាក់ព័ន្ធដោយពង្រឹងកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល និងអង្គការដៃគូសង្គមស៊ីវិល វិស័យឯកជន និងបង្កើតឱកាសការងារ និងខិតខំការពារផលប្រយោជន៍ដល់ពលករខ្មែរទាំងក្នុងនិងក្រៅប្រទេស និងខិតខំការពារពីការរំលោភបំពាននិងកេងប្រវ័ញ្ចគ្រប់រូបភាព។

បើតាមរបាយការណ៍ដែលបានចែកជូនដល់អ្នកសារព័ត៌មានបានឲ្យដឹងថា នាពេលបច្ចុប្បន្ននេះមានគឺមានពលករខ្មែរជាងមួយលាននាក់កំពុងធ្វើការនៅប្រទេសថៃ ហើយក្នុងនោះជាង៣០ភាគរយគឺស្របច្បាប់និងមានឯកសារត្រឹមត្រូវស្របតាមកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលកម្ពុជានិងរដ្ឋាភិបាលថៃ។

លោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបញ្ជាក់ថា អាជ្ញាធរថៃបានបញ្ជូនពលករខ្មែរត្រឡប់មកកម្ពុជាវិញ ក្រោមរូបភាពនិរទេសតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត សរុបមានចំនួន ៧៣.២៧៥នាក់ ស្រី២៥.៥៨០នាក់។ ចំណែកខេត្តបាត់ដំបង បានទទួលពលករខ្មែរពីអាជ្ញាធរថៃ មានចំនួន ៥៦.៧២០នាក់ ស្រី២៥.២៥០នាក់។ រីឯខេត្តប៉ៃលិនទទួលពលករខ្មែរពីអាជ្ញាធរថៃ មានចំនួន ១.២៤៦នាក់ ស្រី ៥១៧នាក់៕

# ក្រុមហ៊ុនឯកជនចំនួន៨៥ ធ្វើការជ្រើសរើសបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេសជាង៤ ម៉ឺននាក់

http://www.rasmeinews.com/ May 22, 2018, 9:33 AM

ដោយៈ មុនីរ័ត្ន / ភ្នំពេញៈ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អញ្ជើញជាអធិបតីភាពនៅក្នុងពិធីផ្សព្វផ្សាយរបាយការណ៍ បូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៧ និងទិសដៅអនុវត្តឆ្នាំ២០១៨ នៅព្រឹកថ្ងៃទី២២ ខែឧសភានេះ នៅក្រសួងមហាផ្ទៃ។

លោកស្រី ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបញ្ជាក់ថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអនុញ្ញាតអោយក្រុមហ៊ុនឯកជនចំនួន៨៥ ធ្វើការជ្រើសរើសបញ្ជូនពលករទៅធ្វើការដោយស្របច្បាប់នៅក្រៅប្រទេស និងតាមប្រព័ន្ធអនុគ្រោះមុខរបរ (EPS) របស់រដ្ឋាភិបាលបានចំនួន ៤៥.៧៩៧នាក់ (ស្រី១៨.២៨០នាក់) ក្នុងនោះក្រុមហ៊ុនចំនួន៨៥ក្រុមហ៊ុន បានជ្រើសរើសនិងបញ្ជូនពលករទៅធ្វើការដោយស្របច្បាប់ នៅក្រៅប្រទេសសរុបចំនួន៣៨.១៣៦នាក់ (ស្រីចំនួន១៦.៤៨នាក់) និងបញ្ជូនទៅប្រទេសថៃ ៣៥.៦៧៤នាក់ ស្រី១៥.០៨០នាក់។ ជប៉ុន ២.២៨០នាក់ ស្រី១.២៤១។ សឹង្ហបុរី ១៣៨នាក់ (ស្រី)។ ម៉ាឡេស៊ី២៧នាក់។ អារ៉ាប់ប៊ីសាអូឌីត ចំនួន១២នាក់ (ស្រី)។ តំបន់រដ្ឋបាលពិសេសហុងកុង ចំនួន៥នាក់ (ស្រី)។ រដ្ឋាភិបាលបានបញ្ជូនពលករ ទៅធ្វើការនៅប្រទេសកូរ៉េ តាមប្រព័ន្ធអនុគ្រោះមុខរបរចំនួន ៧.៦៦១នាក់ (ស្រី១.៧៩៧នាក់)៕

## ឆ្នាំ២០១៧ ពលករខ្មែរដែលស្លាប់នៅថៃ មានប៉ុន្មាននាក់?

http://kleykley.sabay.com.kh/ ថ្ងៃចន្ទ, ២២ ឧសភា ម៉ោង 11:39

លោកស្រី ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបញ្ជាក់ថា អាជ្ញាធរកម្ពុជាបានទទួលសពប្រជាពលរដ្ឋខ្មែរពីអាជ្ញាធរថៃចំនួន ២០៦លើក សរុបចំនួន ២១១នាក់ ក្នុងនោះស្រីចំនួន៤៣នាក់។ ការបញ្ជាក់នេះ នៅក្នុងពិធីផ្សព្វផ្សាយរបាយការណ៍បូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៧ និងទិសដៅអនុវត្តឆ្នាំ២០១៨ នៅព្រឹកថ្ងៃទី២២ ខែឧសភានេះ នៅទីស្តីការក្រសួងមហាផ្ទៃ។ លោកស្រីបានបន្តថា អាជ្ញាធរថៃបានបញ្ជូនពលករខ្មែរត្រឡប់មកកម្ពុជាវិញ ក្រោមរូបភាពនិរទេស តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតសរុបមានចំនួន ៧៣២៧៥ នាក់ ស្រី ២៥៥៨០នាក់។ ចំណែកខេត្តបាត់ដំបង បានទទួលពលករខ្មែរពីអាជ្ញាធរថៃ ចំនួន ៥៦៧២០នាក់ ស្រី ២៥២៥០នាក់។ រីឯខេត្តប៉ៃលិន ទទួលពលករខ្មែរពីអាជ្ញាធរថៃ ចំនួន ១២៤៦ នាក់ ស្រី ៥១៧នាក់៕ អត្ថបទ៖ សោភា

## កម្ពុជា-ថៃ បានរួមគ្នាផ្តល់ភាពស្របច្បាប់ ដល់ពលករកម្ពុជា ជាង៣០ម៉ឺននាក់ ក្នុងចំណោមពលករខុសច្បាប់៤០ម៉ឺននាក់ ដែលកំពុងបំរើការងារនៅប្រទេសថៃ

https://www.facebook.com/mlvt.gov.kh/ May 19, 2018 ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ផ្អែកលើកិច្ចសហប្រតិបត្តិការជាមួយគ្នា រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ លើវិស័យការងារ និង វិស័យអប់រំ បណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ ពិសេសស្ថិតក្នុងរយៈពេល នៃកិច្ចសហប្រតិបត្តិការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ភាគីទាំងពីរបានរួមគ្នាផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជាបានជាង៣០ម៉ឺននាក់រួចហើយ ក្នុងចំណោមពលករជាង៤០ម៉ឺននាក់ ដែលកំពុងបំរើការងារ ដោយខុសច្បាប់នៅក្នុងប្រទេសថៃ។

ឯកឧត្តម បណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានមានប្រសាសន៍ នៅក្រោយជំនួបពិភាក្សាការងារ ជាមួយ ឯកឧត្តម Panyarak Poolthup ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រថៃ ប្រចាំកម្ពុជា

នៅព្រឹកថ្ងៃទី២២ ខែឧសភានេះ នៅទីស្តីការក្រសួងថា ពលករកម្ពុជាដែលបំរើការងារ ដោយគ្មានឯកសារស្របច្បាប់ នៅក្នុងប្រទេសថៃ ពីមុនមកនោះ ឥឡូវនេះបានទទួលភាពស្របច្បាប់ជិតអស់ហើយ និងកំពុងបន្តធ្វើកិច្ចការនេះឱ្យបានរួចរាល់ នៅមុនដំណាច់ ខែ មិថុនា ឆ្នាំ២០១៨ខាងមុខនេះ។ ឯកឧត្តម បណ្ឌិតរដ្ឋមន្ត្រី បានមានប្រសាសន៍ទៀតថា កន្លងមកកម្ពុជា បានបញ្ជូនក្រុមការងារអន្តរក្រសួងជាង៣០០នាក់ ទៅកាន់មជ្ឈមណ្ឌលចំនួន០៣ នៅទីក្រុងបាងកក ខេត្ត បុទុមឋានី និងខេត្ត រ៉ាក់យ៉ង ប្រទេសថៃ ដើម្បីធ្វើកិច្ចសហប្រតិបត្តិការ ជាមួយភាគីថៃ ផ្តល់ភាពស្របច្បាប់ ដល់ពលករកម្ពុជា ដែលមកដល់ពេលនេះ អាចចាត់ទុកថាទទួលបានលទ្ធផលជោគជ័យ ពោលគឺនៅសេសសល់ខ្លះកំពុងបន្តនិតិវិធីផ្តល់ជូន។

យ៉ាងណា ឯកឧត្តម រដ្ឋមន្ត្រី ក៏បានបញ្ជាក់ទៀតថា នៅពាក់កណ្តាលខែមិថុនា ក្នុងឆ្នាំនេះ ឯកឧត្តម នឹងដឹកនាំគណប្រតិភូក្រសួងការងារ ទៅបំពេញទស្សនកិច្ចផ្លូវការនៅប្រទេសថៃ ដើម្បីពិនិត្យចុងក្រោយ និងដោះស្រាយបញ្ហាដែលនៅសេសសល់។ ក្រៅពីនេះក៏ខិតខំជម្រុញល្បឿន នៃកិច្ចសហប្រតិបត្តិការ លើ វិស័យ អប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក៏ដូចជាវិស័យដទៃទៀត ឱ្យបានល្អ និងមានប្រសិទ្ធភាព។

ទន្ទឹមគ្នានោះដែរ ឯកឧត្តម ឯកអគ្គរាជទូតថៃ ប្រចាំកម្ពុជា ក៏បានអបអរសាទរ ចំពោះការបើកច្រកទ្វារ អន្តរជាតិថ្មី របស់កម្ពុជា នៅខេត្តបាត់ដំបង ដើម្បីរំលែកការធ្វើដំណើរ ដោយស្របច្បាប់របស់ពលករកម្ពុជា ពីច្រកប៉ោយប៉ែតទៅតាមច្រកថ្មីនេះ ស្របតាមកិច្ចសហប្រតិបត្តិការ ដោយរលូន និងឈ្នះឈ្នះទៅវិញទៅមក៕

## ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨

## រដ្ឋមន្ត្រីក្រសួងមហាផ្ទៃជំរុញឱ្យគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ត្រូវបន្តពង្រឹងទប់ស្កាត់គ្រប់សកម្មភាពនៃ អំពើជួញដូរមនុស្ស

http://www.akp.gov.kh AKP ភ្នំពេញ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានជំរុញឱ្យគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអាជ្ញាធររាជធានី ខេត្ត ត្រូវបន្តខិតខំពង្រឹងគ្រប់សកម្មភាព និងរូបភាពក្នុងការទប់ស្កាត់ប្រឆាំង នឹងការជួញដូរមនុស្ស ដើម្បីធានាសុវត្ថិភាព និងសេចក្តី សុខជូនប្រជាពលរដ្ឋ និងសង្គមជាតិ។

ក្នុងពិធីផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នាព្រឹកថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨ នៅទីស្តីការក្រសួង មហាផ្ទៃ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជា ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស បានមានប្រសាសន៍ថា គណៈ កម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ត្រូវខិតខំប្រឹងប្រែងបន្តទៀត ដើម្បីការពារប្រជាជនកម្ពុជា ក៏ដូចជាមនុស្សជាតិពីភាពរងគ្រោះដោយការជួញដូរមនុស្សគ្រប់រូបភាព និង ផ្តល់ភាពសុខសាន្ត សុខដុមនីយកម្មជូនដល់គ្រួសារ និងសង្គមជាតិទាំងមូល។ សម្តេចក្រឡា ហោមបានបញ្ជាក់ថា ការវាយតម្លៃលើលទ្ធផលដែល ទទួលបានក្នុងរយៈពេល១ឆ្នាំមកនេះ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការ ជួញដូរមនុស្សគ្រប់ក្រសួង ស្ថាប័ន និងភាគីពាក់ ព័ន្ធទាំងអស់ គឺជាមធ្យោបាយមួយដើម្បីរកឱ្យឃើញនូវអំពើជួញដូរមនុស្ស និងកសាងប្រព័ន្ធ នៃការវាយតម្លៃមួយឱ្យកាន់តែមានប្រសិទ្ធភាព។

សម្តេចក្រឡាហោមបានបន្តថា រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ ក្នុងការពង្រឹងសុខសន្តិភាព ស្ថិរភាពនយោបាយ ការគោរពសិទ្ធិមនុស្ស និងលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ។ ក្រៅពីនេះ រាជរដ្ឋាភិបាលបានផ្តល់ភាពស្របច្បាប់ជូនដល់ពលករដែលកំពុងតែធ្វើការខុសច្បាប់នៅក្រៅប្រទេស ជាពិសេសនៅក្នុងប្រទេសថៃ ការបើកកន្លែងផ្តល់លិខិតឆ្លងដែន និង ប័ណ្ណអនុញ្ញាតិការងារនៅទីតាំងសំខាន់ៗមួយចំនួន ដើម្បីការពារពីការរំលោភបំពាន និងកេងប្រវ័ញ្ចកម្លាំងពលកម្មដល់ពលករ។ សម្តេចក្រឡាហោមបានលើកឡើងថា បច្ចុប្បន្ននេះ អាជ្ញាធរថៃបានបញ្ជូនពលករដែលធ្វើ

ការខុស ច្បាប់មកកម្ពុជាវិញតាមច្រក ប៉ោយប៉ែតក្នុងមួយ ថ្ងៃយ៉ាងតិចបំផុត៨០នាក់ ហើយបញ្ហានេះ រាជរដ្ឋាភិបាលក៏បានបង្កើតកន្លែងសំចតនៅតាម ខេត្តជាប់ព្រំដែន ដើម្បីទទួលបងប្អូនពលករដែលភាគីថៃបានបញ្ជូនត្រឡប់មកកម្ពុជាវិញ ដែលនេះគឺជាបន្ទុកមួយរបស់រាជរដ្ឋាភិបាល ដើម្បីជួយឱ្យពួកគាត់បានត្រឡប់ទៅស្រុក កំណើតវិញបានជួបជុំក្រុមគ្រួសារ។

សម្តេចក្រឡាហោមបានអះអាងថា ការធ្វើដូចនេះគឺជាផ្នែកមួយ នៃការទប់ស្កាត់ប្រឆាំងនឹង ការជួញដូរមនុស្ស និងការលើកកម្ពស់សិទ្ធិមនុស្ស ព្រមទាំងការទទួលខុសត្រូវរបស់រាជរដ្ឋាភិ បាលចំពោះប្រជាពលរដ្ឋ។ សម្តេចក្រឡាហោមបានលើកទឹកចិត្តដល់ភាគីពាក់ព័ន្ធទាំងអស់ ត្រូវបន្តខិតខំប្រឹងប្រែងសកម្ម ភាពប្រយុទ្ធប្រឆាំងការជួញដូរមនុស្សឱ្យបានខ្លាំងក្លាបន្ថែមទៀត ដើម្បីសេចក្តីសុខរបស់ ប្រជាពលរដ្ឋ និងប្រទេសជាតិ។

លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈ កម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានឱ្យដឹងថា ក្នុងឆ្នាំ២០១៧កន្លងមកនេះ អគ្គស្នងការដ្ឋាននគរបាលជាតិ និងសមាជិកក្រុមការងារអនុវត្តន៍ច្បាប់បានសហការជាមួយ ព្រះរាជអាជ្ញាតាមបណ្តារាជធានី ខេត្ត បង្ក្រាបការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចំនួន១៥៩ករណី គឺកើនឡើងចំនួន៦៧ករណី បើធៀបនឹងឆ្នាំ២០១៦កន្លងទៅ។ ឃាត់ខ្លួនជនសង្ស័យ និងបញ្ជូលទៅសាលាដំបូង បានចំនួន២០៣នាក់ ជនសង្ស័យជាជន បរទេសចំនួន២០នាក់ ដែលមាន៨សញ្ជាតិផងដែរ៕ ដោយ អ៊ុន រិទ្ធី

## ក្រសួងមហាផ្ទៃបន្ថែមពេលពិភាក្សាសេចក្តីព្រាងច្បាប់គ្រប់គ្រងសេវាពពោះជំនួស

https://khmer.voanews.com/ 22 ឧសភា 2018 កាន់ វិច្ឆិកា

ភ្នំពេញ៖ សេចក្តីព្រាងច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងសេវាពពោះជំនួស ដែលរដ្ឋាភិបាលចាប់ផ្តើមពិគ្រោះកាលពីដើមឆ្នាំ២០១៧ ត្រូវបានពន្យារពេលដាក់ឆ្លងទៅគណៈរដ្ឋមន្ត្រី ដើម្បីសិក្សាឲ្យកាន់តែលម្អិតបន្ថែមទៀត។ នេះបើតាមការបញ្ជាក់ពីមន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ។

អ្នកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិបង្ក្រាបការជួញដូរមនុស្ស និងផ្លូវភេទលើស្ត្រី និងកុមារ ថ្លែងបែបនេះ ក្រោយបញ្ចប់ពិធីផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងលើកទិសដៅឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨។ អ្នកស្រី ជូ ប៊ុនអេង ប្រាប់អ្នកសារព័ត៌មានថា ការសម្រេចពន្យារការអនុម័តច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងសេវាពពោះជំនួសនេះ ធ្វើឡើងដោយសារមានបញ្ហាមិនច្បាស់លាស់ជាច្រើនពាក់ព័ន្ធច្បាប់របស់កម្ពុជាមួយចំនួនដែលកំពុងនៅជាធរមាន ពាក់ព័ន្ធនឹងការពពោះ សញ្ជាតិ ការនាំក្មេងចេញទៅក្រៅប្រទេស ព្រមទាំងភាពទុច្ចរិតនៃការជួញដូរមនុស្សជាដើម។ ទោះយ៉ាងណា អ្នកស្រីមិនបានបញ្ជាក់ថា ការពន្យារពេលអនុម័តច្បាប់នេះ នឹងត្រូវធ្វើឡើងរហូតដល់ពេលណានោះទេ។

អ្នកស្រីបញ្ជាក់ថា៖ «យើងត្រូវការសិក្សាឲ្យបានល្អ ពីព្រោះនេះគឺជាលើកទី១ ដែលពាក់ព័ន្ធដល់កម្ពុជា អញ្ចឹងយើងគួររៀនសូត្រពីប្រទេសទាំងឡាយដែលគេបាននិងកំពុងតែធ្វើនៅក្នុងពិភពលោក។ ពីព្រោះច្បាប់តែកាលណាដាក់ចេញទៅហើយ យើងពិបាកត្រឡប់ក្រោយណាស់ អញ្ចឹងហើយបានជាសម្តេច [ស ខេង] លោកសំណូមពរថាសូមឲ្យពន្យារការដាក់ទៅគណៈរដ្ឋមន្ត្រី និងសភា ដើម្បីពិនិត្យឲ្យអស់ គ្រប់ជ្រុងជ្រោយ ជៀសវាងយើងធ្វើទៅហើយយើងពិបាកត្រឡប់ក្រោយវិញ»។ ការតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងសេវាពពោះកូនជំនួសនេះ ធ្វើឡើងក្រោយពីអាជ្ញាធរបានចាប់ខ្លួនស្ត្រីជនជាតិអូស្ត្រាលីម្នាក់ និងពលរដ្ឋខ្មែរ២នាក់កាលពីឆ្នាំ២០១៦ ដោយចោទពីបទ «ធ្វើជាអន្តរការីរវាងអ្នកសុំ ហើយនិងស្ត្រីពពោះ និងសុំឲ្យផ្តល់ឯកសារដោយទុច្ចរិត» ក្រោយពួកគេបានផ្តល់សេវានេះ។ សាលា

ដំបូងរាជធានីភ្នំពេញកាលពីដើមខែសីហា ឆ្នាំ២០១៧ បានសម្រេចឲ្យអ្នកទាំងបីជាប់ពន្ធនាគារ១៨ខែ ពាក់ព័ន្ធនឹងសំណុំរឿងជួលស្ត្រីខ្មែរឲ្យពពោះជំនួសនេះ ខណៈដែលច្បាប់ពាក់ព័ន្ធនឹងការពពោះជំនួសនៅមិនទាន់កើតមាននៅឡើយ។

កញ្ញា សេង រាសី អ្នកសម្របសម្រួលកម្មវិធីសមភាពយេនឌ័រក្នុងវិស័យនយោបាយនៃអង្គការសីលកា ប្រាប់ VOA នារសៀលថ្ងៃអង្គារនេះថា កញ្ញាគាំទ្រចំពោះការសម្រេចបង្កើនការសិក្សា និងស្រាវជ្រាវបន្ថែមពាក់ព័ន្ធនឹងការបង្កើតច្បាប់ ស្ដីពីការគ្រប់គ្រងការពពោះជំនួស ឲ្យបានគ្រប់ជ្រុងជ្រោយ។ កញ្ញាបន្ថែមថា ការពពោះជំនួស គឺជាអាជីវកម្មមួយដែលធ្វើឲ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិមនុស្ស ជាពិសេសស្ត្រីដែលជាអ្នកពរពោះជំនួស ដូច្នេះកញ្ញាថា រដ្ឋាភិបាលគួរជំរុញធ្វើយ៉ាងណាឲ្យច្បាប់នេះត្រូវបានចេញយកទៅអនុវត្តឲ្យបានឆាប់។ កញ្ញា សេង រាសី បញ្ជាក់ថា៖ « គោលគំនិតរបស់ក្រសួងតែម្ដង ជាពិសេសក្រសួងយុត្តិធម៌ ក៏ដូចជាក្រសួងកិច្ចការនារី ថាតើលោកបង្កើតច្បាប់មួយហ្នឹង គឺដើម្បីហាមប្រាមកុំឲ្យមានអាជីវកម្មហ្នឹងតែម្ដង ឬមួយក៏បង្កើតមកដើម្បីគ្រប់គ្រងលើអាជីវកម្មមួយហ្នឹង? បើទោះបីជាករណីណាមួយចេញមកក៏ដោយ ខ្ញុំបញ្ជាក់ហើយបញ្ជាក់ទៀតថា ច្បាប់នេះត្រូវតែយុត្តិធម៌សម្រាប់ទាំងអស់គ្នា ហើយឈរលើគោលការណ៍សិទ្ធិមនុស្សជាចម្បង ហើយស្របតាមគោលការណ៍រដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា»។ ចាប់ពីឆ្នាំ២០១៥មក កម្ពុជាបានក្លាយជាគោលដៅដ៏ពេញនិយមមួយសម្រាប់ឪពុកម្ដាយ ដែលមានបំណងស្វែងរកឲ្យមានការស៊ីឈ្នួលពពោះជំនួស បន្ទាប់ពីសេវាកម្មនេះត្រូវបានហាមប្រាមក្នុងប្រទេសថៃ ឥណ្ឌា និងនេប៉ាល់។

បើតាមរបាយការណ៍ឆ្នាំ២០១៧ និងលើកទិសដៅឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលត្រូវបានផ្សព្វផ្សាយនៅថ្ងៃអង្គារនេះ បានបង្ហាញថា បទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទក្នុងឆ្នាំ២០១៧ មានការកើនឡើងបើធៀបនឹងឆ្នាំ២០១៦ ដោយសារមានបញ្ហាប្រឈម និងខ្វះខាតមួយចំនួនដូចជា ឧក្រិដ្ឋជនមានល្បិចកលខ្ពស់ ការត្រួតពិនិត្យ និងគ្រប់គ្រងពលករចំណាកស្រុកតាមព្រំដែនមិនទាន់បានល្អ មន្ត្រីមួយចំនួននៅខ្វះខាតសមត្ថភាពជាដើម៕

## សមត្ថកិច្ចសម្រេចបិទផ្ទះម៉ាស្សាមួយកន្លែងដែលលួចលាក់បម្រើសេវាផ្លូវភេទ

http://cambodiapolice.com/policekh/ 9:15 am 23 ឧសភា 2018 24

ភ្នំពេញ ៖ កម្លាំងសមត្ថកិច្ចនាយកដ្ឋានប្រឆាំងការជួញដូរ និងការពារ អនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ នៅយប់ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨នេះ បានចុះបង្ក្រាបទីតាំងម៉ាស្សា យីហោ ១៦៨ ហេងហេង មួយកន្លែងដែលមានបង្កប់បម្រើសេវាផ្លូវភេទ រកឃើញស្ត្រីរងគ្រោះ៥នាក់ និងជនសង្ស័យ៥នាក់ រួមជាមួយស្រោមអនាម័យជាច្រើនប្រអប់ ។ ប្រតិបត្តិការនេះ ដឹកនាំដោយលោកវរសេនីយ៍ទោ តាន់ វណ្ណារិទ្ធ អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរ និងការពារអនីតិជន ដោយមាន ការសម្របសម្រួលពីលោក កុល បុន ព្រះរាជអាជ្ញារង នៃអយ្យការអម សាលាដំបូងរាជធានីភ្នំពេញ អមដោយលោក យិន ភារិន ជាក្រឡាបញ្ជី និងកម្លាំងសមត្ថកិច្ចមូលដ្ឋានផងដែរ ។ សមត្ថកិច្ចបានឲ្យដឹងថា កន្លែងម៉ាស្សា យីហោ ១៦៨ ហេងហេងនេះ មានទីតាំងស្ថិតនៅផ្លូវ ៣៧១ ភូមិម៉ល សង្កាត់ជង្គោ ខណ្ឌជង្គោ រាជធានីភ្នំពេញ ដែលមានម្ចាស់ឈ្មោះ សួង វាសនា ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ វ៉ា ធានី ភេទស្រី អាយុ៣០ឆ្នាំ ជនជាតិខ្មែរ ។

ក្រោយចុះឆែកឆេរជាក់ស្តែងយនោះ កម្លាំងមត្ថកិច្ចប្រឆាំងការជួញដូរ មនុស្ស បានរកឃើញស្ត្រីរងគ្រោះ ៥នាក់ និងជនសង្ស័យ៥នាក់ ។ ក្នុងនោះកម្លាំងជំនាញបានរកឃើញវត្ថុតាង មានស្រោមអនាម័យប្រើ ប្រាស់រួច និងមិនទាន់ប្រើជាច្រើនប្រអប់ នៅក្នុងផ្ទះម៉ាស្សាខាងលើនេះ ។ បច្ចុប្បន្នផ្ទះម៉ាស្សាខាងលើត្រូវបានសមត្ថិកច្ចសម្រេចបិទជាបណ្តោះអាសន្ន រីឯជនរងគ្រោះ និងជនសង្ស័យ ត្រូវបានបញ្ជូនខ្លួនទៅកាន់នាយកដ្ឋាន ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដើម្បីធ្វើការសាកសួរ និងចាត់ការតាមនីតិវិធីច្បាប់ ៕

# កុមារយ៉ាងតិច ២៤០ នាក់ត្រូវបានរកឃើញធ្វើការតាមសហគ្រាស

https://www.postkhmer.com/ ម៉ិច ដារ៉ា | Publication date 23 May 2018 | 10:18 ICT

**ភ្នំពេញៈ** កុមារយ៉ាងហោចណាស់ ២៤០ នាក់ត្រូវរកឃើញថាមានគេប្រើឱ្យធ្វើពលកម្មធ្ងន់ៗបន្ទាប់ពីក្រសួងការងារបានចុះពិនិត្យនៅតាមសហគ្រាស និងគ្រឹះស្ថាននានាក្នុងនោះក៏មាននៅសិប្បកម្មឡឥដ្ឋផងដែរ ជាករណីដែលធ្លាប់ត្រូវបានអង្គការក្រៅរដ្ឋាភិបាលរកឃើញកន្លងមកផងដែរ។ នេះបើតាមលោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គជបជ)។ ថ្លែងក្នុងកិច្ចប្រជុំប្រចាំឆ្នាំក្នុងក្របខ័ណ្ឌស្ថាប័ននេះនៅក្រសួងមហាផ្ទៃកាលពីថ្ងៃអង្គារលោកស្រី ជូ ប៊ុនអេង បានលើកឡើងថាៈ «មន្ទីរការងារខេត្តសៀមរាប បានចុះអធិការកិច្ចពលកម្មកុមារនៅសិប្បកម្មឡឥដ្ឋចំនួន ២០ ហើយបានបន្តឃ្លាំមើលកម្មករនៅសិប្បកម្មឡឥដ្ឋចំនួន ៤៦ ដទៃៗទៀតដោយបានរកឃើញថាមានចំនួន ៣៧ នៅកំពុងដំណើរការ និង ៣ កន្លែងទៀតបានបិទទ្វារ និងចំនួន ៥ បានព្យួរ ខណៈរោងចក្រ ឬសិប្បកម្មមានកម្មករសរុបចំនួន ៧៨៧ និងស្ត្រីចំនួន ៣៨០ នាក់»។ ប៉ុន្តែលោកស្រីមិនបានផ្តល់តួលេខអំពីថា តើកុមារចំនួនប៉ុន្មាននាក់ត្រូវបានជួយសង្គ្រោះពីសិប្បកម្មទាំងនោះទេ។

លោកស្រី ប៊ុន ជ្រឹម អនុប្រធានមន្ទីរការងារខេត្តសៀមរាបបានថ្លែងថា មន្ទីរការងារខេត្តកំពុងធ្វើការងារទៅលើស្រុកចំនួន ២ រួមមាន ស្រុកបន្ទាយស្រី និងស្រុកសូទ្រនិគម ដើម្បីជួយក្មេងដែលធ្វើការងារនៅសិប្បកម្មឡឥដ្ឋ រួមទាំងយកក្មេង ២០ នាក់មានអាយុពី ១៥ ទៅ ២០ ឆ្នាំពីតាមសិប្បកម្ម និងការពារកុមារចំនួន ៧០ នាក់ដែលធ្វើការងារនៅសិប្បកម្មនេះក្នុងអំឡុងថ្ងៃឈប់សម្រាកពីសាលារៀន។ លោកស្រីបានបញ្ជាក់ថាៈ «យើងបានជួយកុមារចំនួន ៧០ នាក់ដែលក្រោមអាយុ ១៥ ឆ្នាំអ្វីដែលយើងអាចជួយគឺផ្តល់ឲ្យពួកគេនូវវគ្គបំពេញបន្ថែមរយៈពេល ២ ខែនៅពេលពួកគេសម្រាកវិស្សមកាល និងផ្តល់អាហារសម្រន់ដល់ពួកគេជារៀងរាល់ថ្ងៃក្នុងអំឡុងរយៈពេល ២ ខែនេះហើយនៅពេលពួកគេត្រឡប់ទៅសាលាវិញ យើងមានសម្ភារសិក្សាដល់ពួកគេ និងផ្តល់ឯកសណ្ឋានចំនួន ២ កំប្លេ និងធ្លាប់ផ្តល់ឲ្យពួកគេនូវស្បែកជើងចំនួន ២ គូនៅឆ្នាំ ២០១៧ ព្រមទាំងបានផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈដល់កុមារចំនួន ២០ នាក់ដែលមានអាយុពី ១៥ ឆ្នាំទៅ ២០ ឆ្នាំផងដែរក្នុងនោះរួមទាំងការបណ្តុះបណ្តាលលើជំនាញធ្វើសក់ និងអគ្គិសនី» ជាដើម។ លោកស្រីបានបន្តថាៈ «នៅឆ្នាំ ២០១៨ ដោយសារថវិកាត្រូវបានកាត់បន្ថយយើងនឹងយកកុមារដែលមានអាយុក្រោម ១៥ ឆ្នាំចំនួន ៩០ នាក់ពីសិប្បកម្មឡឥដ្ឋ និងក្មេងលក់វត្ថុវិស័យអនុស្សាវរីយ៍ដើម្បីជួយពួកគេ»។

លោកស្រីបានបន្ថែមថាៈ «អ្នកដែលយើងយកចេញគឺកម្មករពេញម៉ោងនៅក្នុងសិប្បកម្មឡឥដ្ឋ ហើយយើងដកពួកគេយកទៅទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ ប៉ុន្តែការពារកុមារដែលរៀននៅពេលរសៀលទៅធ្វើការនៅពេលព្រឹក បើមិនដូច្នេះពួកគេប្រឈមមុខនឹងការបោះបង់ការសិក្សា ហើយប្រសិនបើយើងមិនដកពួកគេចេញ ពួកគេនឹងបោះបង់ការសិក្សាដើម្បីធ្វើការពេញម៉ោង»។ លោកស្រីបានបន្តថាៈ «មានកុមារជាច្រើន (ដែលធ្វើការនៅសិប្បកម្មឡឥដ្ឋ) ប៉ុន្តែដោយសារយើងមានថវិកាកំណត់...ហើយវាផ្តល់ក្នុងមួយឆ្នាំសម្រាប់ជួយកុមារ ៩០ នាក់ហើយនេះជាអ្វីដែលយើងអាចធ្វើវាបាន»។ យ៉ាងណាក្តីនៅពេលសួរអំពីចំនួនតួលេខនៃកុមារសរុបដែលកំពុងធ្វើការងារនៅរោងចក្រ និងសិប្បកម្មនានា លោកស្រីបានបដិសេធផ្តល់អត្ថាធិប្បាយ។ លោកស្រីបានថ្លែងថាៈ «ខ្ញុំមិនអាចផ្តល់តួលេខបានទេដោយសារមានកុមារជាច្រើន...ហើយដោយសារយើងធ្វើការតែ ២ ស្រុក ប៉ុន្តែជាការពិតមានស្រុកជាច្រើនដែលមានសិប្បកម្មឡឥដ្ឋ» រួមមាន ស្រុកអង្គរជុំ ស្រុកជីក្រែង គ្រួសារនីមួយៗមានមនុស្ស ៤ ឬ ៥ នាក់។ លោកស្រីបានថ្លែងថានៅស្រុកបន្ទាយស្រី គ្រួសាររបស់កុមារដែលធ្វើការនៅសិប្បកម្មឡឥដ្ឋបានប្រឈមនឹងបញ្ហាមួយចំនួនរួមមាន សំបុត្រកំណើត ហើយភាគច្រើនបំផុតនៃកុមារទាំងនោះរៀនបានត្រឹមតែថ្នាក់ទី ៦។ លោកស្រីបន្តថាៈ «ពួកគេមិនអាចទៅរៀននៅអនុវិទ្យាល័យទេដែលនេះជាបញ្ហាប្រឈម...មានកុមារប្រហែល ៦០ ភាគរយដែលឪពុកម្តាយធ្វើការនៅសិប្បកម្មឡឥដ្ឋ»។

របាយការណ៍នៃការរកឃើញនេះកើតមានឡើងប៉ុន្មានខែបន្ទាប់ពីអង្គការសិទ្ធិមនុស្សលីកាដូបានចេញលទ្ធផលរកឃើញដែលបង្ហាញអំពីចំនួនបំណុល និងពលកម្មកុមារនៅតាមសិប្បកម្មឡឥដ្ឋដែលខុសច្បាប់ទាំងច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ ប៉ុន្តែបន្ទាប់ពីមានរបាយការណ៍នេះរដ្ឋមន្ត្រីក្រសួងការងារលោក អ៊ិត សំហេង បានគំរាមចាត់វិធានការផ្លូវច្បាប់ទៅលើអង្គការក្រៅរដ្ឋាភិបាលប្រសិនបើលទ្ធផលរកឃើញរបស់ពួកគេត្រូវបានរកឃើញថាមិនត្រឹមត្រូវ។

មន្ត្រីស៊ើបអង្កេតជាន់ខ្ពស់របស់អង្គការលីកាដូ លោក អំ សំអាត បានថ្លែងថា៖ «កន្លងមកយើងបានទទួលព័ត៌មានថាកុមាររងរបួស ឬស្លាប់នៅសិប្បកម្មឡឥដ្ឋ...យើងឃើញម្ចាស់សិប្បកម្មមួយចំនួនទទួលយកខណៈខ្លះទៀតនៅមិនទទួលយកហើយបន្តឲ្យកុមារនៅធ្វើការនៅសិប្បកម្មរបស់ខ្លួនហេតុដូច្នេះ យើងគិតថាក្រសួងគួរតែពិនិត្យនៅតាមសិប្បកម្ម និងរោងចក្រដាទៀងទាត់ដើម្បីការពារមិនឲ្យមានការរំលោភបំពាន និងកេងប្រវ័ញ្ចទៅលើពលកម្មកុមារហើយភាគច្រើនបំផុតនៃកម្មករជំពាក់ប្រាក់ថៅកែដូច្នេះគ្រួសាររបស់ពួកគេរួមទាំងកូនរបស់ពួកគេបង្ខំចិត្តធ្វើការសងបំណុល»៕PS

## ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៨

## ករណីជួញដូរមនុស្ស ត្រូវបានរកឃើញមានការកើនឡើង

https://www.postkhmer.com/ ម៉ិច ដារ៉ា | Publication date 23 May 2018 | 17:03 ICT

**ភ្នំពេញ៖**បណ្តាញប្រតិបត្តិការប្រឆាំងនឹងអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទបានរកឃើញថាករណីនេះកំពុងមានការកើនឡើង។ នេះបើតាមរបាយការណ៍ប្រចាំឆ្នាំចេញផ្សាយ កាលពីម្សិលមិញ ដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស(គជបជ)។ កាលពីឆ្នាំមុន អគ្គស្នងការនគរបាលជាតិ ក៏ដូចជា សមាជិកក្នុងក្រុមការងារអនុវត្តន៍ច្បាប់ បានសហការជាមួយព្រះរាជអាជ្ញាតាមបណ្តា រាជធានី ខេត្ត បង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទបានចំនួន ១៥៩ ករណីលើ ៩២ ករណី បើធៀបនឹងឆ្នាំ ២០១៦ គឺកើនឡើងចំនួន ៦៧ ករណីស្មើនឹង ៧២,៨២ ភាគរយ។

តាមរបាយការណ៍នៅក្នុងឆ្នាំ ២០១៧ ចាប់ខ្លួនបាន ២០៣ នាក់ ខណៈដែលឆ្នាំ ២០១៦ ចាប់ខ្លួនបានតែចំនួន ១១៣ នាក់ប៉ុណ្ណោះ។ ក្នុងនោះមានជនបរទេស ២០ នាក់ និងមាន ៨ សញ្ជាតិ គឺវៀតណាម ៣ នាក់ អង់គ្លេស ២ នាក់ ហូឡង់ ២ នាក់ ជប៉ុន ១ នាក់ អាមេរិក ១ នាក់ រុស្ស៊ី ១ នាក់ ចិន ៩ នាក់ និងឆេក ១ នាក់។ ជាមួយគ្នានេះសមត្ថកិច្ចបានជួយសង្គ្រោះជនរងគ្រោះពីអំពើជួញដូរនេះបាន ៣៤៥ នាក់នៅក្នុងឆ្នាំ ២០១៧ ខណៈឆ្នាំ ២០១៦ ជួយសង្គ្រោះបាន ២៩៨ នាក់។ របាយការណ៍ដដែលបានឲ្យដឹងថា ក្នុងចំណោមជនរងគ្រោះទាំងនោះមានអ្នកអាយុ ក្រោម ១៥ ឆ្នាំ ១៣៨ នាក់ អាយុចន្លោះពី ១៥-១៧ ឆ្នាំ ៤០ នាក់ និងអាយុ ១៨ ឆ្នាំឡើងទៅមាន ១៦៧ នាក់។ បញ្ជូនទៅមន្ទីរសង្គមកិច្ច ១២០ នាក់ បញ្ជូនទៅអង្គការក្រៅរដ្ឋាភិបាល ៥នាក់និងបញ្ជូនទៅក្រុមគ្រួសារវិញ ២២០ នាក់។ ក្រៅពីនោះអំពើជួញដូរមនុស្សបង្ក្រាបបាន ៤៨ក រណីដោយចាប់ខ្លួនបាន ៧២ នាក់ និង ជួយសង្គ្រោះជនរងគ្រោះបាន ១២៩ នាក់ក្នុងឆ្នាំ ២០១៧ ខណៈដែលនៅឆ្នាំ ២០១៦ បង្ក្រាបបាន ២៧ ករណី។ ចំពោះអំពើធ្វើអាជីវកម្មផ្លូវភេទបង្ក្រាបបាន ១១១ ករណីចាប់ខ្លួនបាន ១៣១ នាក់និងជួយសង្គ្រោះជនរងគ្រោះបាន ២១៦ នាក់ ខណៈនៅឆ្នាំ ២០១៦ បង្ក្រាបបាន ៦៥ ករណី។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និង ជាអនុប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គជបជ) បានថ្លែងនៅក្នុងកិច្ចប្រជុំថា៖ «ឆន្ទៈ និង ការប្តេជ្ញាចិត្ត គឺជាគោលការណ៍របស់រដ្ឋាភិបាលកម្ពុជា ដែលដាក់អំពើជួញដូរមនុស្ស ជាអាទិភាពមួយដែលត្រូវតែយកចិត្តទុកដាក់ដោះស្រាយឱ្យបានឆាប់រហ័សហើយ មិនត្រូវលាក់បាំងចំពោះករណីនេះទេ ពីព្រោះវាឲ្យប៉ះពាល់ដល់អាយុជីវិត សិទ្ធិ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស»។ លោកស្រីបានបន្ថែមថា យុទ្ធសាស្ត្ររបស់លោកនាយករដ្ឋមន្ត្រីហ៊ុនសែនគឺដោះស្រាយបញ្ហាពលកចំណាកស្រុក ការលើកកម្ពស់ជីវភាពរស់នៅនិងការកាត់បន្ថយការធ្វើចំណាកស្រុកក៏ដូចជាកាត់បន្ថយជនរងគ្រោះ នៃអំពើជួញដូរមនុស្ស

និងការកេងប្រវ័ញ្ចគ្រប់ប្រភេទ។ លោកស្រីបន្តថា៖ «ប្រជាពលរដ្ឋបន្តចាញ់ការបោកបញ្ឆោតពីជនល្មើសដែលមានល្បិចកល្បខ្ពស់ និង មានបណ្ដាញស្មុគស្មាញក្នុងអំពើកេងប្រវ័ញ្ច និង ជួញដូរមនុស្ស។ ការតាមដាននិងត្រួតពិនិត្យពលករចំណាកស្រុកនៅតាមបណ្ដោយព្រំដែន គឺនៅមិនទាន់មានលក្ខណៈល្អប្រសើរនៅឡើយទេដែលបង្កឱ្យមានជនរងគ្រោះ ... ហើយការផ្ដល់ព័ត៌មាននិងការបញ្ជូនរបាយការណ៍របស់ក្រសួងស្ថាប័ន អង្គភាព និង ខេត្តមួយចំនួន នៅតែមានភាពយឺតយ៉ាវ រីឯ ខេត្តក្រុង អង្គភាព និង ស្ថាប័នមួយចំនួន នៅតែមិនទាន់រៀបចំផែនការ និង កញ្ចប់ថវិកាច្បាស់លាស់នៅឡើយ។ សេវាកម្មកម្សាន្ត «ភ្លើងពណ៌» ដែលកំពុងរីកកើនឡើង គឺជាប្រភពនៃអំពើជួញដូរមនុស្សនិងធ្វើឲ្យប៉ះពាល់ដល់កុមារដែលឪពុកម្ដាយរបស់ពួកគេបានធ្វើចំណាកស្រុកអស់គឺកំពុងរីកធំឡើងៗ... កុមារទាំងនោះនឹងមិនមានឱកាសរៀនសូត្រ ថែទាំសុខភាពនិងសុវត្ថិភាពរបស់ពួកគេដូចកុមារដទៃទៀតទេ»។

ទោះយ៉ាងណាក៏ដោយ របាយការណ៍នោះបានឱ្យដឹងថា រាជធានីភ្នំពេញ មានករណីជួញដូរមនុស្សច្រើនជាងគេ គឺមានជនរងគ្រោះ ៥៧ នាក់ ត្រូវបានជួយសង្គ្រោះកាលពីឆ្នាំមុន។ របាយការណ៍ក៏បានឲ្យដឹងដែរថា ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ បានទទួលពលរដ្ឋខ្មែរដែលរងគ្រោះដោយអំពើជួញដូរមនុស្សមកកម្ពុជាវិញ ចំនួន ៧៥៧ នាក់ ក្នុងនោះមកពីប្រទេសម៉ាឡេស៊ីមាន ៣៥១ នាក់ មកពីប្រទេសថៃ មាន ២៦០ នាក់ មកពីប្រទេសចិន មាន ៥០ នាក់ មកពីប្រទេសឡាវមាន ៣៣ នាក់ មកពីប្រទេសសូម៉ាលី ១៨ នាក់ មកពីឥណ្ឌូណេស៊ី មាន ១៨ នាក់ មកពីវៀតណាមមាន ១៧ នាក់ មកពីជប៉ុនមាន ៥ នាក់ មកពី សិង្ហបុរី មាន ៤ នាក់ និងមកពី អារ៉ាប៊ី សាអូឌីត មាន ១ នាក់។

ដោយឡែក ចំនួនស្ត្រីខ្មែរដែលត្រូវបាននាំទៅឲ្យរៀបអាពាហ៍ពិពាហ៍ជាមួយបុរសជនជាតិ ចិន ជាញឹកញាប់ត្រូវបានគេមើលឃើញថា ពួកគេរងការរំលោភបំពានឬលក់ទៅឱ្យអំពើជួញដូរផ្លូវភេទគឺបានកើនឡើង ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ រីឯ ស្ត្រីដែលទៅបម្រើការងារតាមផ្ទះនៅបរទេសងាយទទួលរងការរំលោភបំពាននិងការជាប់បំណុល។បច្ចុប្បន្នរដ្ឋាភិបាលកំពុងចរចាជាមួយប្រទេសចិន ម៉ាឡេស៊ី និង អារ៉ាប៊ី សាអ៊ូឌីត ដើម្បីបើកផ្លូវសម្រាប់ពលករបម្រើការងារតាមផ្ទះដែលប្រទេសទាំងនោះមានកំណត់ត្រាមិនល្អក្នុងការការពារពលករចំណាកស្រុក ។ កាលពីឆ្នាំ ២០១៦ ការិយាល័យអង្គការសហប្រជាជាតិ ស្ដីអំពីគ្រឿងញៀន និង ឧក្រិដ្ឋកម្មបានចេញរបាយការណ៍មួយមានចំណើងជើងថា «ការពារសន្តិភាព និង វិបុលភាព នៅតំបន់អាស៊ីអាគ្នេយ៍ ដោយការធ្វើសមាហរណកម្មសេដ្ឋកិច្ច និង សន្តិសុខនៅអាស៊ីអាគ្នេយ៍» ដោយបានដាក់ប្រទេសកម្ពុជា ក្នុងចំណោមបណ្ដាប្រទេសដែលពលរដ្ឋមានហានិភ័យខ្ពស់នៃអំពើជួញដូរមនុស្សជាពិសេសពលករចំណាកស្រុកដែលមិនមានជំនាញទៅធ្វើការនៅប្រទេស ថៃ សិង្ហបុរី ឥណ្ឌា និងចិន ដែលភាគច្រើននៃពួកគេមកពីប្រទេសដែលមានការអភិវឌ្ឍតិចតួចដូចជា កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម ជាដើម ហើយភាពធូរលុងនៃការត្រួតពិនិត្យតាមព្រំដែនរវាងប្រទេសក្នុងតំបន់នោះគឺពិបាកបញ្ឈប់អំពើជួញដូរនេះណាស់ហើយវាធ្វើឱ្យតួនាទីនៃការអនុវត្តច្បាប់កាន់តែពិបាក។

លោកស្រី រស់ សុភាព នាយិកាអង្គការយេនឌ័រ និងការអភិវឌ្ឍដើម្បីកម្ពុជា (GADC) បានថ្លែងថា៖« មានអំពើជួញដូរមនុស្សជាច្រើនប្រភេទជាពិសេសតាមរយៈការរកការងារឲ្យធ្វើ...ហើយស្ត្រីក៏ក្លាយទៅជាជនរងគ្រោះនៃអំពើជួញដូរមនុស្សដោយសារស្ថានភាពរស់នៅរបស់ពួកគេជួបការលំបាក»។ លោកស្រីថ្លែងថា៖ «ដោយមិនទទួលបានព័ត៌មានត្រឹមត្រូវនិងចាញ់ការបោកបញ្ឆោតរបស់ឈ្មួញកណ្ដាល... ម្យ៉ាងវិញទៀតដោយសារពួកគេនៅឆ្ងាយពីក្រុមគ្រួសារ ហើយការទទួលបានព័ត៌មានគឺត្រូវពឹងផ្អែកលើអាជ្ញាធរខណៈដែលអាជ្ញាធរមិនអាចជួយពួកគេបានហើយបញ្ហាផ្សេងទៀតគឺការរៀបចំឯកសារដែលមានការស៊ីសំណូកសូកប៉ាន់ ចំណុចទាំងនេះហើយធ្វើឲ្យពួកគេងាយរងគ្រោះពីការបោកបញ្ឆោតរបស់ឈ្មួញកណ្ដាល»។ លោកស្រីបន្តថា៖«ច្បាប់របស់យើងគឺនៅមានចន្លោះប្រហោងដូច្នេះហើយឈ្មួញកណ្ដាលអាចប្រើប្រាស់លុយកាក់ដើម្បីរំលោភបំពាននិងធ្វើអាជីវកម្មលើអ្នកដទៃ... »។ លោកស្រី ថ្លែងថា៖«សម្រាប់ត្រីតូចយើងអាចចាប់បានប៉ុន្តែត្រីធំយើងកម្រនឹងចាប់បានណាស់នៅក្នុងប្រទេសយើង»៕ NS

## ពលករខ្មែររងគ្រោះ០២នាក់ ត្រូវបានមូលនិធិ LPN ប្រទេសថៃ ជួយអន្តរាគមន៍

http://www.pheaktraprak.com/ May 24, 2018

មូលនិធិលើកកម្ពស់ជីវភាពពលករបរទេសថៃ LPN បានធ្វើការជួយ អន្តរាគមន៍ ដល់ពលករខ្មែរម្នាក់ ឈ្មោះ លុង ហាក់ បន្ទាប់ពីបានចាញ់បោកមេខ្យល់នៅក្នុងប្រទេសថៃ នាំទៅធ្វើការនៅលើទូកនេសាទត្រីនៅឯប្រទេសឥណ្ឌូនេស៊ី តាំងតែឆ្នាំ២០១០ រហូតដល់ឆ្នាំ២០១៥ ត្រូវបានបណ្តាញមូលនិធិ LPN ទំនាក់ទំនងទៅស្ថានទូតកម្ពុជា ប្រចាំ ក្រុងចាការតា ប្រទេសឥណ្ឌូនេស៊ី ជួយរំដោះរួច បញ្ជូនអោយវិលត្រឡប់ទៅស្រុកកំណើតរបស់ខ្លួនវិញ។ នៅវេលាបន្ទាប់អគ្គនាយកដ្ឋាននគរបាលជាតិនៃ ព្រះរាជាណាចក្រកម្ពុជា បានទំនាក់ទំនងមកកាន់អគ្គនាយកដ្ឋានតម្រួតប្រទេសថៃ ដើម្បីអោយបើកការស៊ើបអង្កេតលើសំណុំរឿងក្តីនេះបន្តនៅឆ្នាំ២០១៧ ដោយមានមូលនិធិ LPN ប្រទេសថៃជាអ្នកជួយដើររឿងក្តីប្តឹងបន្តទៅតុលាការ ខេត្តសាមុតសាខន ប្រទេសថៃ តាំងពីឆ្នាំ២០១៧។ ប៉ុន្តែដោយសារជួបបញ្ហារឿងសំណុំឯកសារដែលត្រូវអោយពលកររងគ្រោះធ្វើដំណើរទៅដាក់ពាក្យបណ្តឹងនៅសាលាឧទ្ធរណ៍និងភស្តុតាង ដើម្បីឡើងក្តី ប្រកបដោយក្តីយ៉ាកលំបាកពីព្រោះពលកររងគ្រោះមានបញ្ហារឿងសុខភាពផ្ទាល់ខ្លួនផងនិងបញ្ហារឿងឯកសារការធ្វើដំណើរផង ។ បច្ចុប្បន្នពលកររងគ្រោះបានទទួលប្រាក់សំណងក្នុងរឿងក្តីនេះដោយបានការជួយជ្រុំជ្រែងពីមូលនិធិLPN ប្រទេសថៃ រហូតឈានដល់ការឈ្នះនៅចុងឆ្នាំ។

ករណីមួយទៀត គឺដ៏ឃោរឃៅមួយបានកើតឡើងនៅក្នុងខេត្តសុផាន់បុរី ប្រទេសថៃ បណ្តាលឲ្យបុរសពលករខ្មែរម្នាក់ឈ្មោះ ចក់ ដែលរស់នៅក្នុងភូមិពោធិ ស្រុកបារាយណ៍ ខេត្តកំពង់ធំ បានរងរបួសដោយសារត្រូវគ្រាប់កាំភ្លើងចំករដោយមិនវះកាត់យកចេញបានត្រូវបានមូលនិធិ LPN ប្រទេសថៃ ជួយអន្តរាគមន៍តាំងពីឆ្នាំ២០១៧ ក្នុងរឿងក្តីដើម្បីអោយជនរងគ្រោះទទួលបានភាពយុទ្ធតិធម៌និងទទួលបានប្រាក់សំណងតាមនិតិវិធីច្បាប់។ ថ្វីត្បិតតែបច្ចុប្បន្នជនរងគ្រោះអាចរស់រៀនមានជីវិតដូចមនុស្សដូចធម្មតាក៏ពិតមែន ប៉ុន្តែជនរងគ្រោះនៅមានរឿងសុខភាពដោយហេតុការណ៍ដ៏ឃោរឃៅនេះ។ បច្ចុប្បន្នជនបង្កត្រូវបានតុលាការខេត្តសុផាន់បុរី កាត់អោយជាប់ទោសរយៈ៤៤ឆ្នាំក្នុងករណីអំពើហឹង្សាដ៏ឃោឃៅនេះ ។ បច្ចុប្បន្នជនរងគ្រោះ ឈ្មោះ ចក់ កំពុងរងចាំទទួលមូលប្បទានប័ត្រជាសាច់ប្រាក់ពីក្រសួងយុត្តិធម៌ថៃតាមនិវិធីច្បាប់របស់ប្រទេសថៃ នៅពេលបីខែខាងមុខទៀត នាពេលបីខែខាងមុខទៀតដោយរលប់ទៅស្រុកកំណើតជនរងគ្រោះវិញនៅថ្ងៃទី២៤-២៨ខែឧសភាឆ្នាំ២០១៨ ខាងនេះ។ "សូមថ្លែងអំណរគុណដល់មូលនិធិ LPN ប្រទេសថៃដែលតែងតែជួយរកភាពយុត្តិធម៌ជូនពលករបរទេស ដែលគ្មានទីពឹង រហូតទទួលបានភាពយុត្តិធម៌។ ២៣-០៥-២០១៨

Samak Tubtanee #SompongSrakaew ពលករខ្មែរ-KhmerLabour

## រដ្ឋមន្ត្រីក្រសួងការងារថៃ ផ្តល់ឱកាសចុងក្រោយ

https://www.facebook.com/khmerlabour/ ពលករខ្មែរ-KhmerLabour May 24, 2018

រដ្ឋមន្ត្រីក្រសួងការងារថៃ ផ្តល់ឧកាសចុងក្រោយអោយនិយោជកថៃ នាំពលករបរទេស ដែលនៅសល់ប្រមាណ១សែន៦ម៉ឺននាក់ ឲ្យប្រញាប់ប្រញាល់ នាំទៅធ្វើត្បៀតប្រវត្តិពលករនៅមណ្ឌលOSS អោយរួចរាល់នៅថ្ងៃទី១៥ ខែមិថុនាឆ្នាំ២០១៨ខាងនេះ ព្រោះរាជរដ្ឋាភិបាលថៃមិនបន្តរយៈពេលមន្ថែមទៀតទេ បើមិនដូច្នេះទេ នឹងត្រូវមានទោសតាមច្បាប់គ្រប់គ្រងពលករបរទេសតាំងតែថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៨ ។ ប្រភពពី÷ข่าวสาม3มิติ ២៤-០៥-២០១៨

## ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨

## ប្រជាពលរដ្ឋខ្មែរដែលធ្វើចំណាកស្រុកនិងធ្វើការខុសច្បាប់នៅប្រទេសថៃចាប់បញ្ជូនក្នុងខែមេសាឆ្នាំ២០១៨មានចំនួន៤,២៦៨នាក់

http://cambodiapolice.com/ 5:04 pm 24 ឧសភា 2018

**បន្ទាយមានជ័យ** ៖ យោងតាមរបាយការណ៍ការិយាល័យនគរបាលប្រឆាំងការជួញដូរនិងការពារអានីតិជនខេត្តបន្ទាយមានជ័យក្នុងខែមេសា ឆ្នាំ២០១៨នេះ អាជ្ញាធរថៃចាប់បញ្ជូនប្រជាពលរដ្ឋខ្មែរដែលធ្វើចំណាកស្រុកនិងធ្វើការដោយខុសច្បាប់នៅប្រទេសថៃដែលចាប់បញ្ជូនមកវិញមានចំនួន៤,២៦៨នាក់ ស្រី១,៤៧៣នាក់កុមារចំនួន៤៣៩នាក់ កុមារី១៦៧នាក់តាមរថយន្តភាគីថៃចំនួន១០២គ្រឿង តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតខេត្តបន្ទាយមានជ័យ។ ស្ថិតិពលរដ្ឋក្នុងខេត្តចំណាកស្រុកចេញទៅរកការងារធ្វើនៅប្រទេសថៃមានចំនួនសរុប៥០៤នាក់ ស្រី២៣៣នាក់ ក្នុងនោះស្របច្បាប់ចំនួន៦០នាក់ ស្រី២២នាក់ មិនស្របច្បាប់ចំនួន៤៤៤នាក់ ស្រី២១១នាក់ ត្រឡប់មកវិញ២,៤២៧នាក់ស្រី១,១៦៨នាក់ កុមារ៤០នាក់។

គួររំលឹកថាៈបញ្ហាពលករចំណាកស្រុកខុសច្បាប់ដែលប្រឈមគ្រោះថ្នាក់និងសុវត្ថិភាពរាល់ប្រជុំគណៈបញ្ជាការឯកភាពខេត្តបន្ទាយមានជ័យលោក សួន បវរ អភិបាលខេត្តបានលើកឡើងជារឿយៗដល់កម្លាំងសមត្ថកិច្ចដែលឈរជើងតាមបន្ទាត់ព្រំដែន និងកម្លាំងជំនាញត្រូវលុបបំបាត់ច្រករបៀងខុសច្បាប់ និងទប់ស្កាត់ពលករចំណាកស្រុកដោយខុសច្បាប់ ការពារសុវត្ថិភាពដល់បងប្អូនប្រជាពលរដ្ឋ។ ដាស់តឿនដាក់វិធានការត្រូវចាប់មេខ្យល់និងអប់រំណែនាំប្រជាពលរដ្ឋឱ្យមានការយល់ដឹងត្រូវបញ្ឈប់ការចាញ់បោកមេខ្យល់ទៅរកការងារធ្វើដោយស្របច្បាប់។

ព័ត៌មានបានឱ្យដឹងថាការដែលពលករចំណាកស្រុកខុសច្បាប់នៅតែបន្តលួចចេញតាមច្រករបៀងខុសច្បាប់នៅតែកើតមានគឺបណ្តាលមកពីកម្លាំងសមត្ថកិច្ចឈរជើងតាមបន្ទាត់ព្រំដែនឃុបឃិតជាមួយមេខ្យល់ ហើយកម្លាំងនិងមន្ត្រីជំនាញដើរដាក់ខែជាមួយមេខ្យល់ឬបង់ចំនួនពលករម្នាក់១៥,០០០រៀលទៅ២០.០០០រៀល អាច១ខែមេខ្យល់ម្នាក់បង់១លានទៅ២លានរៀលជាប្រចាំខែបើមិនបង់គឺចាប់ពលករអប់រំឱ្យត្រឡប់ទៅវិញ តែមេខ្យល់រួចខ្លួនរហូតនៅតែបន្តរកស៊ីដោយរលូន ៕ ចន្ត្រា

## សមត្ថកិច្ចបញ្ជូនខ្លួនមនុស្សប្រុសស្រី៣នាក់ ក្នុងចំណោម៥នាក់ ទៅតុលាការ រឿងបើកហាងកោសជប់ បន្ទប់សេវាផ្លូវភេទ

https://www.khmernews.news/ By chan veasna May 25, 2018

រាជធានីភ្នំពេញ៖ ព្រឹកថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨នេះ សមត្ថកិច្ចនាយកដ្ឋានប្រឆាំងការជួញដូរ និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានបញ្ជូនខ្លួនថៅកែហាងកោសជប់ យីហោ១៦៨ ហេង ហេង ២នាក់ប្តីប្រពន្ធ និងស្ត្រីមេកាម្នាក់ ទៅកាន់សាលាដំបូងរាជធានីភ្នំពេញ។ ក្នុងនោះសមត្ថកិច្ច បានចុះបង្ក្រាបឃាត់ខ្លួន បានជនសង្ស័យចំនួន៥នាក់ ជនសង្ស័យជាថៅកែហាង ឈ្មោះ សួង វាសនា ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិខ្មែរជាប្តី និងឈ្មោះ វ៉ា ធានី ភេទស្រី អាយុ៣០ឆ្នាំ ជនជាតិខ្មែរជាប្រពន្ធ។ ចំណែកស្ត្រីជនសង្ស័យ ជាមេកាម្នាក់ទៀត មិនទាន់មានការបញ្ជាក់អំពីអត្តសញ្ញាណ ប៉ុន្តែក្រោយពីនាំយកទៅសាកសួរ និងកសាងសំណុំរឿងបញ្ជូនទៅកាន់តុលាការ គេឃើញមានតែជនសង្ស័យ៣នាក់ប៉ុណ្ណោះ។

## ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨

## សមត្ថកិច្ចអន្តរាគមន៍ករណីធ្វើទារុណកម្មលើក្មេងឈ្នួលរយៈពេល៤ឆ្នាំទើបបែកធ្លាយ

http://www.rasmeinews.com/ May 28, 2018, 8:26 AM

*ដោយៈចាន់តូ/ភ្នំពេញ*.ក្មេងស្រីម្នាក់ជាកូនឈ្នួល បម្រើការងារនៅផ្ទះអ្នកលក់សម្លៀកបំពាក់មួយកន្លែង ផ្ទះលេខ១៧អា ជាប់ផ្សារបុរីសន្តិភាព២ ភូមិតំណាក់ត្រយឹង សង្កាត់ចោមចៅ២ ខណ្ឌពោធិសែនជ័យ ។ក្មេងស្រីម្នាក់ត្រូវ

បានស្ត្រីម្ចាស់ផ្ទះ ប្រើអំពើហឹង្សា ធ្វើទារុណកម្ម សឹងរាល់ថ្ងៃ វាយ ចាក់ ឈានដល់បង្អត់បាយ ជារឿយៗ ។ អស់រយៈពេល៤ឆ្នាំ ដោយទង្វើសាហាវពេក ទើបនៅវេលាម៉ោង៥ល្ងាច ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៨នេះ បែកធ្លាយរឿងពលរដ្ឋក្បែរខាងរាយការណ៍ សមត្ថកិច្ចចុះទៅអន្តរាគមន៍ រំដោះក្មេងស្រី ចេញពីផ្ទះកើតហេតុ និងឃាត់នាំស្ត្រីសង្ស័យទៅសាកសួរនៅប៉ុស្តិ៍ ។ ក្មេងស្រីរងគ្រោះឈ្មោះជាស្រីនូហៅស្រីពៅអាយុ១៦ឆ្នាំមករស់នៅផ្ទះកើតហេតុខាងលើរយៈពេល៤ឆ្នាំមកហើយ មានស្រុកកំណើតភូមិទំនប់ថ្មី ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ ចំណែកស្ត្រីចិត្តកំណាច មានឈ្មោះ ម៉េង រ័ត្នពិសី ហៅ ភា អាយុ៣៣ឆ្នាំ មុខរបរលក់សម្លៀកបំពាក់ នៅផ្ទះកើតហេតុ។ បើតាមអ្នកក្បែរខាងថា ជាជនជាតិវៀតណាម កាត់ចិន មានប្តី ឈ្មោះ សុខ ទី អាយុ៣៣ឆ្នាំ មុខរបរ លក់សម្លៀកបំពាក់ មានកូនស្រីម្នាក់ក្នុងបន្ទុក ។

តាមការរៀបរាប់របស់ក្មេងស្រីរងគ្រោះ ទាំងទឹកភ្នែក ក្នុងអារម្មណ៍ភ័យញ័រ ប្រាប់នៅចំពោះមុខសមត្ថកិច្ចថា គាត់ត្រូវបានស្ត្រីខាងលើ យកមកឲ្យធ្វើការងារ តាំងពីអាយុ១២ឆ្នាំមកម្លេះ ធ្វើជាកូនឈ្នួលបម្រើ ផ្ទះខាងលើ រហូតមកដល់ពេលនេះ អស់រយៈពេល៤ឆ្នាំហើយ។ ស្ត្រីម្ចាស់ផ្ទះ បង្ខំឲ្យធ្វើការងារ តាំងពីព្រឹកទល់យប់ បើធ្វើមិនទាន់ ប្រដាប់ដោយដែក វាយ ពេញរាងកាយ ក្បាល ជួន យកម្ជុលដេប៉ាក់ មកចាក់ លើរាងកាយ ក្នុង១ថ្ងៃៗ ឲ្យហូបបាយ២ពេល ពេលព្រឹក និងពេលល្ងាច ថ្ងៃត្រង់បន្តឲ្យធ្វើការងារ ។ ក្មេងស្រីរងគ្រោះបានបន្តទៀតថា មកស្នាក់នៅធ្វើការដំបូង បានប្រាក់ឈ្នួល ៦០ដុល្លារក្នុង១ខែ ។ទើបតែ១ឆ្នាំមកនេះ បាន១០០ដុល្លារក្នុង១ខែ ហើយខែថ្មីនេះ ម្តាយនាងមានការខ្វះខាត ថវិកាទិញថ្នាំ ព្យាបាលឪពុក បានសុំខ្ចីលុយ១០០ដុល្លារមុន ។ អ្វីជាងនេះទៅទៀត ម្ចាស់ផ្ទះដាក់បម្រាម មិនឲ្យនិយាយរឿងធ្វើទារុណកម្មរាងកាយប្រាប់អ្នកជិតខាងឬប្រាប់ដំណឹងដល់ក្រុមគ្រួសារនៅឯស្រុកឡើយនិង មិនអនុញ្ញាតឲ្យ ជួបនិយាយជាមួយម្តាយតាមទូរស័ព្ទទេ ។ ក្រោយមានការបំភ្លឺពីក្មេងរងគ្រោះ សមត្ថកិច្ចហៅនាំខ្លួនស្ត្រីសង្ស័យទៅសាកសួរនៅប៉ុស្តិ៍ និងផ្អែកលើភស្តុតាង ស្លាកស្នាម ជាំ របួស ពេញខ្លួន ក្បាល ដៃ ជើង សមត្ថកិច្ចឃាត់ខ្លួនជនសង្ស័យ កសាងសំណុំរឿងបញ្ជូនទៅផ្នែកជំនាញ ចាត់ការបន្តតាមនីតិវិធី ៕S/

## សាលាដំបូងខេត្តកំពង់ចាម ឃុំខ្លួនស្ត្រីម្នាក់ ជួញដូរមនុស្សឆ្លងដែនទៅប្រទេសចិន

http://www.cen.com.kh/archives/ May 28, 2018

កំពង់ចាម ៖ ស្ត្រីម្នាក់ដែលជាប់ពាក់ព័ន្ធនឹងការជួញដូរមនុស្សឆ្លងដែនទៅប្រទេសចិន ត្រូវបានលោកស្រី លី ម៉ារីណា ចៅក្រមស៊ើបសួរ សាលាដំបូងខេត្តកំពង់ចាម នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៨ បានសម្រេចចេញដីកាបង្គាប់ឲ្យឃុំខ្លួន ដោយចោទប្រកាន់ពីបទនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន យោងទៅតាមមាត្រា១១នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលបានប្រព្រឹត្តក្នុងការនាំល្បួងលួងលោមក្មេងស្រីម្នាក់ យកទៅប្រទេសចិន នៅភូមិក្រដាស់(ខ) ឃុំតាំងក្រសាំង ស្រុកបាធាយ ខេត្តកំពង់ចាម កាលពីអំឡុងខែកុម្ភៈ ឆ្នាំ២០១៧។

សូមរំលឹកផងដែរថាៈ កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បានទទួលពាក្យបណ្តឹងពីម្តាយជនរងគ្រោះ ប្តឹងឈ្មោះ ឈៀង លី ភេទស្រី អាយុ៤៥ឆ្នាំ នៅភូមិក្រដាស់(ក) ឃុំតាំងក្រសាំង ស្រុកបាធាយ ខេត្តកំពង់ចាម ដែលបាននាំជនរងគ្រោះឆ្លងដែនដោយខុសច្បាប់ យកចេញទៅប្រទេសចិនដើម្បីលក់ឱ្យបុរសជនជាតិចិនធ្វើជាប្រពន្ធ។ បច្ចុប្បន្ន ជនរងគ្រោះត្រូវបានសមត្ថកិច្ចចិន ជួយសង្គ្រោះ និង បញ្ជូនមកប្រទេសកម្ពុជាវិញ កាលពីថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១៧ តាមច្រកទ្វារអន្តរជាតិភ្នំពេញ។ ក្រោយពីទទួលបានពាក្យបណ្តឹង កម្លាំងរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន សហការជាមួយកម្លាំងរបស់ការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនខេត្តកំពង់ចាមបានចុះធ្វើការស្រាវជ្រាវស៊ើបអង្កេត និង ចងក្រងសំណុំរឿងតាមនីតិវិធី បញ្ជូនទៅអយ្យការ អមសាលាដំបូងខេត្តកំពង់ចាម ដើម្បីចាត់ការតាមច្បាប់។ លុះដល់ថ្ងៃទី២៤ ខែឧសភា

ឆ្នាំ២០១៨ កម្លាំងរបស់ការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បានចុះបង្រ្កាបតាមដីកាបញ្ជាឱ្យចូលខ្លួន របស់អយ្យការ អមសាលាដំបូងខេត្តកំពង់ចាម ហើយបានធ្វើការឃាត់ខ្លួនជនសង្ស័យម្នាក់ ឈ្មោះ ឈៀង លី បញ្ជូនទៅអយ្យការអមសាលាដំបូងខេត្តកំពង់ចាម ដើម្បីចាត់ការតាមច្បាប់។

យោងតាមដីកាបង្គាប់របស់លោកស្រី លី ម៉ារីណា ចៅក្រមស៊ើបសួរ សាលាដំបូងខេត្តកំពង់ចាម ប្រធានពន្ធនាគារខេត្តកំពង់ចាម បានទទួលយកជនជាប់ចោទពីសមត្ថកិច្ច ហើយបញ្ជូនទៅឃុំខ្លួននៅពន្ធនាគារខេត្តកំពង់ចាម រួចរាល់ហើយ នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៨ ។ ដោយៈបញ្ញាស័ក្តិ

## ស្ថានតំណាងកម្ពុជាបានជួយពលរដ្ឋខ្មែរ២៨នាក់ធ្វើការដោយខុសច្បាប់នៅក្រៅប្រទេស

https://wmc.org.kh/ ថ្ងៃសៅរ៍ ទី២៦ ខែឧសភា ឆ្នាំ២០១៨ ជុំ ជោគជាតា

ភ្នំពេញៈតាមសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិបានឱ្យដឹងថា ស្ថានតំណាងកម្ពុជានៅប្រទេសចំនួន ៤ បានជួយសង្គ្រោះពលរដ្ឋខ្មែរចំនួន ២៨នាក់ ត្រឡប់មកកម្ពុជាវិញ។ តាមសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិចុះផ្សាយនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៨នេះ បញ្ជាក់ថា ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃបានសហការជាមួយអាជ្ញាធរថៃ រៀបចំមាតុភូមិនិវត្តន៍របស់អនីតិជនខ្មែរចំនួន ៦នាក់ មានអាយុចន្លោះពី១០ឆ្នាំ ដល់ ១៦ឆ្នាំ ដែលទទួលរងគ្រោះដោយការជួញដូរមនុស្ស ត្រឡប់មកកម្ពុជាវិញតាមច្រកអន្តរជាតិប៉ោយប៉ែតកាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៨។

ដោយឡែក ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី បានសហការជាមួយអាជ្ញាធររបស់ប្រទេសម៉ាឡេស៊ី ដោះស្រាយបញ្ហានិងរៀបចំមាតុភូមិនិវត្តន៍របសពលរដ្ឋខ្មែរចំនួន ១២នាក់ មកពីខេត្តកំពត កំពង់ឆ្នាំង កំពង់ធំ កំពង់ចាម ត្បូងឃ្មុំ បាត់ដំបង និងព្រះវិហារ ដែលក្នុងនោះពលករមានចំនួន ៥នាក់ និងពលការិនី ៦នាក់ ដែលបានទៅធ្វើការដោយខុសច្បាប់នៅប្រទេសម៉ាឡេស៊ី និង ១នាក ជាកុមារ។ ពលរដ្ឋទាំង ១២នាក់នោះ បានមកដល់កម្ពុជាវិញជាបន្តបន្ទាប់ចន្លោះពីថ្ងៃទី០៥ ដល់ថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០១៨ ។

ស្របជាមួយគ្នានេះ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសសិង្ហបូរី បានជួយរៀបចំមាតុភូមិនិវត្តន៍របស់ពលការិនីខ្មែរ ១នាក អាយុ ២៥ឆ្នាំ មកពីខេត្តកំពង់ធំ ដែលបានទៅបម្រើការងារជាជំនួយការមេផ្ទះនៅ ប្រទេសសឹង្ហបូរី កាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៨ តែមិនអាចទ្រាំការងារលំបាកនៅទីនោះបាន។ ស្ថានទូតបានផ្តល់កន្លែងស្នាក់នៅ អាហារបរិភោគ និងជួយទាមទារលិខិតឆ្លងដែន រួមទាំងសំបុត្រយន្តហោះពីភ្នាក់ងារនាំពលករ ហើយពលការិនីរូបនេះ បានមកដល់កម្ពុជាវិញ នៅថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១៨។

ចំណែកស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំតំបន់ស្វយ័តជនជាតិក្វាំងស៊ី ទីក្រុងណាននីង ប្រទេសចិន បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសចិន រៀបចំមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរចំនួន៩នាក់ ក្នុងនោះស្ត្រី ៨នាក់ មកពីខេត្តកណ្តាល កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ ក្រចេះ និងព្រៃវែង ដែលត្រូវបានមេខ្យល់នាំធ្វើដំណើរពីកម្ពុជាទៅរៀបការនិងស្នាក់នៅដោយខុសច្បាប់នៅក្នុងប្រទេសចិន។ក្រៅពីនេះស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំតំបន់ស្វយ័តជនជាតិក្វាំងស៊ីក៏បានជួយសង្គ្រោះបុរស១នាក់ មកពីខេត្តកំពង់ស្ពឺដែលចូលទៅធ្វើការក្នុងប្រទេសចិនដោយខុសច្បាប់ផងដែរ។ ពលរដ្ឋខ្មែរចំនួន ៩នាក់ខាងលើ បានត្រឡប់មកកម្ពុជាវិញនៅព្រឹកថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០១៨៕

## តម្រួតថៃឃាត់ខ្លួនអ្នកបើកបររត់ទូ ល្មោភកាម រំលោភពលការិនីខ្មែរ

http://www.pheaktraprak.com/ May 26, 2018

ជនជាតិថៃម្នាក់ ដែលមានមុខរបរជាអ្នកបើកបររថយន្ត ដឹកអ្នកដំណើរត្រូវបានកំលាំងតម្រួតថៃ ធ្វើការឃាត់ខ្លួន ដោយយោងទៅលើពាក្យបណ្តឹងរបស់ជនរងគ្រោះដែលជាពលការិនីខ្មែរ ដោយបានចោទប្រកាន់ទៅលើបុរសម្នាក់ថា បានចាប់រំលោភខ្លួនរហូតបានសម្រេចនៅក្នុងរថយន្ត ខណៈដែលខ្លួនបានធ្វើដំណើរវិលត្រឡប់មកលេងស្រុកកំណើត ។ការឃាត់ខ្លួននេះបានធ្វើឡើងកាលពីថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៨ វេលាម៉ោង៣រសៀល នៅលើកំណាត់ផ្លូវទៅកាន់សណ្ឋាគារ ៩១ កណ្តាលទីរួមស្រុក វាំងណាំយិនខេត្តស្រះកែវ ប្រទេសថៃ ដែលជនសង្ស័យរូបនេះមានឈ្មោះ សុង សុមផាត់ ភេទប្រុសអាយុ៥២ឆ្នាំ រស់នៅភូមិ ៥ ឃុំ សែថង ស្រុក ខ្លងហាត ខេត្តស្រះកែវ មានមុខរបរជាអ្នកបើកបររថយន្តតួរីស ដឹកអ្នកដំណើរលេខ ស្រះកែវ ១០.០៧៩៧ រត់លើផ្លូវពីផ្សាររោងក្លឿ ទៅកាន់ ផាតាយ៉ា ។បើតាមការអះអាងពីនារីរងគ្រោះ ដែលជាពលការិនីកម្ពុជា អាយុ៣៣ឆ្នាំ ទៅធ្វើការនៅក្នុងប្រទេសថៃ បាននិយាយថា កាលពីថ្ងៃទី២៤ ខែ ឧសភា នាងបានធ្វើដំណើរតាមរថយន្តនេះ ក្នុងទិសដៅពី កាប៊ីនបុរី ទៅកាន់ផ្សាររោងក្លឿ ក្នុងស្រុកអារញ្ញប្រាថេត ដើម្បីទៅលេងស្រុកកំណើត នៅឯកម្ពុជា ។គឺនៅពេលនោះគេបានបើករថយន្តទៅបញ្ចូលហ្គាសប៉ុន្តែលុះដល់កន្លែងស្ងាត់ អ្នកបើកបរក៏បានចាប់ខ្លួនរំលោភនៅលើកៅអីខាងក្នុងរថយន្តនោះរហូតបានសម្រេច ។

ក្រោយមកនាងក៏បានទូរស័ព្ទទៅប្រាប់ស្វាមី ( រស់នៅក្នុងប្រទេសថៃដូចគ្នា ) ដើម្បីដាក់ពាក្យប្តឹងទៅសមត្ថកិច្ច ។ក្រោយពេលចាប់ខ្លួនដើម្បីយកមកសាកសួរ នៅក្នុងស្ថានីយ៍តម្រួត វាំងណាំយិនគឺមានក្រុមគ្រួសារ សាច់ញាតិ របស់ជនសង្ស័យ ពិសេសក៏មានលោក វាសនា ពោធិថងមេឃុំសែថង ផងដែរ សរុបប្រមាណ ជិត១០នាក់ បានធ្វើដំណើរមកកាន់ស្ថានីយ៍តម្រួត ដើម្បីចរចារ និងទាក់ទងសុំធានាខ្លួនជនសង្ស័យរូបនេះអោយមានសេរីភាព លើកលែងពីការឃុំខ្លួន ។អ្វីដែលពិតប្រាកដនោះគឺ នៅម៉ោង១០ ព្រឹកថ្ងៃទី២៦ នេះ ក្រុមតម្រួតបានធ្វើការឃុំខ្លួនបុរសដែលជាអ្នកបើកបររថយន្តជាបណ្តោះអាសន្នសិន ដោយមិនអោយលើសពី២៤ម៉ោងនោះឡើយ ដើម្បីនាំយកនារីរងគ្រោះដែលជាជនជាតិខ្មែរទៅកាន់មន្ទីរពេទ្យ វាំងណាំយិនក្នុងការពិនិត្យទៅតាមបច្ចេកវិទ្យា D N A លើរូបរាងកាយ និងលើអ្វីដែលពាក់ព័ន្ធនឹងករណីរំលោភនេះ ។ ជាចុងក្រោយក្រុមតម្រួតថៃ ក៏បានអនុញ្ញាតអោយសាច់ញាតិ និង ក្រុមគ្រួសាររបស់ជនបង្ក អាចមានសិទ្ធិធានាខ្លួនបានដោយកំណត់អោយដំកល់ប្រាក់ចំនួន ២០០ ០០០បាត( ពីរសែនបាត ) ដោយនៅពេលនេះដែរគឺក្រុមគ្រួសារកំពុងពិភាក្សាគ្នាក្នុងការរកប្រាក់មកដំកល់ ៕

## ពលករខ្មែរជាង១០នាក់ ត្រូវបានតម្រួតដោះលែងវិញអស់ហើយ បន្ទាប់ពីតម្រួតចាប់យកទៅរោងផាក

http://www.pheaktraprak.com/ May 25, 2018

នៅពីវេលាម៉ោង០១រសៀលថ្ងៃសុក្រទី២៥ខែឧសភាឆ្នាំ២០៨ មានករណីពលករខ្មែរ មួយក្រុមមានគ្នាប្រមាណជាង១០នាក់ ត្រូវកម្លាំងតម្រួតថៃចាប់ខ្លួនយកទៅកាន់រោងផាក់ យោងតាមប្រភពម្ចាស់អាខោនហ្វេសប៊ុកឈ្មោះ ផល សុខា បានរៀបរាប់តាម facebook live ថាគាត់ទាំងអស់គ្នាមានឯកសារធ្វើការត្រឹមត្រូវតែនៅត្រូវតម្រួតចាប់យកទៅប៉ុស្តិ៍ទៀតធ្វើះអោយពួកគាត់មានការងឿងឆ្ងល់យ៉ាងខ្លាំថាហេតុអ្វីបានជាមានឯកសារហើយនៅត្រូវតម្រួតចាប់ទៀត។ នៅវេលាម៉ោង០៥ល្ងាច ម្ចាស់អាខោនហ្វេសប៊ុកដដែលបានឡាយវីដេអូម្តងទៀតប្រាប់ពីហេតុការណ៍ដែលពួកគាត់ត្រូវតម្រួតដោះលែងមកវិញគឺដោយសារថៅកែពួកទៅលួសចេញពីប៉ុស្តិ៍តម្រួត។

ករណីខាងលើនេះបានធ្វើឲ្យពលករខ្មែរធ្វើការនៅប្រទេសថៃមានការងឿងឆ្ងល់យ៉ាងខ្លាំង ព្រោះគាត់មានឯកសារត្រឹមត្រូវហើយតែហេតុអ្វីត្រូវតម្រួតចាប់យកទៅប៉ុស្តិ៍ទៀត បើតាមសន្និដ្ឋានរបស់ខ្ញុំប្រហែលជាពួកនៅធ្វើការកន្លែងផ្សេងហើយនៅពេល សមត្ថកិច្ចចាប់មិនមានថៅកែចេញមកបកស្រាយ ព្រោះនៅពេលសមត្ថកិច្ចចុះចាប់តែងតែសួររកថៅកែ ខណៈពេលនោះប្រហែលជាថៅកែគាត់មិននៅទើបសមត្ថកិច្ចចាប់យកទៅប៉ុស្តិ៍ដើម្បីឲ្យថៅកែពិតប្រាកដទៅបង្ហាញខ្លួនទើបសម្ថកិច្ចព្រមដោះលែង។

## សិក្ខាសាលាស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅប្រទេសថៃ"

https://www.facebook.com/ **Sompong Srakaew** is with Prak PheakTra May 26 at 6:15pm • Bangkok, Thailand •

សូមគោរពអញ្ជើញសារព័ត៌មានជាតិ និងអន្តរជាតិចូលរួមសិក្ខាសាលាប្រជុំស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅប្រទេសថៃ" នេះជាលើកទី 1 ហើយដែលអង្គការក្រៅរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលនានាក្នុងប្រទេសថៃបានធ្វើសិក្ខាសាលានេះឡើងស្តីពីការពារសិទ្ធិជនរងគ្រោះដោយសារការជួញដូរមនុស្សនៅក្នុងប្រទេសថៃ. លើប្រធានបទការពារស្ត្រី កុមារនិងពលករដែលកំពុងធ្វើការនៅក្នុងប្រទេសថៃទាំងអស់ដែលរងគ្រោះដោយសារអំពើជួញដូរមនុស្សខ្លឹមសារនៃសិក្ខាសាលាខាលើកនេះគឺសង្កត់ធ្ងន់ក្នុងការជួយអន្តរាគមន៍ដល់ជនរងគ្រោះអោយរួចផុតពីការជួយដូរ និងការកៀបសង្កត់លើកំលាំងពលកម្ម ព្រមទាំងលើកកម្ពស់ជីវភាពនិងសិទ្ធិសេរីភាព. របស់ជនរងគ្រោះអោយទទួល បាននូវសិទ្ធិសេរីភាព ព្រមទាំងមានជីវិតរស់នៅអោយកាន់តែប្រសើឡើងនៅក្នុងសង្គម.សិក្ខាសាលានេះធ្វើឡើងគឺ ចង់ធ្វើការផ្សព្វផ្សាយការប្រយុទ្ធប្រឆាំងនឹងការជិះជាន់លើកម្លាំងពលកម្មនិងការជួញដូរមនុស្សនិងផ្តោតសំខាន់គឺការពារជនរងគ្រោះអោយជៀសផុតពីការជិះជាន់ពលកម្មនិងការជួយដូរមនុស្សដើម្បីអោយជនរងគ្រោះទទួលបាននូវការ ការពារនិងទទួលបានសិទ្ធក្នុងការងារអោយបានស្របច្បាប់ ដែលពលករខ្មែរមកធ្វើការក្នុងប្រទេថៃត្រូវតែទទួលបាននូវសិទ្ធការពារសូមអញ្ជើញអ្នកដែលមានការពាក់ពន្ធ័ទាំងអស់ ដែលចាប់អារម្មណ៍ក្នុងការចូលរួមសិក្ខាសាលានេះក្នុងន័យការប្រយុទ្ធប្រឆាំងការជិះជាន់កំលាំងពលកម្ម ការជួញដូរមនុស្សនិងការពារជនរងគ្រោះនៅក្នុងប្រទេសថៃនិងសហគមន៍អាស៊ានទាំងមូល សិក្ខានេះចាប់ផ្តើមប្រជុំនៅថ្ងៃពុធទី៣០ខែឧសភាឆ្នាំ២០១៨ នៅសាលប្រជុំជាន់ទី 8 បន្ទប់ 801 អគារ Chalerm Mahanakorn ខួបលើកទី 60(អាគារចាំជូរីទី 10) នៃសាកលវិទ្យាល័យជូឡាឡុងកន ប្រទេសថៃ។ ទំនាក់ទំនងចុះឈ្មោះចូលរួមប្រជុំតាមរយៈលេខទូរស័ព្ទ 085 765 1025 (ប៊ីងប៉ង់) លោក Sompong Srakaew 086 163 1390 អ៊ីម៉ែល: sompongIpn@gmail.com, saranyamailto@gmail.com

## ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៨
## ការងារចំនួន ១២ ប្រភេទត្រៀមប្រកាសអញ្ញាតឲ្យពលករបរទេសធ្វើបាន

http://www.prakpheaktra.com/ May 28, 2018

ថៃ៖ ការងារចំនួន ១២ ប្រភេទថ្មី ត្រៀមប្រកាសអនុញ្ញាតឲ្យពលកបរទេសអាចធ្វើការបាន៖

១-ការងារកម្មករ ២-ការងាជាងករអិត ៣-ការងារកសិកម្ម ៤-ការងារផ្នែកបញ្ចី

៥-ការងារធ្វើកាំបិត ៦-ការងារធ្វើពូក ៧-ការងារធ្វើស្បែកជើង ៨-ការងារធ្វើមួក

៩-ការងារវិស្វកម្ម ១០-ការងារវិស្វករ ១១-ការងារកែផ្ទៃម៉ូត ១២-ការងារប៉ានធ្វើថូជី,ឆ្នាំងដី

ប្រភពពី÷PPTVHD36 ២៨-០៥-២០១៨

# ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨
# ក្រសួង ប្រាប់កម្មករការងារផ្ទះឲ្យធ្វើកិច្ចសន្យាដោយបំពេញលក្ខខណ្ឌ១១ចំណុច

http://kleykley.sabay.com.kh/ ម៉ោង 11:39

យោងតាមសេចក្តីប្រកាស ស្តីពីលក្ខខណ្ឌការងារសម្រាប់កម្មករការងារផ្ទះ ចុះហត្ថលេខាថ្ងៃទី២៩ឧសភាឆ្នាំ២០១៨ ដោយលោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបង្ហាញពីលក្ខខណ្ឌ១១ចំណុច សម្រាប់កិច្ចសន្យាជាលាយលក្ខណ៍អក្សររវាងកម្មករការងារផ្ទះ និងនិយោជក។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- ឈ្មោះ និងអាសយដ្ឋាន របស់និយោជក និងកម្មករការងារផ្ទះ

២- អាសយដ្ឋាននៃកន្លែងធ្វើការងារ

៣- កាលបរិច្ឆេទចាប់ផ្តើម

៤- ប្រភេទការងារដែលត្រូវបំពេញ

៥- ប្រាក់ឈ្នួល របៀបគិតប្រាក់ឈ្នួល និងការកំណត់អំពីការបើកប្រាក់ឈ្នួល

៦- ម៉ោងធ្វើការធម្មតា

៧- ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល និងការឈប់សម្រាកប្រចាំថ្ងៃ និងប្រចាំសប្តាហ៍

៨- ការផ្តល់អាហារ និងកន្លែងស្នាក់នៅ (បើមាន)

៩- រយៈពេលនៃការសាកល្បងការងារ មិនលើសពីមួយខែ (បើមាន)

១០- លក្ខខណ្ឌសម្រាប់ការរៀបចំឲ្យកម្មករការងារផ្ទះត្រឡប់ទៅស្រុក (ផ្ទះ) (បើមាន)

១១- លក្ខខណ្ឌដែលពាក់ព័ន្ធជាមួយនឹងការបញ្ចប់កិច្ចសន្យាការងារ ដូចជារយៈពេលនៃការជូនដំណឹងជាមុនដោយកម្មករការងារផ្ទះ ឬ និយោជក (បើមាន)។

សេចក្តីប្រកាសខាងលើឲ្យដឹងដែរថា កម្មករការងារផ្ទះត្រូវមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ។ ចំណែកក្មេងអាយុចាប់ពី១៥ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ អាចធ្វើការងារផ្ទះណាដែលស្រាលៗ មិនមានលក្ខណៈងាយបង្កគ្រោះថ្នាក់ ឬប៉ះពាល់សុខភាព។ ប្រភពដដែលបន្តថា ក្នុងករណីមានវិវាទ មិនអាចដោះស្រាយបាន ភាគីណាមួយនៃវិវាទអាចប្តឹងទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំពោះអ្នកនៅរាជធានីភ្នំពេញ និងទៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំពោះអ្នកនៅតាមបណ្តាខេត្ត។

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ :......១៣៣៥......ក.ប/ប្រ.ក.ម.ក

# ប្រកាស

# ស្តីពី

# លក្ខខណ្ឌការងារសម្រាប់កម្មករការងារផ្ទះ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបញ្ចប់នឹងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ប្រសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨
- តាមការចាំបាច់របស់ក្រសួង

## ស ម្រេច

**ប្រការ១**.-

ប្រកាសនេះមានគោលបំណងកំណត់អំពីលក្ខខណ្ឌការងារសម្រាប់កម្មករការងារផ្ទះនៅក្នុងព្រះរាជាណាចក្រកម្ពុជា។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩

**ប្រការ២**.-

សម្រាប់គោលដៅនៃប្រកាសនេះ ៖

(ក) ពាក្យថា **ការងារផ្ទះ** សំដៅយកកិច្ចការទាំងឡាយដែលត្រូវប្រតិបត្តិនៅក្នុងរង្វង់គ្រួសារមួយ ឬសម្រាប់គ្រួសារមួយជាកំណត់ដូចជាការបោសសំអាត ការចំអិនអាហារ ការបោកគក់ និងអ៊ុត ការថែទាំកុមារ ការថែទាំមនុស្សចាស់ ការថែទាំសមាជិកគ្រួសារ ការថែទាំសួន ការថែទាំទ្រព្យសម្បត្តិ ការបើកបររថយន្តសម្រាប់គ្រួសារ និងការថែទាំសត្វចិញ្ចឹមក្នុងគ្រួសារជាដើម។

(ខ) ពាក្យថា **កម្មករការងារផ្ទះ** សំដៅយកជនណាដែលទទួលធ្វើកិច្ចការណាមួយ ឬលើសពីមួយនៃការងារផ្ទះដោយស្ម័គ្រចិត្ត និងទទួលកម្រៃ។

(គ) ជនណាម្នាក់គ្រាន់តែទទួលធ្វើកិច្ចការណាមួយ ឬលើសពីមួយនៃការងារផ្ទះម្តងម្កាល ឬ មិនទៀងទាត់ និងមិនឈរលើមូលដ្ឋាននៃវិជ្ជាជីវៈណាមួយ មិនមែនជាកម្មករការងារផ្ទះទេ។

**ប្រការ៣**.-

ប្រកាសនេះអនុវត្តចំពោះកម្មករការងារផ្ទះទាំងអស់។

ប្រកាសនេះមិនអនុវត្តទេចំពោះជនណាដែលត្រូវបានគ្រួសារណាមួយទទួលយកមកឱ្យរស់នៅជាមួយ ហើយត្រូវបានគ្រួសារនេះចាត់ចែងឱ្យជួយធ្វើការងារក្នុងផ្ទះ ដោយទទួលបានសិទ្ធិ ប្រព្រឹត្តិកម្ម ការការពារ និង ផលប្រយោជន៍ដូចគ្នានឹងសមាជិកនីមួយៗនៃគ្រួសារ។

**ប្រការ៤**.-

កម្មករការងារផ្ទះត្រូវមានអាយុចាប់ពី១៨ឆ្នាំឡើង។ ក្មេងអាយុចាប់ពី១៥ឆ្នាំ ដល់ក្រោម១៨ឆ្នាំ អាចអនុញ្ញាតឱ្យធ្វើការងារផ្ទះណាដែលស្រាលៗ មិនមានលក្ខណៈងាយបង្កឱ្យមានគ្រោះថ្នាក់ ឬ ប៉ះពាល់សុខភាព។

**ប្រការ៥**.-

កិច្ចការទាំងឡាយ ដែលត្រូវចាត់ឱ្យកម្មករការងារផ្ទះទទួលធ្វើ ត្រូវតែកំណត់ឱ្យបានច្បាស់នៅក្នុងកិច្ចសន្យាការងារជាលាយលក្ខណ៍អក្សរ។

**ប្រការ៦**.-

ក្នុងករណីកម្មករការងារផ្ទះស្នាក់នៅជាមួយគ្រួសារណាមួយ ដែលជាទីកន្លែងធ្វើការងាររបស់ខ្លួន និយោជកត្រូវផ្តល់ឱ្យកម្មករការងារផ្ទះដោយមិនគិតកម្រៃនូវការហូបចុក ការស្នាក់នៅសមរម្យ និងការពិនិត្យព្យាបាលបឋមនៅពេលមានជំងឺ។

**ប្រការ៧**.-

កម្មករការងារផ្ទះ និងនិយោជកនីមួយៗ ត្រូវធ្វើកិច្ចសន្យាការងារជាលាយលក្ខណ៍អក្សរ

ឱ្យបានស្របទៅតាមបទប្បញ្ញត្តិនៃច្បាប់ និងបទបញ្ញាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

កិច្ចសន្យាការងាររវាងកម្មករការងារផ្ទះ និងនិយោជក ត្រូវកំណត់ឱ្យបានច្បាស់អំពីលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

-ឈ្មោះ និងអាសយដ្ឋាន របស់និយោជក និងកម្មករការងារផ្ទះ។

-អាសយដ្ឋាននៃកន្លែងធ្វើការងារ។

-កាលបរិច្ឆេទចាប់ផ្តើម។

-ប្រភេទការងារដែលត្រូវបំពេញ។

-ប្រាក់ឈ្នួល របៀបគិតប្រាក់ឈ្នួល និងការកំណត់អំពីការបើកប្រាក់ឈ្នួល។

-ម៉ោងធ្វើការធម្មតា។

-ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល និងការឈប់សម្រាកប្រចាំថ្ងៃ និងប្រចាំសប្តាហ៍។

-ការផ្តល់អាហារ និងកន្លែងស្នាក់នៅ (បើមាន)។

-រយៈពេលការសាកល្បងការងារ មិនលើសពីមួយខែ (បើមាន)។

-លក្ខខណ្ឌសម្រាប់ការរៀបចំឱ្យកម្មករការងារផ្ទះត្រឡប់ទៅស្រុក(ផ្ទះ)វិញ (បើមាន)។

-លក្ខខណ្ឌដែលពាក់ព័ន្ធជាមួយនឹងការបញ្ចប់កិច្ចសន្យាការងារដូចជារយៈពេលនៃការជូនដំណឹងជាមុនដោយកម្មករការងារផ្ទះ ឬនិយោជក (បើមាន)។

**ប្រការ៨**.-

និយោជកជាជនបរទេស ដែលស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានកម្មករការងារផ្ទះជាជនជាតិខ្មែរធ្វើការក្នុងគ្រួសារ ឬសម្រាប់គ្រួសាររបស់ខ្លួន ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិនៃប្រកាសនេះ និងបទបញ្ញាពាក់ព័ន្ធនានាជាធរមាន។

**ប្រការ៩**.-

ការឈប់សម្រាកប្រចាំសប្តាហ៍ ត្រូវមានថេរវេលាអប្បបរិមា២៤ម៉ោងបន្តបន្ទាប់។ ជាគោលការណ៍ត្រូវឈប់នៅថ្ងៃអាទិត្យ លើកលែងតែមានការព្រមព្រៀងដោយស្ម័គ្រចិត្តរបស់កម្មករការងារផ្ទះ ការឈប់សម្រាកនេះអាចធ្វើឡើងនៅក្នុងថ្ងៃណាមួយក៏បាននៅក្នុងសប្តាហ៍ដដែល។

បទប្បញ្ញត្តិនៃប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួល ត្រូវយកមកអនុវត្តចំពោះកម្មករការងារផ្ទះ។

កម្មករការងារផ្ទះដែលធ្វើការងារនៅថ្ងៃឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួល ត្រូវទទួលបានប្រាក់ឈ្នួលស្មើនឹង២០០ (ពីររយ) ភាគរយនៃប្រាក់ឈ្នួលនៃថ្ងៃធ្វើការងារធម្មតា។

**ប្រការ១០.-**

និយោជកត្រូវបើកប្រាក់ឈ្នួលជាសាច់ប្រាក់ ជូនកម្មករការងារផ្ទះដោយផ្ទាល់ ឬតាមធនាគារដោយផ្អែកទៅលើការព្រមព្រៀងគ្នាដោយស្ម័គ្រចិត្តរវាងកម្មករការងារផ្ទះ និងនិយោជក។ ការបើកប្រាក់ឈ្នួលសម្រាប់កម្មករការងារផ្ទះសម្រាប់ខែនីមួយៗ ត្រូវធ្វើឡើងនៅថ្ងៃធ្វើការដោយត្រូវមានការជូនដំណឹងជាមុនអំពីថ្ងៃបើកប្រាក់ឈ្នួលនេះ។ ការបើកប្រាក់ឈ្នួលនេះអាចធ្វើឡើងរៀងរាល់១៥ថ្ងៃម្តង ក្នុងករណីមានការស្នើសុំពីកម្មករការងារផ្ទះ ឬមានចែងនៅក្នុងកិច្ចសន្យាការងារ។

**ប្រការ១១.-**

រាល់វិវាទការងារដែលបានកើតឡើងរវាងកម្មករការងារផ្ទះជាមួយនឹងនិយោជក ភាគីទាំងពីរនៃវិវាទត្រូវតែយកចិត្តទុកដាក់ដោះស្រាយឱ្យអស់លទ្ធភាពដោយមធ្យោបាយសន្តិវិធី។ ក្នុងករណីមិនសះជា ភាគីណាមួយនៃវិវាទអាចប្តឹងមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំពោះអ្នកនៅរាជធានីភ្នំពេញ និងមកមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំពោះអ្នកនៅខេត្ត។

ការដោះស្រាយវិវាទការងាររវាងកម្មករការងារផ្ទះ និងនិយោជក ត្រូវតែធ្វើឡើងដោយអនុលោមតាមកិច្ចសន្យាការងារដែលបានចុះហត្ថលេខារវាងគូភាគី បទប្បញ្ញត្តិទាក់ទងនឹងការងារ និងបទបញ្ញាផ្សេងៗជាធរមាន។

ក្នុងករណីវិវាទការងារនេះនៅតែមិនសះជា ភាគីណាមួយនៃវិវាទអាចប្តឹងទៅតុលាការ។

**ប្រការ១២.-**

រាល់ការងារផ្ទះ ដែលមានលក្ខណៈជាការងារដោយបង្ខំឬជាកាតព្វកិច្ច ការងារកាត់ជំពាក់ការងារមានលក្ខណៈជាទម្រង់ធ្ងន់ធ្ងរ និងបែបទាសភាព ត្រូវបានហាមឃាត់។

**ប្រការ១៣.-**

និយោជក ត្រូវទទួលខុសត្រូវលើគ្រោះថ្នាក់ការងារទាំងអស់លើកម្មករការងារផ្ទះ និងរបបសន្តិសុខសង្គម ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធ នៃព្រះរាជាណាចក្រកម្ពុជា ដូចកម្មករនិយោជិតផ្សេងៗទៀតដែរ។

**ប្រការ១៤.-**

អ្នកប្រព្រឹត្តិល្មើសទៅនឹងប្រកាសនេះ ត្រូវទទួលការដាក់ពិន័យ ឬផ្តន្ទាទោសដូចមានចែងក្នុងច្បាប់ និងបទបញ្ញាជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ១៥.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អគ្គាធិការនៃអគ្គាធិការដ្ឋាន អង្គភាពក្រោមចំណុះក្រសួង និង ទីភ្នាក់ងារជាតិមុខរបរ និងការងារ ត្រូវអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ អង្គារ ១៥កើត ខែ ជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

***កន្លែងទទួល៖***

*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ*
*-គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ*
*-ដូចប្រការ១៥*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

## ក្រសួងការងារចេញប្រកាស ស្តីពី លក្ខខណ្ឌសម្រាប់អ្នកបម្រើការងារតាមផ្ទះ ចំពេលផ្ទុះករណីហិង្សាលើក្មេងស្រីម្នាក់

http://km.rfi.fr/cambodia ដោយ វ៉ា សំណព្វ30/05/201830/05/2018

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កាលពីថ្ងៃទី ២៩ ឧសភា បានចេញប្រកាសមួយ ស្តីពី លក្ខខណ្ឌការងារសម្រាប់កម្មករការងារផ្ទះ។ អ្វីជាការកត់សំគាល់ ប្រកាសរបស់ក្រសួងការងារនៅពេលនេះ បានកើតឡើងជួនចំពេលដែលមានផ្ទុះករណីហិង្សាពីស្ត្រីម្ចាស់ផ្ទះម្នាក់ទៅលើក្មេងស្រីជាកម្មករបម្រើការងារតាមផ្ទះ។ បច្ចុប្បន្នស្ត្រីរូបនោះកំពុងត្រូវបានបញ្ជូនខ្លួនទៅកាន់តុលាការក្រុងភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីច្បាប់។

ប្រកាសរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ មានចំនួន១៥ប្រការ ដែលបានចែងលំម្អិតអំពីការការពារសិទ្ធិរបស់កម្មករបម្រើការងារតាមផ្ទះ រួមទាំងការផ្តល់សិទ្ធិកាន់តែទូលំទូលាយថែមទៀត ដូចគ្នានឹង កម្មករ-កម្មការិនី ដែលបំរើការងារនៅតាមរោងចក្រសហគ្រាសផ្សេងៗដែរ។ ប្រការ៤នៃប្រកាសរបស់ក្រសួងការងារបានចែងថា កម្មករការងារផ្ទះ ត្រូវមានអាយុចាប់ពី១៨ឆ្នាំឡើង។ ហើយបើក្មេងអាយុចាប់ពី១៥ឆ្នាំដល់ក្រោម១៨ឆ្នាំ អាចអនុញ្ញាតឲ្យធ្វើការងារផ្ទះណាដែលស្រាលៗនិងមិនមានលក្ខណៈងាយបង្កឲ្យមានគ្រោះថ្នាក់ ឬ ប៉ះពាល់ដល់សុខភាពឡើយ។ ប្រកាសនេះ ក៏មានចែងពីកាតព្វកិច្ចរបស់ម្ចាស់ផ្ទះ និងកម្មករការងារផ្ទះ ដែលមានចែងនៅក្នុងច្បាប់ការងាររបស់កម្ពុជា ពិសេសទាក់ទងនឹងអត្ថប្រយោជន៍ ការឈប់សម្រាកប្រចាំសប្តាហ៍ និងការទទួលខុសត្រូវលើគ្រោះថ្នាក់ការងារជាដើម។ ប្រការ

១៤នៃប្រកាសនេះ បានចែងថា អ្នកប្រព្រឹត្តល្មើសទៅនឹងប្រកាសនេះ ត្រូវទទួលការផាកពិន័យ ឬផ្តន្ទាទោសដូចមានចែងក្នុងច្បាប់ និងបទបញ្ញាជាធរមាន។

គួរជំរាបជូនថា នេះគឺជាលើកទី១ហើយ ដែលក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញប្រកាសស្តីពីលក្ខខណ្ឌការងារសម្រាប់កម្មករការងារផ្ទះ បន្ទាប់ពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានអំពាវនាវឲ្យមានការបង្កើតយន្តការមួយ ដើម្បីការពារដល់កម្មករដែលបម្រើការងារតាមផ្ទះ។ បន្ថែមលើការកត់សំគាល់នេះ ការចេញប្រកាសរបស់ក្រសួងការងារនៅពេលនេះ បានកើតឡើង ចំពេលដែលមានផ្ទុះករណីហិង្សាពីស្ត្រីម្ចាស់ផ្ទះម្នាក់ ដែលបានវាយធ្វើបាបទៅលើក្មេងស្រីអាយុ១៦ឆ្នាំ ដែលជាកូនឈ្នួលរបស់ខ្លួន។ បច្ចុប្បន្នស្ត្រីជនជាតិវៀតណាមកាត់ចិន ដែលគេស្គាល់ឈ្មោះថា ម៉េង វ័ន្តពិសី (ហៅ សុភា) អាយុ៣៣ឆ្នាំ រស់នៅខណ្ឌពោធិ៍សែន រាជធានីភ្នំពេញ កំពុងត្រូវបានបញ្ជូនខ្លួនទៅកាន់តុលាការក្រុងភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីច្បាប់។

លោក អំ សំអាត មន្ត្រីស៊ើបអង្កេតជាន់ខ្ពស់របស់អង្គការសិទ្ធិមនុស្សលីកាដូបានថ្លែងស្វាគមន៍ចំពោះ ការបង្កើតយន្តការរបស់ក្រសួងការងារនេះ ប៉ុន្តែលោកយល់ថា វាមិនទាន់គ្រប់គ្រាន់ទេ។ សម្រាប់លោក អំ សំអាត លោកចង់ឲ្យមានការបង្កើតច្បាប់ថ្មីមួយ ដើម្បីការពារលើកម្មករការងារផ្ទះនេះតែម្តង៕

## បុរសវ័យចំណាស់ម្នាក់ ចូលទៅកាប់ឈើក្រញូង ក្នុងទឹកដីថៃ ត្រូវទាហានថៃបាញ់ស្លាប់

https://www.dap-news.com/kh/ ថ្ងៃពុធ, ៣០ ឧសភា ២០១៨ 10:11 ដោយ: ដើមអម្ពិល ID:117

**ពោធិ៍សាត់៖** បុរសវ័យចំណាស់ម្នាក់ បានស្លាប់បាត់បង់ជីវិត គួរឲ្យអាណោចអាធម ដោយសារទាហានថៃបាញ់ ខណៈជនរងគ្រោះ ជាជនជាតិខ្មែរម្នាក់នោះ ចូលឆ្លងដែនទៅក្នុងទឹកដីថៃ ដើម្បីកាប់ឈើក្រញូង កាលពីវេលាម៉ោង១៦ និង១៥នាទីថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៨ស្ថិតនៅចំនុចព្រំប្រទល់ ខេត្តត្រាតនៃប្រទេសថៃ ព្រំប្រទល់ខេត្តពោធិ៍សាត់ នៃប្រទេសកម្ពុជា ។

អធិការនគរបាលស្រុកវាលវែង លោកវរសេនីយ៍ទោជាង ឡេង បានប្រាប់ មជ្ឈមណ្ឌលព័ត៌មានដើមអម្ពិល តាមទូរសព្ទនៅព្រឹកថ្ងៃទី ៣០ ខែ ឧសភានេះថា សពជនរងគ្រោះឈ្មោះសុះ សុខ ភេទប្រុសអាយុ ៥២ ឆ្នាំជនជាតិខ្មែររស់នៅភូមិសង្គមថ្មី ឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់។លោកអធិការដដែល ក៏បានឲ្យដឹងទៀត រហូតមកដល់ថ្ងៃនេះ សពជន រងគ្រោះត្រូវបានក្រុមគ្រួសារ យកមកធ្វើបុណ្យតាមប្រពៃណី នៅផ្ទះរបស់ខ្លួន ៕

## តុលាការសម្រេចឃុំខ្លួនស្ត្រីដែលធ្វើទារុណកម្មលើក្មេងជាអ្នកបម្រើ

http://www.rasmeinews.com/ May 30, 2018, 5:26 PM

*ដោយៈសិទ្ធ/ភ្នំពេញ*.៖ថៅកែហាងលក់សម្លៀកបំពាក់ដែលជាប់ពាក់ព័ន្ធករណីធ្វើទារុណកម្មលើក្មេងស្រីជាអ្នកបម្រើបានត្រូវតុលាការសម្រេចកាលពីរសៀលថ្ងៃទី៣០ខែឧសភាឆ្នាំ២០១៨ឃុំខ្លួនដាក់ពន្ធនាគារក្រោមការចោទប្រកាន់ពីបទហិង្សាមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះតាមមាត្រា២១៩នៃក្រមព្រហ្មទណ្ឌ។

យោងតាមមាត្រា២១៩នៃក្រមព្រហ្មទណ្ឌឃើញថា ស្ត្រីរូបនេះត្រូវប្រឈមនឹងការជាប់ពន្ធនាគារពី២ឆ្នាំទៅ៥ឆ្នាំ និងពិន័យជាប្រាក់៤លានរៀលទៅ១០លានរៀល បើសិនជាតុលាការរកឃើញថាមានពិរុទ្ធភាពដូចការចោទប្រកាន់នេះមែន។ ថៅកែហាងរូបនេះឈ្មោះ ម៉េង វ័ន្តពិសី ហៅ សុភាភេទស្រីអាយុ៣៣ឆ្នាំបានត្រូវសមត្ថកិច្ចឃាត់ខ្លួន កាលពីវេលាម៉ោង៥ល្ងាចថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៨ នៅផ្ទះអ្នកលក់សម្លៀកបំពាក់មួយកន្លែង លេខ១០៧អា ខាងត្បូងជាប់ផ្សារបុរីសន្តិភាព២ ភូមិតំណាក់ត្រយឹង សង្កាត់ចោមចៅ២ ខណ្ឌពោធិ៍សែន រាជានីភ្នំពេញ។ ចំណែកក្មេងស្រីរងគ្រោះឈ្មោះជា ស្រីនូ ហៅស្រីពៅ អាយុ១៦ឆ្នាំ មករស់នៅផ្ទះកើតហេតុខាងលើរយៈពេល៤ឆ្នាំហើយ ជាអ្នកធ្វើការងារផ្ទះ មានស្រុកកំណើតភូមិទំនប់ថ្មី ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ក្មេងស្រីរងគ្រោះ មានបងប្អូន៩នាក់ ប្រុស៤នាក់

ស្រី៥នាក់ នាងជាកូនទី៨ មានឪពុក ឈ្មោះ ជា សួ អាយុ៦៨ឆ្នាំ ឈឺនៅកន្ទេល មានម្ដាយឈ្មោះ ឡេ ឡាយ អាយុ៦៥ឆ្នាំ មុខរបរលក់បន្លែ។

តាមការរៀបរាប់របស់ក្មេងស្រីរងគ្រោះ ទាំងទឹកភ្នែក ក្នុងអារម្មណ៍ភ័យញ័រ ប្រាប់សមត្ថកិច្ចថា នាងត្រូវបានស្ត្រីខាងលើ យកមកឱ្យធ្វើការងារ តាំងពីអាយុ១២ឆ្នាំមកម្ល៉េះ ធ្វើជាកូនឈ្នួលបម្រើ ផ្ទះរហូតមកដល់ពេលនេះ អស់រយៈពេល៤ឆ្នាំហើយ។ ស្ត្រីម្ចាស់ផ្ទះ បង្ខំឲ្យធ្វើការងារតាំងពីព្រឹកទល់យប់ បើធ្វើមិនទាន់ទេបានយកដែក វាយពេញរាងកាយក្បាល ជួនយកម្ទូលដេប៉ាក់ មកចាក់លើរាងកាយក្នុង១ថ្ងៃឱ្យហូបបាយ២ពេល ពេលព្រឹក និងពេលល្ងាច ថ្ងៃត្រង់បន្តឲ្យធ្វើការងារ។ ក្មេងស្រីរងគ្រោះ បានបន្តទៀតថា មកស្នាក់នៅធ្វើការដំបូង បានប្រាក់ឈ្នួល៦០ដុល្លារក្នុង១ខែ ទើបតែ១ឆ្នាំមកនេះ បាន១០០ដុល្លារក្នុង១ខែ ហើយខែថ្មីៗនេះ ម្ដាយនាងមានការខ្វះខាត ថវិកា ទិញថ្នាំព្យាបាលឪពុក បានសុំខ្ចីលុយ១០០ដុល្លារមុន។

អ្វីជាងនេះទៅទៀត ម្ចាស់ផ្ទះដាក់បំរាមមិនឱ្យនិយាយរឿង ធ្វើទារុណកម្ម រាងកាយ ប្រាប់អ្នកជិតខាង ឬប្រាប់ដំណឹងដល់ក្រុមគ្រួសារនៅឯស្រុកឡើយ មិនអនុញ្ញាតឲ្យជួបនិយាយជាមួយម្ដាយតាមទូរស័ព្ទទៀតផង។ ករណីខាងលើក្រោយពីទទួលបានព័ត៌មានរាយការណ៍ពីប្រជាពលរដ្ឋ សមត្ថកិច្ចចុះទៅដល់កន្លែងកើតហេតុ ត្រូវបានស្ត្រីខាងលើឡូឡា រករឿងទាំងអ្នកជិតខាង គំរាមវាយស្ត្រីម្នាក់នៅក្បែរនោះ ដែលជួយឈឺឆ្អាលរឿងខាងលើ៕S/

## អធិការស្រុកវាលវែង អប់រំមុខសញ្ញាលួចឆ្លងដែនខុសច្បាប់ ចូលដីថៃកាប់ឈើគ្រញូង ៨នាក់

https://www.dap-news.com/kh/ ថ្ងៃពុធ, ៣០ ឧសភា ២០១៨ 11:47 ដោយ: ដើមអម្ពិល ID:114

ពោធិ៍សាត់៖ អធិការនគរបាលស្រុកវាលវែង កាលពីថ្ងៃទី២៩ ខែ ឧសភាបានធ្វើការអប់រំមុខសញ្ញា លួចឆ្លងដែនខុសច្បាប់ចូលដីថៃ ដើម្បីកាប់ឈើគ្រញូងចំនួន ៨ នាក់ ហើយបញ្ជូនឲ្យត្រឡប់ទីលំនៅឋានវិញ។ អ្នកទាំង៨នាក់នោះរស់នៅភូមិចំបក់ធំ ឃុំប្រាំបីមុំ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ រួមមាន៖

១.ឈ្មោះ នឿន វ៉ាត់ ភេទប្រុស អាយុ ៣២ ឆ្នាំ
២,ឈ្មោះ គល់ រ៉េម ភេទប្រុស អាយុ ៤០ ឆ្នាំ
៣,ឈ្មោះ រ៉េម រាជ ភេទប្រុស អាយុ ១៦ ឆ្នាំ
៤,ឈ្មោះ សុខ រ៉េម ភេទប្រុស អាយុ ៣៦ ឆ្នាំ
៥,ឈ្មោះ ប៉ាង ជា ភេទប្រុស អាយុ ៣៧ ឆ្នាំ
៦,ឈ្មោះ កែប សុខឃឿន ភេទប្រុស អាយុ ២៤ ឆ្នាំ
៧,ឈ្មោះ ជុំ សារ៉ែន ភេទប្រុស អាយុ ៤៥ ឆ្នាំ
៨,ឈ្មោះ វ៉េត រ៉ូ ភេទប្រុស អាយុ ២០ ឆ្នាំ ៕

## ស្ថានតំណាងកម្ពុជា នៅប្រទេសម៉ាឡេស៊ី និងវៀតណាម អន្តរាគមន៍ជួយពលរដ្ឋខ្មែរ១៨នាក់ ឲ្យបានត្រឡប់មកមាតុភូមិវិញ

http://freshnewsasia.com/ 2018-05-30

**(ភ្នំពេញ)៖** ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨នេះ បានចេញសេចក្តីប្រកាសព័ត៌មានមួយ ដោយបញ្ជាក់ឲ្យដឹងថា ស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសម៉ាឡេស៊ី និងស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំទីក្រុងហូជីមិញ ប្រទេសវៀតណាម បានបន្តអន្តរាគមន៍ជួយសង្គ្រោះប្រជាពលរដ្ឋខ្មែរ ចំនួន ១៨នាក់ មកមាតុប្រទេសវិញ។ **បើតាមសេចក្តីប្រកាសព័ត៌មាន របស់ក្រសួងការបរទេសបានបញ្ជាក់ថា៖**

**១៖** ស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសម៉ាឡេស៊ី បានសហការជាមួយអាជ្ញាធរម៉ាឡេស៊ី ដោះស្រាយបញ្ហា និងរៀបចំមាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរ ៩នាក់ មកពីខេត្តកណ្តាល កំពង់ចាម កំពង់ធំ និងស្វាយរៀង ដែលបានធ្វើការដោយខុសច្បាប់នៅម៉ាឡេស៊ី ឲ្យបានត្រឡប់មកដល់កម្ពុជាវិញនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៨។

**២៖** ស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំទីក្រុងហូជីមិញ បានសហការជាមួយអាជ្ញាធរ មានសមត្ថកិច្ចរបស់វៀតណាម ដោយដោះស្រាយបញ្ហា និងរៀបចំឲ្យមាន មាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរ ចំនួន៩នាក់ មកពីខេត្តស្វាយរៀង ដែលចូលទៅស្នាក់នៅ និងប្រកបរបរដោយខុសច្បាប់ នៅវៀតណាម។ ស្ថានអគ្គកុងស៊ុល នឹងជូនពលរដ្ឋទាំង៩នាក់ មកកម្ពុជាវិញ នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៨ ស្អែកនេះ តាមច្រកទ្វារព្រំដែនអន្តរជាតិបាវិត៕

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
======

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
======

**ស្ថានតំណាងកម្ពុជា អន្តរាគមជួយពលរដ្ឋខ្មែរ១៨នាក់**

----------

១. ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ម៉ាឡេស៊ី** បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ម៉ាឡេស៊ី ដោះស្រាយបញ្ហានិងរៀបចំមាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរចំនួន**៩នាក់** មកពីខេត្តកណ្តាល កំពង់ចាម កំពង់ធំ និងស្វាយរៀង ក្នុងនោះបុរសមានចំនួន៥នាក់ និងនារី៤នាក់ ដែលបានទៅធ្វើការដោយខុសច្បាប់នៅប្រទេសម៉ាឡេស៊ី។ ពលករ-ពលការិនីទាំង៩នាក់ បានមកដល់កម្ពុជាវិញ នៅព្រឹកថ្ងៃទី**២៧** ខែ**ឧសភា** **ឆ្នាំ២០១៨** ។

២. ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុង**ហូជីមិញ** បានសហការជាមួយអាជ្ញាធរវៀតណាម រៀបចំមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរ**៩នាក់** (ក្នុងនោះកុមារមានចំនួន៦នាក់) មានអាយុចន្លោះពី០១ឆ្នាំដល់៣២ឆ្នាំ មកពីខេត្តស្វាយរៀង ដែលចូលទៅស្នាក់នៅនិងប្រកបរបរលក់ឆ្នោតដោយខុសច្បាប់នៅក្នុងប្រទេសវៀតណាម។ បច្ចុប្បន្ន ពលរដ្ឋខ្មែរទាំងនោះកំពុងស្នាក់នៅបណ្តោះអាសន្នក្នុងមជ្ឈមណ្ឌលគាំពារសង្គមក្នុងទីក្រុងហូជីមិញ។

ស្ថានអគ្គកុងស៊ុល នឹងជូនពលរដ្ឋទាំង៩នាក់ មកកម្ពុជាវិញ នៅថ្ងៃទី**៣១** ខែ **ឧសភា** ឆ្នាំ **២០១៨** តាមច្រកទ្វារព្រំដែនអន្តរជាតិ**បាវិត** ដើម្បីប្រគល់ជូនអាជ្ញាធរកម្ពុជា ចាត់ចែងបញ្ជូនបន្តទៅស្រុកកំណើត។

ថ្ងៃ ពុធ ១រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ភ្នំពេញ, ថ្ងៃទី ៣០ ខែឧសភា ឆ្នាំ ២០១៨

**ជុំ សុន្ទរី**
**អ្នកនាំពាក្យ**
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## អាជ្ញាធរថៃ បញ្ជូនពលករខ្មែរ១០នាក់ មកស្រុកវិញតាមច្រកទ្វារព្រំដែនអន្តរជាតិចាំយាម

http://cambodiapolice.com/ 10:41 am 31 ឧសភា 2018

**កោះកុង** ៖ ប្រជាពលរដ្ឋខ្មែរចំនួន១០នាក់ លួចឆ្លងដែនខុសច្បាប់ ត្រូវបានអាជ្ញាធរថៃ ចាប់បញ្ជូនមកស្រុកកំណើតវិញតាមច្រកទ្វារព្រំដែនអន្តរជាតិចាំយាម កាលពីល្ងាចថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨។ តាមការសាកសួររបស់កម្លាំងសមត្ថកិច្ចមូលដ្ឋានបានឲ្យដឹងថា ក្រុមគាត់ត្រូវបានអាជ្ញាធរថៃ ឃុំអស់រយៈពេលជិត១ឆ្នាំ នៅខេត្តត្រាត ដោយ

ចោទថា នេសាទទឹករាក់ ក្នុងតំបន់ហាមឃាត់។ ចំពោះពលករទាំងអស់ មានស្រុកកំណើតនៅខេត្តកំពង់ចាម។ បច្ចុប្បន្ន កម្លាំងប៉ុស្តិ៍ច្រកទ្វារ បានអប់រំណែនាំ និងរកមធ្យោបាយសម្រួលដល់ការធ្វើដំណើរ ដល់ពលករ ត្រលប់ទៅស្រុកកំណើតវិញ ៕

## លោកស្រី ម៉ែន សំអន ជំរុញគ្រប់ភាគី ទប់ស្កាត់អំពើហិង្សា គ្រប់រូបភាពលើកុមារ

https://www.dap-news.com/kh/ ព្រហស្បតិ៍, ៣១ ឧសភា ២០១៨ 12:16 ដោយ: ស សំណាង ID:113

**ភ្នំពេញ៖** លោកស្រីកត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច បានជំរុញឲ្យគ្រប់ភាគី ពាក់ព័ន្ធរួមសហការគ្នាទប់ស្កាត់ ការប្រើប្រាស់កំលាំង ពលកម្មលើកម្មកុមារតាមរយៈ ការប្រើអំពើហិង្សា ការជួញដូរ និងការធ្វើទារុណកម្មគ្រប់រូបភាព ។ លោកស្រីឧបនាយករដ្ឋមន្ត្រី ម៉ែន សំអន បានលើកឡើង ក្នុងពិធីអបអរសាទខួបលើក ទី៦ ទិវាកុមារអន្តរជាតិ ១ មិថុនា ឆ្នាំ២០១៨ នាព្រឹកថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ថា ទិវាកុមារអន្តរជាតិ ក្រោមប្រធានបទ ទិវាពិភពលោកប្រឆាំង ពលកម្មកុមារ១មិថុនា ដើម្បីទប់ស្កាត់គ្រោះថ្នាក់ការងារ និងភាពងាយរងគ្រោះផ្នែកសុខភាព សម្រាប់កម្មករ និយោជិតវ័យក្មេង និងលុបបំបាត់ពលកម្មកុមារ ។ ប្រធានបទនេះ ពិតជាមានអត្ថន័យសមស្រប តាមសភាពការណ៍នៅកម្ពុជា។ ពលកម្មកុមារគឺជាបាតុភូត សង្គមដ៏ស្មុគស្មាញដែល មានទំនាក់ទំនងទៅនឹង ទិដ្ឋភាពសេដ្ឋកិច្ចសង្គមកម្ពុជា និងឥរិយាបថសហគមន៍ និងគ្រួសារ។

លោកស្រីបន្តថា "ភាពក្រីក្រ និងការយល់ដឹងរបស់សហគមន៍ ដែលមានកម្រិតទាប គឺជាមូលហេតុចម្បងដែលនាំ ឲ្យមានពលកម្មកុមារ។ ម្យ៉ាងទៀតក្រុមគ្រួសារក្រីក្រ ដែលខ្វះធនធាន ខ្វះជំនាញ មានការអប់រំទាប និងមានប្រាក់ចំណូលតិច ជាមុខសញ្ញាក្នុងការ ប្រើប្រាស់ពលកម្មកុមារ ដើម្បីទ្រទ្រង់ជីវភាពរស់នៅ ប្រចាំថ្ងៃរបស់ពួកគេ។ ដោយសារមូលហេតុនេះ គេសង្កេតឃើញពលកម្មកុមារ នៅតែមានក្នុងតំបន់មួយចំនួនកម្ពុជា" ។ លោកស្រីបន្ថែម រាជរដ្ឋាភិបាលបាន ចាត់ទុកការលុបបំបាត់ ពលកម្មកុមារជា បញ្ហាអាទិភាពមួយ ។ ដើម្បីចាត់វិធានការ មានប្រសិទ្ធភាព ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានពង្រឹងការទប់ស្កាត់ ការប្រើប្រាស់ពលកម្មកុមារ ដោយផ្តោតលើ គោលការណ៍ចម្បង៣ គឺ៖ ការដកហូតកុមារពី ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ , សហការជាមួយសង្គមស៊ីវិល និងការប្រយុទ្ធប្រឆាំងការជួញដូរស្ត្រី និងកុមារ និងការលើកកម្ពស់ការងារសមរម្យ និងសុវត្ថិភាពការងារកុមារ ។

សូមបញ្ជាក់ថា រាជរដ្ឋាភិបាលបានបង្កើត គណៈកម្មាធិការជាតិ ប្រឆាំងពលកម្មកុមារ កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៦ ដឹកនាំដោយក្រសួងការងារ ដើម្បីជំរុញការអនុវត្ត គោលនយោបាយ ផែនការសកម្មភាពជាតិ បទដ្ឋានច្បាប់ បទប្បញ្ញត្តិទាំងឡាយដែល ពាក់ព័ន្ធនឹងការលុបបំបាត់ ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ពិនិត្យតាមដាន និងវាយតម្លៃលើ ការអនុវត្តអនុសញ្ញា នៃអង្គការពលកម្មកុមារ និងសហការជាមួយក្រុមប្រឹក្សាជាតិ កម្ពុជាដើម្បីកុមារអនុវត្ត អនុសញ្ញាស្តីពីសិទ្ធិកុមារ ៕